
គង្គ ប៊ុនឈឿន

គង្គ ប៊ុនឈឿន

សូមជូនរឿង

# ស្ដីឲសម្លាប់

(ប្រលោមលោកមនោសញ្ចេតនា)

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

013503

ការផ្សាយរបស់

បណ្ណាល័យ ឆពណ្ណរង្សី

ថ្ងៃទី ... ខែ ... ឆ្នាំ 2006

រក្សាសិទ្ធិគ្រប់បែបយ៉ាង

ចេញផ្សាយឆ្នាំ ២០០៦ ✓

# អារម្ភកថា

**ស្ទឹងសង្កែ** មិនត្រឹមមានឈ្មោះជាស្ទឹងកវីនិពន្ធ ឬជាស្ទឹងទឹកខ្មៅ ដែលអ្នកនិពន្ធមនោសញ្ចេតនាគ្រប់ជំនាន់ ជ្រលក់សរសេរមិនចេះរីងស្ងួតនោះឡើយ ថែមទាំងមានឈ្មោះអាថ៌កំបាំងមួយទៀត គឺជាស្ទឹងសម្ងាត់ ដែលបង្កប់លាក់ទុករឿងរ៉ាវស្នេហាសោកសង្រេងរបស់ក្រមុំអភ័ព្វមួយរូប នៅឃុំព្រែកហ្លួង ស្រុកសង្កែ[១] ខេត្តបាត់ដំបង តាំងពីជំនាន់ ដែលស្រុកទេសទើបបានទទួលឯករាជ្យថ្មីៗ ពីនឹមដែកអាណានិគមបារាំង ។

ទោះបីរឿងនោះ កន្លងទៅប្រមាណ ៥០ឆ្នាំហើយក្តី ក៏កម្លាំងនៃក្តីស្នេហ៍បរិសុទ្ធរបស់យុវនារី ដែលដើរខុសផ្លូវ នៅតែមានឥទ្ធិពលមកលើសន្តានចិត្តយុវវ័យគ្រប់ជំនាន់ ហើយវាពិតជាចិតនៅជាមេរៀនអមតៈ ជាប់រៀងរហូតនៅលើរលកទឹកនៃដងស្ទឹងមួយ ដែលមានត្រើយពីរចែកដាច់ពីគ្នា ។

មិនតែប៉ុណ្ណោះ វាជាកញ្ចក់ឆ្លុះឱ្យឃើញ នូវភាពល្ងិតល្ងង់របស់ក្រមុំ ចំពោះសេចក្តីស្នេហានាសម័យនោះ តើខុសប្លែកពីសេចក្តីស្នេហារបស់កម្លោះក្រមុំយើង នាសម័យបច្ចុប្បន្ននេះយ៉ាងណាខ្លះ ?

មិនដឹងថាតើ ព្រលឹងរបស់រំដួលព្រែកហ្លួង ដែលស្លាប់ទៅយូរឆ្នាំហើយនោះ ដឹងថាខ្ញុំបានសរសេររឿងរបស់នាង ឬយ៉ាងណានោះទេ ? ប៉ុន្តែខ្ញុំវិញ តែងគិតដល់នាងជានិច្ច បានជាខំស្រាវជ្រាវរឿងពិតនេះ មកសរសេរឡើងវិញ ព្រោះគាត់ត្រូវជាម្តាយមីងជីដូនមួយរបស់ខ្ញុំ ! ។

ចាប់សរសេរនៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០២

នៅខេត្តនន្ទបុរី ប្រទេសថៃឡង់ដ៍

**គង្គ ប៊ុនឈឿន**

---

១-បច្ចុប្បន្ន ឃុំព្រែកហ្លួង នៅក្នុងស្រុកឯកភ្នំ

# ១

# ផ្កាមួយកន្លង់បី

**ខេត្ត**បាត់ដំបង នៅរវាងឆ្នាំ ១៩៥៣...

ម៉ោង១២ អាធ្រាតទៅហើយ សព្វសត្តនិករកំពុងសម្ងំចូលនិទ្រាយ៉ាងលង់លក់ស្ងប់ស្ងាត់ តែរលកទឹកក្នុងដងស្ទឹងសង្កែ មុខឃុំព្រែកហ្លួង ហាក់មិនបានសម្ងំពួនស្ងួនដំណេកសោះឡើយ គឺនៅតែកំរើករញ្ជួយជាប់ជានិច្ច តាមទម្ងន់បក់បោកនៃជំនោរខ្យល់ដងស្ទឹង និងបញ្ចេញពន្លឺព្រេចៗ ក្រោមស្រមោលរស្មីព្រះច័ន្ទ ១៣ កើត ។

នៅកណ្តាលរនាំងរាំងននសន្ធិយាដ៏ស្ងាត់ឈឹងនេះ ស្រាប់តែមានសម្លេងឆ្កែព្រូសលាន់ទ្រហឹង នៅក្នុងទីធ្លាមុខគេហដ្ឋានរបស់មេឃុំរ៉ាត ដែលចិតនៅក្រោមម្លប់ដើមដូងភ្ជីរជាំងៗ ធ្វើឱ្យរន្ធត់ញាប់ញ័រដល់ដំណេកអ្នកដែលកំពុងនិទ្រា នៅក្នុងផ្ទះ ÷

-« ឪរ៉ា !... ភ្ញាក់ឡើង !....» សម្លេងមីងទ្នួនដាស់ប្តីក្រោយដែលងើបឡើងលួនចេញក្រៅមុង ទៅលួចមើលតាមប្រហោងជញ្ជាំងក្តា «....ពួកឥស្សរៈ មកប្លន់ផ្ទះយើងទេដឹង !.... ខ្ញុំឃើញពួកវាជិះសេះប្អូនប្រាំនាក់ហ្ន៎ ?...»

មេឃុំភាត ភ្ញាក់ឡើងរាងស៊ើងមមើងបន្តិច ទើបខ្សឹបដាក់ត្រចៀកប្រពន្ធវិញ ក្រោយដែលបើកមុងចេញមកក្រៅដែរ ÷

-« អ្ហ៎,... ម៉ែវាកុំនិយាយអីចឹង ពួកឥស្សរៈជាពួកអ្នកតស៊ូរំដោះជាតិពីខ្មាំងបារាំង គេមិនមកប្លន់អីអ្នកស្រុក ដូចជាពួកចោរនោះទេ !... ក្រែងពួកនេះ ជាពួកចោរណាំ !.... បានជាវាមកទាំងកណ្តាលយប់ដូច្នេះ ?...»

-«....អ៊ើ ឥស្សរៈឬចោរ ដូចតែគ្នាទេឥឡូវនេះ !....» មីងនួនឆ្លើយកាត់ «...បើស្រុកបានឯករាជ្យហើយ វាមិនព្រមចូលខ្លួនមកសារភាពរួបរួមជាមួយរាជការ គឺពួកវានៅជាចោរព្រៃអីចឹង ?...»

មេឃុំភាត ទំនងជាមិនបានឮពាក្យអង្វរទាំរបស់ប្រពន្ធ នៅឃ្លាទីពីរនេះឡើយ ព្រោះថ្លង់នឹងសម្លេងឆ្កែព្រូសពេក ទើបលួនទៅពិនិត្យមើលតាមប្រហោងជញ្ជាំងក្តា ដើម្បីឱ្យបានច្បាស់ តើពួកណាជាពួកណា ? ។

អាស្រ័យដោយ រស្មីព្រះច័ន្ទដ៏ថ្លាបំព្រងនោះ មេឃុំភាតអាចមើលស្គាល់ជនដែលជិះសេះទាំងប្រាំ ប្រដាប់ដោយកាំភ្លើងវែងស្ពាយនៅស្មាគ្រប់គ្នា ទើបងាកមកខ្សឹបប្រាប់ប្រពន្ធដែលលូនមកជិតដែរថា ÷

-« មិនមែនចោរទេ ពួកនេះអញស្គាល់ច្បាស់ គឺជាពួកលោកត្រឡែ មេឥស្សរៈ ដែលធ្លាប់មកលេងផ្ទះយើងប្អូនប្រាំដងហើយនោះអី ហ្នុំ ! ម្នាក់ដែលជិះសេះស មាឌមាំជាងគេ គឺជាលោកនោះហើយ !...»

មីងនួន ដែលដាក់ភ្នែកតាមប្រហោងជញ្ជាំងជាប់ជានិច្ចដែរ ក៏

រអ៊ូដាក់ប្ដីទៀត ÷

-« នៅហៅវាលោកធើអីទៀត វាមិនមែនជាមេកស្សរះរំដោះជាតិស្អីនោះទេ គឺវាជាមេចោរដើរធ្វើបាបឆក់ប្លន់ កាប់សម្លាប់អ្នកស្រុក ! គេនិយាយរអ៊ូរអរាមអស់ហើយ តាំងពីស្ទឹងចាស់ រនោមដូនសំ រហូតមកដល់ខ្ពប ព្រែកហ្លួងយើងនេះ !...»

-« អ៊ើ.... ហ៊ី ក៏អញមិនដឹង អ្នកស្រុកមកប្ដឹងអញពីរឿងហ្នឹងតែរាល់ថ្ងៃដែរតើ !... ព្រោះតែរឿងហ្នឹងហើយ បានជាអញរារែកមិនយល់ព្រមតាមបំណងរបស់គេ ដែលមកសុំស្ដីដណ្ដឹងរំដួលកូនយើងនោះណា !..»

-« បើទុកណាជាឪវាឯងព្រម ក៏ខ្ញុំមិនព្រមដែរ ខ្ញុំមិនឱ្យកូនយើងទៅធ្វើជាប្រពន្ធមេចោរ ដែលគេកំពុងជេរប្រទេចផ្ដាសាពេញស្រុកពេញភូមិនោះទេ !... តែឆ្ងល់... តើយប់នេះគេមកធ្វើអីទៀត ?..»

-« អ៊ើ... មិនដឹងដែរ ចាំមើលមើល៍ ?...»

សម្លេងជជែកគ្នារបស់មេឃុំរ៉ាត និងមីងទួនជាប្រពន្ធនេះ មិនបានឮដល់ត្រចៀកភេរវជនទាំង ៥ នោះឡើយ ព្រោះផ្ទះមេឃុំធំខ្ពស់ពីរចូលមិនទើសខ្នង ត្បិតផ្សំពេលនោះ ឆ្កែជាច្រើនបានចោមរោមព្រួស លាន់ទ្រហឹងស្ទើរស្ដាប់អ្វីមិនឮទៀតផង ។

ភេរវជនជិះសេះឈ្មោះត្រឡៃ ដែលមួយសន្ទុះធំមកហើយ នៅអង្គុយលើខ្នងសេះ ញាក់ខ្សែរេរាចុះឡើង ដោយធុញថប់នឹងសម្លេងឆ្កែព្រូសពេកនោះ ក៏បោះកន្ទុយបារីបាស្សតុស[១] ចោល ហើយស្រែក

១- BASTOZ ឈ្មោះប្រភេទបារីបញ្ចប់ម៉្យាងនាសម័យនោះ

បញ្ជាទៅកាន់សហការីថា ÷

-«នែ៎ រ៉ី ថ្ងៃណាស់ រកគិតអីមិនឃើញទេ ចាត់ការបំបិទសម្លេងវាខ្លះទៅមើល៍...! »

ជនម្នាក់ដែលជិះសេះនៅក្បែរ គ្រាន់តែទទួលសម្លេងបញ្ជាស្ទើរមិនទាន់ ក៏លើកកាំភ្លើងគាស់កៃតំរង់ទៅរកឆ្កែមួយហ្វូង ដែលកំពុងរត់ប្រជែងដណ្ដើមគ្នាព្រួសជុំវិញសេះទាំងប្រាំ ! ផាំង ! ផាំង !... សម្លេងកាំភ្លើងពីរគ្រាប់ បានដាស់អារម្មណ៍រាត្រីដ៏ពុះកញ្ជ្រោល និងចាប់កញ្ឆក់យកជីវិតឆ្កែពីរក្បាល ដែលមុននេះបន្តិច កំពុងសប្បាយនឹងព្រួសហៅរកព្រៀវនោះ ឱ្យប្រកាច់ដួលរមៀល ធ្លាក់អណ្ដាតដាច់ខ្យល់ស្លាប់នៅក្បែរគល់ដូងភ្លាម ធ្វើឱ្យឆ្កែដែលនៅសល់ទាំងប៉ុន្មានផ្អើលរត់បែកខ្ញែកគ្នា ចេញពីទីលានមុខផ្ទះអស់រលីង ។

ក្រោយដែលលបមើលឃើញ ភេរវជនបាញ់ឆ្កែរបស់ខ្លួនហើយ មេឃុំវ៉ាតក៏ពុះកញ្ជ្រោលឈាមក្ដៅពេញទ្រូងឡើងភ្លាម ដៃវាចាប់យកដាវពីក្រោមកន្ទេលមកក្ដាប់យ៉ាងណែន និងឆៀតទៅបញ្ជាក់ប្រាប់ភរិយាថា ÷

-«នែ៎ ម៉ែវ៉ា ពួកហ្នឹងច្បាស់ជាមកបង្ករឿងជាមួយយើងហើយយប់នេះ ! ទៅប្រាប់រំដួលកូនយើងឱ្យលបបើកទ្វារចុះតាមជណ្ដើរក្រោយ ទៅពួននៅក្បែរជង្រុកស្រូវភ្លាមទៅ !...»

មីងទួន មិនទាន់បានរំលៀកខ្លួនរំកិលចេញផង ស្រាប់តែលេចស្រមោលរាងដ៏ល្វតល្វន់របស់កញ្ញារំដួល បួលមកដល់ជែបអ្នកទាំងពីរភ្លាម បន្ទរដោយសំនៀងព្រួយបារម្ភថា ÷

-«ពុក !... ម៉ែ !.... អ្នកណាបាញ់អីហ្នឹង ?...»

មីងទួន ងាកទៅខ្សឹបដាក់ត្រចៀកកូនក្រមុំភ្លាម ÷

-«នែ៎ រំដួល ពុកឯងឱ្យប្រញាប់ចុះតាមក្រោយ ទៅពួនទៅឯជង្រុកស្រូវភ្លាមទៅ ពួកអាត្រមៃ្ទមកទៀត...ហើយ !..»

គ្រាន់តែស្ដាប់ឮនូវពាក្យសំដីរបស់ម្ដាយ កញ្ញារំដួលក៏ប្រញាប់ចាកចេញពីទីនោះទៅភ្លាម នៅចន្ទឹមនឹងសំរែករបស់មេភោរវាជនត្រមៃ្ទស្រែកពីក្រោមមកថា ÷

-«យី អ៊ើ... មេឃុំរ៉ាត !... យើងមកដល់ជិតកន្ទះម៉ោងទៅហើយ មិនព្រមបើកទ្វារចេញមកទទួលហៅរកយើង ឱ្យឡើងទៅអង្គុយលេងលើផ្ទះផងសោះហ្ន៎ !...»

មេឃុំរ៉ាត ក្នុងវ័យប្រមាណ៥០ឆ្នាំ ជាមនុស្សរឹងប៉ឹងមិនងាយតក់ស្លុតនៅចំពោះមុខសភាពការណ៍អ្វីឡើយ ។ បន្ទាប់ពីឮសំដីរបស់មេចោរត្រមៃ្ទ មេឃុំរ៉ាតក៏ងាកមកខ្សឹបដាក់ប្រពន្ធទៀតថា ÷

-«ឯង ទៅយកគាំភ្លើងមកដាក់អែបទ្វារនេះ ទុកឱ្យអញ !... អញចេញទៅជួបពួកវាមួយភ្លែត !...»

-«ផុតបង្កៀត ឬយ៉ាងម៉េចហ្នឹង ឪវា ?...»

-«មិនបាច់ទេ !... ប្រយ័ត្នប្រយែងតែរំដួលទៅបានហើយ!...»

-«មិនអីទេ... ខ្ញុំបានប្រាប់វា ឱ្យចុះទៅពួននៅឯជង្រុកស្រូវហើយ !...»

មិនបង្អង់ឱ្យយូរ មេឃុំរ៉ាតក៏កាន់ដាវសំរបខ្លួនមិនឱ្យពួកចោរឃើញ ហើយបើកទ្វារចេញទៅអង្គុយនៅកាំជណ្ដើរលើបំផុត ហើយ

បន្ទីបណ្តើរថា ៖

-« ធើម៉េចនឹងយើងដឹង ថាពួកអស់លោកឯងមកទាំងកណ្តាលអាធ្រាតហ្នឹង ហើយម៉េចក៏ព្រហើនហ៊ានបាញ់ឆ្កែរបស់យើង ដែលយើងចិញ្ចឹមឱ្យចាយសុី ?....»

នាយត្រមែ្ល ដែលមានវ័យប្រមាណ ៤០ ឆ្នាំដែរ សើចយ៉ាងស្រួលពីលើខ្នងសេះ ភ្ជាប់ដោយសំនៀងពាក្យ ៖

-« ព្រោះយើងមកម្តងនេះ មានការសំខាន់ចង់មកបញ្ជាក់ជាមួយលោកមេឃុំវ៉ាតឯង បើទុកឱ្យវានៅស្រែកព្រូសលាន់ទ្រហឹងបែបហ្នឹងនិយាយការអីកើតទៅ ?...»

ប្រមុខឃុំព្រែកហ្លួង សួរមកវិញដោយគ្មានញញើតមាត់ ៖

-« បញ្ជាក់រឿងអីទៀត ឬមួយក៏រឿងចង់មកដណ្តឹងកូនយើងហ្នឹង ?...»

នាយត្រមែ្ល បង្ហើរសំណើចមច្ចុរាជគួរឱ្យព្រឺ ៖

-« ត្រូវហើយ គឺយើងចង់មកសួរបញ្ជាក់ជាចុងក្រោយថា តើលោកមេឃុំព្រមលើកកូនឱ្យយើង ឬមិនព្រម ព្រោះយើងចូលមកស្តីដណ្តឹងបីដងហើយណា !...»

ប្រមុខឃុំព្រែកហ្លួង គិតបន្តិចទើបឆ្លើយយ៉ាងអង់អាច ៖

-« មុនដំបូងយើងគិតថាឱ្យដែរ ព្រោះកូនក្រមុំយើង ៗមិនទុកធ្វើអីទេ យើងចូលចិត្តណាស់មនុស្សដែលមានស្មារតីភ្ញាក់រលឹក រួមចំណែកក្រោកឈរដេញចារាំងអាណានិគមនេះ ប៉ុន្តែក្រោយពីយើងដឹងថា ឈ្មោះអ្នកឯងនេះមិនល្អទេឥឡូវនេះ គឺអ្នកឯងមិនមែនជាអ្នក

ស្រលាញ់ឥស្សរៈភាព បែរជាតាំងខ្លួនជាឧច្ចាមចោរព្រៃទៅវិញដូច្នេះ យើងសូមប្រកាសនៅពេលនេះថា យើងមិនឱ្យទេ សូមអ្នកឯងថយទៅរកស្រីឯណាផ្សេងទៅ !...»

គេហាក់ដូចជាមិនឃើញប្រតិកម្មអ្វី ចេញពីនាយត្រៃឡែមកវិញឡើយ ក្រៅតែពីគេសួរបញ្ជាក់តបស្នងដោយអារម្មណ៍ត្រជាក់ថា ៖

-«ហ្អឹងលោកមេឃុំ សំរេចចិត្តស្រួលបួលហើយឬ បានជាហ៊ាននិយាយបែបនេះមកកាន់ត្រៃឡែយើង ឬមួយក៏ទើបតែងើបពីដេកមកស៊ើងមមើង មិនដឹងថាយើងជាអ្វី ?...»

មេឃុំវ៉ាត ស៊ើបយ៉ាងស្រួលក្នុងរលកសម្លេង ៖

-«យើងមិនមែនមមីមមើ ស៊ើងមមើងអីនោះទេ គឺយើងស្គាល់ពួកឯងច្បាស់ហើយនាយត្រៃឡែ ដែលធ្លាប់តែគំរាមចាប់កូនប្រពន្ធគេរាប់មិនអស់មកហើយនោះ ?...»

ភេរវជន បន្តរប្រយោគព្រៃផ្សៃមកទៀត ៖

-«ចុះបើដឹងដែរ ម៉េចក៏លោកមេឃុំមិនឆ្លើយថាព្រមឱ្យយើងមក កុំឱ្យយើងពិបាកលេងធមីក្ដៅ ប្រើគេឱ្យឡើងចាប់អូសកូនក្រមុំចុះពីលើផ្ទះមកនោះ តែទោះបីយ៉ាងណាក៏យើងមិនធ្វើបាបរំលោភដូចស្រីមុនៗដែរ ព្រោះយើងស្រឡាញ់រំដួលពិត ចង់បាននាងយកទៅធ្វើជាប្រពន្ធពេញលក្ខណៈ !...»

-«ស្អីក៏ដោយ យើងមិនព្រមទេ !...» មីងទួនស្រែកប្រកាសមកពីក្រោយទ្វារ ធ្វើឱ្យមេឃុំវ៉ាតកាន់តែមានកម្លាំងចិត្ត តំរាមតបទៅមេឧច្ចាមវិញភ្លាមថា ៖

-«យើងគិតរួចជាស្រេចថា ឯងច្បាស់ជាប្រើសំដីបែបនេះដើម្បីគំរាមយើង តែពួកឯងប្រទាំហើយ មេឃុំវ៉ាតយើងនេះកាន់ការមកជាង ២០ ឆ្នាំហើយ មិនដែលចាញ់សំឡុតពួកក្រុមចោរណាទេ ហើយឯងកុំសង្ឃឹមឱ្យសោះថា យប់នេះ ឯងនឹងអាចធ្វើអ្វីតាមចិត្តឯងបាននោះ ?...»

មេចោរត្រឡៃ គំរាមជាចុងក្រោយ ÷

-«យើងក៏ចង់ឃើញដែរ តើយប់នេះ មេឃុំវ៉ាតដ៏ខ្លាំងពូកែការពារកូនក្រមុំរបៀបណាទៅ ?...»

នៅភ្ជាប់នឹងឃ្លារបស់មេចោរ គេឮសួរសម្លេងមីងទួនខ្សឹបពីក្រោយទ្វារមកប្រាប់ប្ដីថា ÷

-«នែ៎ ឪវ៉ា មិនស្រួលទេអីង ខ្ញុំគួរទៅប្រាប់ពួកទាហានសាលាឃុំឬយ៉ាងណា ?...»

-«គ្មានទាហានណានៅទេ អញប្រើឱ្យពួកវាទៅតាមចាប់ចោរលួចក្របីនៅឯព្រៃរនាម តាំងពីម្សិលមិញអស់ទៅហើយ នៅតែអាយស់ម្នាក់ វាដេកយាមសាលាឃុំ តែកំពុងឈឺគ្រុនចាញ់ផង បើប្រាប់ក៏វាគ្មានកម្លាំងមកធ្វើអីកើតដែរ ឯងកុំភ័យពេក ខំទប់ចិត្តនៅឱ្យស្ងៀមទៅ មានអញនៅទីនេះ ពួកវាមិនហ៊ានធ្វើអីផ្ដេសផ្ដាសទេ !...»

ដោយឃើញមេឃុំវ៉ាត ងាកមកខ្សឹបដាក់ភរិយា នាយត្រឡៃទឹកស្មានតែ មេឃុំភ័យស្លន់ស្លោរចាញ់ពាក្យសំឡុតគំរាមរបស់គេ ទើបស្រែកបញ្ជាទៅកាន់ដៃជើងរបស់គេថា ÷

-«នែ៎ ចាំអីទៀត អាឆ្ការ អាក្រាញ់ !... មេឃុំវ៉ាតមិនព្រម

លើកកូនឱ្យអញទេ ឡើងទៅចាប់កូនក្រមុំវាភ្នាមម៉ោ វាពិតជាសម្ងំនៅលើផ្ទះហ្នឹងហើយ !...»

អាក្រាញ់ លោតពីខ្នងសេះភ្លែត ស្ទុះផ្ងោតមុនអាឆ្ការរបៀបមើលងាយម្ចាស់ផ្ទះ ស្មានតែគាត់ថាបានតែមាត់ ប៉ុន្តែគ្រាន់តែអាក្រាញ់ ឡើងបានប្រាំកាំជណ្ដើរប៉ុណ្ណោះ មេឃុំវ៉ាតក៏ស្ទុះផ្លារ ដកដាវចេញពីក្បែរខ្លួន លោតទៅកាប់អាក្រាញ់ចំស្មាស្ដាំឮសូរភ្លិប ! ភ្លិប !. ដោយគ្មានខុសបន្តិចណាឡើយ ព្រោះខែភ្លឺច្រឡាក់ ។ ផ្លែដាវដែលសំលៀងទុកមកជាយូរ ហើយដែលមុតអាចកោររោមជើងបាននោះបានផ្ដាច់ដៃស្ដាំអាក្រាញ់ស្ទើរលេះដាច់ចេញពីស្មា បណ្ដាលឱ្យវារបូតកាំភ្លើងពីដៃ និងស្រែករោទិ៍ស្ទើរដាច់កន្ទើត ខ្វាំងជាងក្ដៅត្រូវគ្រាប់ទៅទៀត ហើយរិលខ្លួនដួលផ្ងារបះជើងទៅក្រោយ ធ្លាក់ពីជណ្ដើរទៅដីជាដំណាំ ព្យួជាមួយឈាមខ្មៅពាញ់ពារ ស្រោចទៅលើមុខអាឆ្ការដែលស្ទុះមកតាមក្រោយ ។

អាឆ្ការ ឃើញដូច្នោះក៏ស្ទុះតែបីជំហាន លើកកាំភ្លើងបាញ់សំដៅមករកមេឃុំវ៉ាតភ្នាម តែគាត់គេចផុតស្ទុះឡើងចូលមកក្នុងផ្ទះវិញ ឆក់បានកាំភ្លើងវែង ដែលមីងទួនយកបំរុងទុកឱ្យជាស្រេច ហើយគាស់កៃបាញ់ទៅអាឆ្ការកតញញៀត ឃោន់ផាំង ! ផាំង ! មិនឱ្យវាឡើងមកតាមជណ្ដើររួចឡើយ ។

ចំណែកនាងរំដួល ដែលចុះតាមជណ្ដើរក្រោយរត់ទៅពួននៅក្បែរជង្រុក មិនសុខមិនសាប់ ក៏ស្ទុះរឹងរត់ចេញតាមប្រឡោះរបងក្រោយសំដៅទៅប្រាប់កំលោះយស់ ដែលគេក្ដៅខ្លួនដេកគ្រុននៅក្នុងសាលា

ឃុំ ÷

-«បងយស់ ! ពួកកាំភ្លើងទេ !... លឿនឡើងប្រញាប់ទៅជួយពុកផង ពួកមេចោរត្រៃឡៃវាមកអុកឡុកទៀតហើយ !..»

យស់ ជាយុវជនទាហានឃុំដែលក្រតោកយ៉ាកបំផុត កំព្រាឪពុកមានតែម្ដាយ ហើយធ្លាប់លួចស្រឡាញ់នាងរំដួលកូនមេឃុំវាតមកយូរហើយ តែចាស់ៗមិនដឹងឡើយ ដឹងតែនាងរំដួលប៉ុណ្ណោះ ។ រំដួលមិនជាស្អប់យស់ទេ ព្រោះពិតមែនតែយស់ក្រ តែនាងសំគាល់ឃើញថា យស់ជាយុវជនតស៊ូអំណត់អត់ធន់ ធ្លាប់បានបួសរៀន និងមានកិរិយាមារយាទត្រឹមត្រូវ សុភាពរាបសារ គួររាប់អានពឹងពាក់បាន។ ប៉ុន្តែមកទល់ថ្ងៃនេះ នាងមិនទាន់ទុកយស់ជាបុរសក្នុងបេះដូងនាងនៅឡើយ គឺគ្រាន់តែកត់សំគាល់ក្នុងក្រសែភ្នែកនាងប៉ុណ្ណោះ ។

ក្រោយដែលឮសួរកាំភ្លើង និងឃើញនាងរំដួលរត់ទៅប្រាប់ទាំងត្រហេបត្រហបដូច្នោះ ទោះបីជាគេកំពុងមានជម្ងឺគ្រុនញាក់មិនទាន់ស្វាងស្រឡះនៅឡើយក៏ដោយ ក៏យស់មានកម្លាំងព្រឺស ហាក់ដូចមិនឈឺអ្វីទាំងអស់ ហើយស្ទុះក្រោកចាប់ទាញកាំភ្លើងដែលបញ្ឈរនៅក្បែរងាកមកសួររំដួលយ៉ាងខ្លីថា ÷

-«...ខ្ញុំដឹងហើយ អាមេចោរត្រៃឡៃ វាច្បាស់ជាមកសួររឿងរំដួលឯងហ្នឹងហើយ !... ខ្ញុំត្រូវ...តែទៅប្រដៅ...វា !...»

-«តែ វាមានគ្នាច្រើនណាស់ ប្រយ័ត្ន !...»

-«ច្រើនប៉ុណ្ណាក៏ដោយ ខ្ញុំមិនខ្លាចទេ !...»

នៅពេលដែលរំដួលពួននៅសាលាឃុំ យស់ក៏កាន់កាំភ្លើងហាក់

កាត់របងចូលមកតាមក្រោយផ្ទះមេឃុំវ៉ាត ដែលពេលនោះ គេឃើញគាត់កំពុងបាញ់តទៅរកពួកចោរពីលើផ្ទះ ។ យស់ខំអែបខ្លួននឹងសសរផ្ទះ យកទីតាំងចំណាប់ចំនួនបានហើយ ក៏បាញ់សំដៅអាឆ្កែរ ដែលវាកំពុងពួននៅអែបក្បាលជណ្ដើរ បាញ់តបទៅលើផ្ទះវិញ ។

អាឆ្កែរភ្លេចខ្លួនក៏ត្រូវមួយគ្រាប់របស់យស់ ចំថ្ងាសបែកលលាដ៍ធ្លាយខួរ ដួលប្រកាច់ស្លាប់ភ្លាម ក្រោយពីស្រែកអ៊ូយបានតែមួយម៉ាត់។

មេឃុំវ៉ាត ដែលមិនបានចាប់ភ្លឹកថា នាយយស់បានមកពួនបាញ់ពីក្រោមផ្ទះ ប្រឡំស្មានតែអាឆ្កែរត្រូវនឹងគ្រាប់របស់គាត់ ក៏បើកទ្វារចុះចេញទៅដើម្បីចង់មើលឱ្យច្បាស់ ។ ប៉ុន្តែក្នុងមួយវិនាទីដ៏អកុសលនោះ មេចោរត្រឡៃ គ្រាន់តែឃើញមេឃុំវ៉ាតបញ្ចេញខ្លួននៅលើកាំចណ្ដើរភ្លាម វាក៏លើកកាំភ្លើងបាញ់ផាំង ! មក ដោយបេះដូងក្ដៅរោលបំផុត បណ្ដាលឱ្យចំដើមទ្រូងមេឃុំមួយគ្រាប់យ៉ាងដំណំ ÷

-«អ៊ូយ !... ម៉ែវ៉ា អញត្រូវគ្រាប់ !... វាហើយ !..»

មីងនួនភ័យស្ទន់ស្ទោរ ក៏ស្ទុះចេញទៅជួយគ្រាហ៍យកប្ដីដែលត្រូវគ្រាប់ ឡើងមកលើផ្ទះវិញ នៅពេលដែលអាចោរពីរនាក់ទៀត កំពុងតែបាញ់សំដៅទៅរកចំណុចរបស់យស់ ។ ឯនាយត្រឡៃខំបាញ់បន្ថែមមករកមេឃុំវ៉ាតទៀត ប៉ុន្តែមិនត្រូវសោះ វាក៏លោតពីខ្នងសេះ ប្រុងរត់ឡើងតាមចណ្ដើរចូលទៅចាប់នាងវិម្ពល ដែលវានឹកស្មានថានាងពួនសម្ងំនៅលើផ្ទះ ។

ប៉ុន្តែ គោលដៅរបស់ជនទុរយសនេះ ក៏មិនបានសំរេចដែរ ព្រោះក្នុងពេលដ៏ប្រថុចញ៉ុចនោះ ស្រាប់តែមានស្នូរកាំភ្លើងលាន់ឮពីទី

ផ្សេង បាញ់ចម្រុះមករកក្រុមចោរ និងបាញ់ស្កាត់មិនឱ្យអាមេចោរឡើងទៅលើផ្ទះបានឡើយ ។

យល់អាសន្ន អាមេចោរត្រឡែក៏លោតឡើងលើខ្នងសេះវិញ នៅពេលដែលគ្នាវាម្នាក់ទៀតត្រូវគ្រាប់ស្លាប់ទៀត រួចវាក៏ស្រែកហៅអាម្នាក់ដែលនៅសល់ឱ្យភៀសខ្លួន បំផាយសេះចេញពីទីនោះទៅជាមួយវាភ្លាម ក្រោមស្នូរគ្រាប់កាំភ្លើងបាញ់ប្រដេញតាមពីក្រោយ លាន់ដូចរន្ទះ ។ ប៉ុន្តែមុននឹងចេញផុតពីរបងផ្ទះ មេចោរត្រឡែមិនភ្លេចនឹងលើកកាំភ្លើងបាញ់ផ្តាច់ជីវិតអាក្រាញ់ ដែលត្រូវមេឃុំវ៉ាតកាប់ត្រូវពីរផ្លែដាវមិនទាន់ស្លាប់នោះផងឡើយ និងស្រែកដង្ហោយជាចុងក្រោយថា ÷

-« បើអញយកមេរំដួលធ្វើជាប្រពន្ធមិនបាន អញឈប់ជាន់ដីព្រែកហ្លួងនេះ !...»

ក្រោយដែលភេរវជនកំណាចចេញផុតទៅ យស់ក៏ស្ទុះពីក្រោមផ្ទះផ្លោះតាមជណ្តើរឡើងទៅលើ ដើម្បីជួយមើលមេឃុំវ៉ាត ដែលកំពុងមានរបួសធ្ងន់ធ្ងរ ។ កញ្ញារំដួលក៏បានមកដល់ជាបន្ទាប់ដែរ ហើយសំខាន់ជាងនេះ គឺទាហានប្រាំរូបបានឡើងដល់ក្រោយគេ ដែលក្នុងចំណោមនោះ ទាហានម្នាក់រូបស្រស់សង្ហារជាងគេ មានងារជាព្រិន្ទបាលឯក ឈ្មោះចំណាន ។

អ្នកស្រុកតាមដងស្ទឹងសង្កែ ចាប់តាំងពីភូមិវត្តកែវ ព្រែកខ្ពបព្រែកហ្លួង ព្រែកអំបិល រហូតដល់បាក់អម្រែក តែងស្គាល់ព្រិន្ទបាលឯកចំណាននេះច្បាស់ គឺជានាយទាហានមួយរូប ដែលគណៈបញ្ជាការ

ទ័ពខេត្ត បានចាត់ឱ្យនាំទ័ពមកបោះប្រចាំការនៅវត្តក្លាំងងារ សំរាប់ចេញប្រតិបត្តិការបោសសំអាត ពួកឧទ្ទាមចោរព្រៃនានា ដែលធ្វើទុក្ខបុកម្នេញប្រជាជននៅតាមដងស្ទឹងនេះ ដូចជាក្រុមចោររបស់មេភេរវជនត្រឡៃជាដើម ។

ព្រឹទ្ធបាលឯកចំណាននេះ អាយុ ៣៥ ឆ្នាំ នៅកម្លោះទេ ហើយតាំងពីមកឈរជើងនៅក្នុងភូមិសាស្ត្រ តាមដងស្ទឹងសង្កែប៉ែកខាងក្រោមនេះ ចាតុភាពលួចឆក់ប្លន់នានាមិនសូវមានឡើយ ព្រោះនាយទាហានរូបនេះ ប្រើច្បាប់វិន័យតឹងរឹង មិនចេះយោគយល់ចំពោះជនល្មើសណាម្នាក់ទេ ។ តាំងពីក្មេងរហូតទៅដល់មនុស្សធំ តែងកោតញញើតចំណាននេះណាស់ ពេលណាឃើញចំណានចេញប្រតិបត្តិការម្តងៗ ទោះគ្នាច្រើនឬម្នាក់ឯងក្តី តែងមិនហ៊ាននៅរឹងទទឹងពាំងមុខទ័ពឡើយ ព្រោះជាញឹកញាប់ណាស់ ដែលគេតែងឃើញព្រឹទ្ធបាលឯករូបនេះ ចាប់បានពួកលេងល្បែងភ្នាល់ ដូចជាជល់មាន់ លេងអាប៉ោង បៀរប៉ៅជាដើម ទៅឈរតំរៀបគ្នានៅមាត់ច្រាំង ហើយធាក់ពីក្រោយទម្លាក់ទឹក ពេលដែលទឹកកំពុងជន់ហូរខ្លាំង ។ មិនតែប៉ុណ្ណោះ ពួកណាដែលមិនរាង តែងចាប់កោរក្បាលលាបថ្នាំក្រហមទៀតផង ។

ចំណែកពួកចោរព្រៃ ឬពួកប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ កម្របានទៅដល់តុលាការណាស់ បើសិនជាជនទាំងនោះហ៊ានតដៃនៅក្នុងពេលចេញបង្ក្រាប ។

នៅសម័យអសន្តិសុខ នាយទាហានម្នាក់ៗមានអំណាចខ្លាំងក្លា

ហើយទង្វើតឹងរឹងដូចជាព្រិន្ទបាលឯកចំណាននេះ ថ្វីបើមនុស្សខូចខ្លះមិនសប្បាយចិត្ត តែធ្វើឱ្យអ្នកឯទៀតកោតស្ញប់ស្ញែងមិនតិចដែរ ព្រោះអាចនាំឱ្យភូមិថានបានរាបទាប អ្នកស្រុករកស៊ីបានស្រួល ។

ទោះបីយ៉ាងនេះក្តី ក៏គេសំគាល់ឃើញថា តាំងពីព្រិន្ទបាលឯកចំណានមកតាំងបន្ទាយបោសសំអាតអធិករណ៍ នៅក្នុងភូមិសាស្ត្រនេះ មិនទាន់ធ្វើឱ្យក្រុមរបស់មេចោរត្រឡែបចុះញ៉មម្តងណាឡើយ ។ វានៅតែព្រហើន ប្រើឱ្យកូនចៅមកកាប់សំលាប់ប្រជាជន និងឆក់ប្លន់ទ្រព្យសម្បត្តិជាហូហែមិនដែលដាច់ ហើយចំណានតែងមានបំណងជាប់ជានិច្ចរាល់ថ្ងៃ ដើម្បីចាប់អាមេចោរនេះទៅប្រគល់ឱ្យរាជការថ្នាក់លើ ព្រោះវាជាមុខសញ្ញាសំខាន់ជាងគេទាំងអស់ ។

ហើយបើតាមដំរុយពាក្យរបស់មេបញ្ជាការទ័ពខេត្តថា បើព្រិន្ទបាលឯកចំណានចាប់បានអាមេចោរនេះ ថ្នាក់លើប្រាកដជាដំឡើងឋានន្តរស័ក្តិឱ្យគេ ដល់អនុសេនីយត្រីឬអនុសេនីយទោជាមិនខាន ។

ប៉ុន្តែសំរាប់ចំណានវិញ មិនមែនព្រោះតែរឿងឡើងស័ក្តិនោះទេ ដែលធ្វើឱ្យគេគួចចិត្តចង់ចាប់អាមេចោរត្រឡែនោះ គឺវាបណ្តាលមកពីគេមានគំនុំដ៏ក្តៅគគុកមួយទៀត ព្រោះអាត្រឡែវាប៉ុនប៉ងចាប់យកនាងរំដួល កូនក្រមុំមេឃុំវ៉ាត ដែលចាត់ទុកដូចវាជាគូប្រជែងស្នេហារបស់គេដែរ ។

ដោយពិតនោះ ក្នុងរយៈកាលពិតមួយឆ្នាំ ដែលគេមកកាន់ការបោសសំអាតខ្លាំង នៅតាមដងស្ទឹងនេះ គេបានជំពាក់ចិត្តនឹងនាងរំដួលជាខ្លាំង ព្រោះនាងមិនត្រឹមតែស្អាតលើសស្រីក្រមុំឯទៀតនៅក្នុង

ឃុំព្រែកហ្លួងប៉ុណ្ណោះទេ ថែមទាំងនាងមានចរិយាសម្បត្តិល្អប្រពៃ សុភាពរាបសារទន់ភ្លន់ ស្គាល់ចាស់ស្គាល់ទុំ ចេះចាំក្បួនខ្នាតធម៌អារ្យ វិជ្ជាមេផ្ទះ និងច្បាប់ស្រី ស្ទើរឥតខ្ចោះចន្លោះត្រង់ណាឡើយ ។

ក្នុងវ័យ ១៩ ឆ្នាំគត់ រំផ្ទួលគឺជាផ្កាពេញដោយគន្ធពិដោរ ដែលមេឃុំរ៉ាតនិងភរិយាបានអប់រំបន្ទំនាងតាមបែបបូរាណ ច្រើនជាងស៊ីវិល័យ គឺទោះបីជានៅសម័យនោះ មានយុវនារីឯទៀត ស្លៀកសំពត់សំឡុយ កំព្រោងឬហ៊ីបក៏ដោយ ក៏មិនងនួននៅតែឱ្យកូនស្លៀកហូលជាម្លូង ឬក្បិនជាប់ជានិច្ច ឯសក់ក៏កាត់ខ្ចីរបៀបផ្កាថ្កូវ បង្ហាញនូវជើងសក់និងកញ្ចឹងកល្អផូរផង់ និងទងត្រចៀក ដែលរំយោលដោយទំហឹបឬអាយ៉ាដក់ពីស្រស់ពណ្ណរាយ ។

នៅពេលណាដែលនាងស្លៀកក្បិនចេញទៅណាម្ដងៗ ប្រុសៗមិនរាប់ថានៅកម្លោះ ឬមានប្រពន្ធហើយនោះទេ តែងតែឆ្គួតវង្វេងក្នុងការតាមសំលឹងគយគន់មើលរាងកាយនាង ដែលស្រឡៅស្រឡូនដូចរូប ដើមទ្រូងហុចក្បំណែន ត្រគាកអែនហាប់ កំភួនជើងដូចត្រយោងចេក ដែលអ្វីៗសុទ្ធជាគ្រឿងលំអនៃក្ដីស្រមៃរបស់បុរស ។

មានចៅកែឡុង ចៅកែកាឡូត និងចៅកែត្រើទន្លេសាប ស្ទើរតែចង់ចូលស្ដីដណ្ដឹងនាងមិនតិចនាក់ទេ ប៉ុន្តែពួកគេប្រែជាដកថយវិញអស់ នៅពេលដែលឮថា មេឧទ្ទាមត្រឡៃប៊ុនប៊ងចង់បាននាងដែរ រួមទាំងឃើញព្រិន្ទបាលឯកចំណាន ពិះសេះកាត់មុខផ្ទះនាងជាញឹកញាប់ផងនោះ គ្រប់ៗគ្នាក៏រួញ មិនហ៊ានចេញមុខប្រកួតប្រជែងឡើយ ទោះជាមានទ្រព្យសម្បត្តិប៉ុណ្ណាក៏ដោយ ។

ទោះបីយ៉ាងនេះក្តី ក៏ចំណានបានត្រឹមតែបង្ហាញមនោសញ្ចេតនាថាគេស្រឡាញ់រំជួលប៉ុណ្ណោះ ប៉ុន្តែមិនឮថាប៉ុនប៉ងចូលស្តីដណ្តឹងនាងឬយ៉ាងណានោះដែរ ? ព្រោះតាំងពីគេមកបើកប្រតិបត្តិការនៅតាមដងស្ទឹងនេះ គេមិនដែលបង្ហើបប្រាប់អ្នកណាឱ្យដឹងថា គេមានឪពុកម្តាយបងប្អូន ឬស្រុកកំណើតកើតជានៅឯណាដែរនោះឡើយ ។

ដោយឃើញមេឃុំរ៉ាតមានរបួសធ្ងន់ធ្ងរពេក ពេលនោះព្រិន្ទបាលឯកបំណាន ក៏និយាយឡើងដោយញាប់រន្ទាន់ថា ÷

-«...ខ្ញុំបានដំណឹងសម្ងាត់ថា អាត្រឡៃវ៉ានឹងមកអុកឡុកលោកអ៊ំមេឃុំ ទើបខ្ញុំបាននាំគ្នាមកជួយ តែស្តាយណាស់ លោកអ៊ំនៅតែមានរបួស ហើយចាប់មិនបានអាមេក្លោងនោះទៀត !... ឥឡូវត្រូវតែយកលោកអ៊ំទៅមន្ទីរពេទ្យខេត្តភ្លាម !... ទុកយូរមិនបានទេ !...»

មេឃុំ ប្រឹងនិយាយទាំងត្រដាបត្រដួស នៅពេលដែលឈាមចេះតែហូរចេញមកតាមមុខរបួសមិនឈប់សោះ ថា ÷

-«លោកព្រិន្ទបាលឯក ខ្ញុំត្រេកអរណាស់ ដែលលោកបានជួយមកបង្ក្រាបពួកចោរព្រៃ នៅលើទឹកដីភូមិឋានរបស់ខ្ញុំ តាំងពីបានលោកមកជួយសហការ អ្នកស្រុកភូមិឃុំរបស់ខ្ញុំ មានការកក់ក្តៅច្រើនជាងមុនៗ.... តែខ្ញុំសូមផ្តាំថា លោកត្រូវតែកំទេចអាមេចោរត្រឡៃឱ្យបាន.... កុំទុកវ៉ាឱ្យនៅធ្វើបាបអ្នកស្រុកតទៅទៀតឱ្យសោះ !...»

-«លោកអ៊ំ កុំខំនិយាយពេក !...» បំណានពោលកាត់ដោយខ្វាបចិត្ត «...ខ្ញុំប្តេជ្ញាថា បើកំទេចវ៉ាមិនបាន ក៏មិនទាន់ចេញពីទឹកដីនេះដែរ !... លោកអ៊ំ ខំទប់ស្មារតីឡើង ខ្ញុំឱ្យគេយកលោកអ៊ំ....

ទៅពេទ្យ !,,,»

-«ទេ !,, ទេ !,,, មិនបាច់យកទៅទេ !,,,» មេឃុំវ៉ាតងាកមកប្រចាប់ដៃភរិយា និងលើកដៃអង្អែលសក់កូន ពោលដោយដង្ហើមកាន់តែខ្សោយ «,,,នួន !,,, នៅមើលថែរក្សារំដួលកូនយើងឱ្យល្អណាំ !,,, ប្រយ័ត្នកុំឱ្យធ្លាក់ក្នុងកណ្ដាប់ដៃអាមេចោរត្រៃឡៃឱ្យសោះ !,, អ៊ូយ !,,,,»

ដោយមុខរបួសធ្ងន់ពេក មេឃុំវ៉ាតក៏ដាច់ខ្យល់ស្លាប់នៅពេលនោះមិនអាចយកទៅពេទ្យទាន់ឡើយ ធ្វើឱ្យមីងនួនសែនវិយោគសោកស្ដាយ រួមជាមួយកូនស្រីក្នុងរាត្រីដ៏សែនរន្ធត់ខ្លោចផ្សា ទោះប្រើចុងប៉ាក្ការៀបរាប់យ៉ាងណា ក៏ពុំសមស្លួននឹងទម្ងន់ទុក្ខរបស់ម្ដាយនិងកូនក្នុងពេលនោះដែរ ។,,,,,

# ២

## ចម្លើយមិនច្បាស់ !

**នោះ**បីជាកំទេចបាន ក្រុមចោរបីនាក់របស់អាត្រឡៃក៏ដោយ ក៏អ្នកស្រុកហាក់ដូចមិនសូវរីករាយប៉ុន្មានឡើយ ព្រោះទំហំទុក្ខនៃការបាត់បង់មេឃុំវ៉ាតនោះ មានលក្ខណៈធំធេងជាង ហើយដំណឹងនេះគ្រាន់តែព្រឹកឡើងស្ទើរមិនទាន់ ក៏បានឮខ្ចរខ្ចាយពេញភូមិ ឃុំក្នុងស្រុកសង្កែនិងផ្សព្វផ្សាយតៗគ្នា ស្ទើរពេញខេត្តបាត់ដំបងភ្លាម ព្រោះមេឃុំវ៉ាត ពិតមែនតែបុណ្យស័ក្តិមិនជាធំដុំប៉ុន្មាន តែគាត់មានឈ្មោះល្បីនិងប្រជាប្រិយមកយូរឆ្នាំហើយ ក្នុងកិច្ចកសាងការពារភូមិឃុំ ដោយស្មោះត្រង់បំផុត ។

បងប្អូនសាច់ញាតិរបស់មេឃុំវ៉ាត និងមីងទួន រាប់តាំងពីស្ទឹងចាស់ រនាមដូនសំ និងហូរហែតាមដងស្ទឹងរហូតទៅដល់ផ្សារស្រុកសង្កែ បាននាំគ្នាមកចូលរួមធ្វើបុណ្យសពដែលកំណត់ធ្វើរយៈបីថ្ងៃនោះយ៉ាងមហោឡាឬកពន់ប្រមាណ ។

រដ្ឋអំណាចស្រុកនិងខេត្ត ក៏បានបញ្ជូនតំណាងឱ្យនាំកំរងផ្កាមកគោរពសព និងយកអំណោយជាលុយកាក់មកជួយសំរាលទុក្ខក្រុម

គ្រួសារសពទៀតផង ។ ជាមួយនោះ គេក៏ឃើញព្រិន្ទពាលឯកចំណាន បានបរិច្ចាគធនធានផ្ទាល់ខ្លួន យកមកឱ្យផ្ទាល់ដៃនាងរំដួល នៅពេលព្រឹកនៃថ្ងៃចាប់ផ្ដើមបុណ្យ ដោយពោលបញ្ជាក់ថា ៖

-«អ្នកនាងរំដួល យប់មិញនេះ បើខ្ញុំមកទាន់ហេតុការណ៍តាំងពីដំបូងទី ប្រាកដជាលោកអ៊ំមិនស្លាប់ទេ !... ខ្ញុំសោកស្ដាយខ្លាំងណាស់ ! ខ្ញុំសូមនាំយកលុយកាក់មកចូលរួមរំលែកទុក្ខក្នុងមរណភាពរបស់លោកអ៊ំផង និងតាំងចិត្តប្ដេជ្ញាតាមបណ្ដាំរបស់លោកអ៊ំ និងកំទេចអាត្រឡៃឱ្យបានក្នុងពេលឆាប់ៗ និងការពារជាដាច់ខាត មិនឱ្យវាធ្វើអ្វីដល់អ្នកនាងបានឡើយ !...»

នាងរំដួល ទទួលលុយកាក់ពីដៃព្រិន្ទពាលឯកជំនួសម្ដាយដែលជាប់រវល់រៀបចំចង្ហាន់លោក ហើយបង្ហើរសំនៀងតបវិញដោយញញឹមស្ងួតថា ៖

-«សូមអរគុណលោកជាទីបំផុត ដែលជួយឈឺឆ្អាលចំពោះគ្រួសារខ្ញុំយ៉ាងនេះ !... ពេលនោះ បើកុំតែបានលោកមកជួយទាន់ ម្ល៉េះសមខ្ញុំពិតជាគេចមិនរួចពីកណ្ដាប់ដៃវាទេ !...»

ចំណាន គិតថានឹងនិយាយតែមួយឃ្លា រួចថយចេញទៅវិញ តែជួនជាឮស្រីក្រមុំ ឆ្លើយតបដ៏សែនពិរោះយ៉ាងនោះ គេក៏ឆ្លៀតបន្ថែមមួយឃ្លាទៀត ដោយភ្លេចគិតថា នៅជ្រុងសសរផ្ទះមួយនោះ យស់ដៃកាន់ថាស ឈរសម្លឹងមើលមក ដោយអារម្មណ៍ប្លែកនោះឡើយ ៖

-«សូមអ្នកនាងកុំព្រួយឱ្យសោះ ដរាបណាមានព្រិន្ទពាលឯក

ចំណាន អាត្រឡែត្រូវតែចាត់ឈ្មោះពីផែនដីនេះ !...»

ចំណាន ពោលដោយបង្អើរខ្សែភ្នែកពេញដោយមន្តស្នេហ៍ទៅរក យុវនារី តែរំដួល ប្រែជាអោនមុខមិនទទួលយកខ្សែភ្នែកដ៏ចំឡែកនេះ ឡើយ ព្រោះនាងទើបដឹងច្បាស់ថា នៅជ្រុងម្ខាងនោះ ប្រហែលជា យស់សម្លឹងមកដោយអន់ចិត្ត ព្រោះឃើញនាងស្វាគមន៍ចំណាន ដែលពីឆ្ងាយមកហើយ នាងមិនដែលបង្ហាញទិដ្ឋភាពបែបនេះឡើយ ។

ទោះបីជាពេលនោះ យស់ខំប្រឹងចាត់ចែងជួយធ្វើបុណ្យសព មេឃុំវ៉ាត ដោយគ្មានខ្វាចនឿយហត់ ដើម្បីយកចិត្តនាងរំដួល ឱ្យ នាងនឹកអាណិតគេថា គេស្រឡាញ់នាងយ៉ាងណាក៏ដោយ ក៏ពេលនោះ គេបែរជាគិតដោយអស់សង្ឃឹមវិញថា ៖

-«ឱ ! ខ្លួនអញអើយ មើលទៅបែបមិនឈ្នះគេទេ ! បើមិន មែនអាត្រឡែ គឺច្បាស់ជាព្រិន្ទបាលឯកនេះហើយ ដែលនាងព្រមរៀប ការជាមួយ នៅពេលណាដែលគេចូលស្តីដណ្តឹងនាង ព្រោះគេមាន បុណ្យស័ក្តិធំជាង ហើយរូបរាងក៏សង្ហារទៀត ?...»

....**ក្រោយ**ពីពិធីឈាបនកិច្ចសពមេឃុំវ៉ាត បងប្អូនទាំងអស់បាន មកជួបជុំពិគ្រោះជាមួយមីងនួន មុននឹងសុំលាត្រឡប់ទៅភូមិស្រុកវិញ រៀងៗខ្លួន ។

ជាដំបូងស្រីម្នាក់នៅខាងស្ទឹងចាស់ បញ្ចេញយោបល់ថា ៖

-«នែ៎ ចុះនួនឯងគិតយ៉ាងណាទៅ បើល្បងវ៉ាតគាត់ស្លាប់ទៅ ហើយយ៉ាងនេះ គិតឱ្យរំដួលទៅនៅឯស្ទឹងចាស់មួយរយៈជាមួយខ្ញុំទៅ ដឹង កុំឱ្យអាត្រឡែវាមកអុកឡុកទៀត ព្រោះកាលណាវាចោលសំដី

បែបហ្នឹងហើយ មិនយូរមិនឆាប់វាមុខជាមករកចាប់រកចងទៀតហើយ តើនួនឯង មានអ្វីការពារកូនទៅ ?...»

មីងនួន ដកដង្ហើមធំ មិនទាន់ទាំងឆ្លើយផង ស្រាប់តែបុរសម្នាក់ចំណាស់ប្រហែលមេឃុំវាត ឆ្លើយកាត់ ÷

-«អ្ហ៎... ឱ្យវិដូលទៅនៅឯស្ទឹងចាស់ជាមួយបងចាន់យ៉ាងម៉េចកើតទៅ បើស្ទឹងចាស់ជិតកន្លែងដែលអាត្រឡៃវាតាំងជម្រុំ នៅពេលវាដឹង មុខជាវាទៅចាប់យកស្រួលដូចបកចេក ! បើថានេះទេ ឱ្យក្មួយវិដូលទៅនៅជាមួយខ្ញុំ ឯរនាមដូនសំសិនទៅ ទម្រាំពេលណាលោកព្រិន្ទពាលឯកចំណាន ចាប់បានអាត្រឡៃ សឹមឱ្យវាត្រឡប់មកវិញ !...»

មានស្រីចំណាស់ម្នាក់ ឆ្លើយកាត់ផ្លូងទៀត ÷

-«ហ៊ី !... ល្បងរឿន ម៉េចនិយាយអីចឹង ឱ្យទៅនៅជាមួយល្បងឯង ដូចជាយកចំណីទៅដាក់ក្នុងមាត់ខ្លាអីចឹង ព្រោះរនាមដូនសំ ជាកន្លែងដែលពួកអាត្រឡៃវាឆ្លងកាត់ចុះឡើង មិនលែងអីនឹងវាដឹងនោះឡើយ មានតែទៅនៅឯបាក់ព្រាជាមួយខ្ញុំទេ ទើបរួចខ្លួនម៉្យាងទៀតនៅឯមាត់ពាមទន្លេសាបនោះ ស្រួលរកស៊ីទៀត ថៅកែផ្នស់ ថៅកែកាណូត និងថៅកែឡូត៍នេសាទក៏សម្បូរណ៍ ម៉េចៗឱ្យវាយកប្តីពួកគេមានៗនៅទីនោះទៅ វាចប់រឿងទៅហើយ !..»

មីងនួន ញាក់បបូរមាត់ឆ្លើយតប ÷

-«...អ៊ើ... ចាំមើល ខ្ញុំពិគ្រោះជាមួយកូនសិនមើល៍ តើវាចង់ទៅនៅឯណាជាង ឬមួយក៏វាស៊ូទ្រាំនៅទីនេះ ?...»

បន្តិចនោះ មានស្រីម្នាក់រាងតូចទ្រទាប់ កាត់សក់ផ្កាថ្កូវដូចជាកញ្ញារំដួលដែរ ហើយអាយុប្រមាណ ៣៨ ឆ្នាំ ឈ្មោះឡឹង ក៏បន្ទឺជាចុងក្រោយគេថា ÷

-«ដឹងធើម៉េចហ្ន៎ បើមីងនួនឯង មានកូនស្រីរូបស្អាតអីចឹងមានគេចោមស្រឡាញ់ច្រើនយ៉ាងនេះ ពិបាកហើយ បើតាមខ្ញុំគិតមើលទៅទៅនៅឯបាក់ព្រាក៏មិនស្រួលដែរ ព្រោះឆ្ងាយពីគេឯង ហើយជាកន្លែងដែលពួកវា តែងចុះទៅរកត្រីជាញឹកញាប់ យ៉ាងណាក៏នៅតែវាដឹងដែរ ! បើតាមគំនិតខ្ញុំថា គួរឱ្យទៅនៅជាមួយខ្ញុំ ឯមុខផ្សារសង្កែតែម្តងទៅ នៅឯណោះ ជាទីប្រជុំជន ជិតរាជការ ប៉ូលីស ទាហាន ប៉េអិម ពួកអាត្រឡៃមុខជាមិនហ៊ានទៅជិតទេ ព្រោះវាខ្លាចគេចាប់វាណាស់ !...»

ស្រាប់តែពេលនោះ អ្នកដែលមានយោបល់មុន ក៏នាំគ្នាផ្តេកផ្តួលគំនិតមកតាមសំដីរបស់នាងឡឹងវិញ ដោយញញឹមញញែមថា ÷

-«អ៊ុំ... មែនហើយ កាឡឹងគេមានទូកធំដូចជាផ្ទះបណ្តែតទឹកនៅក្នុងស្ទឹង ចំមុខផ្សារវិល(១) ស្រាប់ ទីនោះអ៊ូអែរ មានគេមានឯងច្បាស់ជាអាត្រឡៃវាមិនហ៊ានអើតក្បាលទៅមែន គួរឱ្យក្មួយរំដួលទៅនៅជាមួយបងជីដូនមួយវាមួយរយៈទៅ បានសុខហើយ !...»

ម្តងនេះ គេឃើញទឹកមុខមីងនួន ដែលក្រៀមក្រំមកយូរហើយរាងស្រស់ថ្លាឡើងវិញបន្តិច ហើយបន្ទរ ÷

-«លោក់យាំងអី ខ្ញុំនឹកឃើញរឿងនេះយូរហើយ តែមិនហ៊ាន

១-ផ្សារវិល ក្លាយពីភាសាបារាំងថាផ្សារ VILLE គឺផ្សារក្រុង

វ៉ខានកាឡឹង ព្រោះប្ដីគេទើបនឹងស្លាប់ដែរ... ក្រែងគេមិនទាន់ផុតទុក្ខព្រួយ ឯងយកមនុស្សទៅឱ្យអំពល់គេទៀត !...»

នាងឡឹង ឆ្លើយបញ្ជាក់ ÷

-«មីងកុំគិតទើសទាល់អីចឹងអី រឿងឪវាស្លាប់ជារឿងផ្សេង ហើយកន្លងទៅប្អូនប្រាំខែហើយដែរ ឯរឿងមីងមានបញ្ហានេះ ខ្ញុំត្រូវតែជួយដោះស្រាយ ខ្ញុំមិនចង់ឃើញប្អូនវ៉ដ្ឋល ក្លាយជាប្រពន្ធចាប់បង្ខំរបស់អាមេចោរនោះទេ !...»

ಌಚ ಌಚ ಌಚ

...**វេលា**ល្ងាចព្រលប់ វ៉ដ្ឋលបានឆ្លៀតពេលចុះទៅមុជទឹកនៅមាត់កំពង់ ដែលពេលនោះ នាងបានជួបនឹងយុវជនទាហានឃុំយស់ទៅពួនចាំនៅក្បែរគុម្ពត្រែងមួយ ។

ជាបន្ទាន់ យស់ បានស្ទុះមក ហើយសួរដោយចោលភ្នែករំពៃឆ្វេងស្ដាំ ខ្លាចមានគេឃើញ ថា ÷

-«ខ្ញុំឮល្ងៀងៗថា វ៉ដ្ឋលប្រុងទៅនៅផ្សារសង្កែមែនទេ ?...»

វ៉ដ្ឋលងក់ក្បាល ហើយវាចាតិចៗ ដោយខ្លួនប្រាណផណ្ដប់ក្រមាគ្របពីលើស្មា និងដៃម្ខាងទៀត កាន់ផ្ដិលសាប៊ូក្រអូប ÷

-«មែនហើយ ស្អែកនេះ ម៉ែគាត់ឱ្យខ្ញុំទៅនៅជាមួយបងជីដូនមួយខ្ញុំ នៅផ្សារសង្កែហើយ ! មកពីគាត់ខ្លាចពួកអាត្រឡែមកចាប់ខ្ញុំ ព្រោះគ្មានអ្នកណាអាចការពារខ្ញុំ បានទាំងថ្ងៃទាំងយប់ គ្រប់ម៉ោងគ្រប់ពេលនោះទេ !...»

-«ចុះខ្ញុំ រំដួលមិនទុកចិត្តទេឬ ?...» យស់ ឆ្លើយតបដោយ អង់អាច «... កុំភ្លេចថា យប់កើតរឿងនោះ ខ្ញុំបាញ់ត្រូវពួកវាម្នាក់ដែរណា៎ !... ខ្ញុំពិតជាអាចការពាររំដួលបាន !...»

-«បងយស់ពិតជាអង់អាចក្លាហានមែន !...» រំដួលតប ដោយញញឹមស្ងួត «...ប៉ុន្តែបើវាលើកគ្នាមកច្រើននាក់ ឯយើងមានតែប៉ុន្មាននាក់ មិនអាចទប់ទល់បានទេ !...»

-«ចុះលោកព្រិទ្ធបាលឯកចំណាន គេសន្យាថាអាចការពាររំដួលបានហើយនោះ រំដួលទៅព្រួយអីទៀត ?...»

ឮប្រយោគនេះរបស់ប្រុសកម្លោះ រំដួលបើកភ្នែកសម្លក់ ÷

-«...គាត់ថាអីចឹងមែន តែគាត់ជាអ្នករាជការ មានពេលឯណាមកការពារយើងគ្រប់ជង្គើមចេញចូលនោះ ខ្ញុំគ្មានទុកចិត្តទេ គឺគាត់ថាយកតែគួរប៉ុណ្ណោះ ! ម្យ៉ាង គាត់មិនមែនជាសាច់ញាតិអីជាមួយយើង គាត់មិនមែនមកប្ដូរស្លាប់រស់ជាមួយយើងនោះទេ !..»

-«តែពេលដែលគាត់យកលុយមកចូលបុណ្យសព លោកអ៊ំមេឃុំ ខ្ញុំឃើញទឹកមុខគាត់ម៉ិតប្រាយណាស់ គឺច្បាស់ជាគាត់ស្រឡាញ់រំដួលហើយ គាត់ពិតជាប្ដូរស្លាប់រស់ចំពោះរំដួលណា៎ !...»

ឆោមទេវី បើកភ្នែកសម្លក់ប្រុសកម្លោះជាលើកទីពីរ ÷

-«អ្នកណាប្រាប់ថា គាត់ស្រឡាញ់ខ្ញុំ ?...»

ម្ដងនេះ យស់ និយាយដូចជាមែនបន្ទិលេង ÷

-«...ខ្ញុំដឹង ! ព្រោះខ្ញុំតាមដានគាត់យូរហើយ គឺថ្ងៃណាក៏គាត់តែងមកជិះសេះក្រវែលកាត់មុខផ្ទះរំដួលដែរ ហើយឧស្សាហ៍ដើមភ្នែក

កន្ទុយភ្នែកសម្លេកសម្លក់ ព្រោះគាត់ជាកម្លោះចាស់ មិនទាន់មានប្រពន្ធទេណា៎ !...»

-«តែពីរបីថ្ងៃ ក្រោយពីបុណ្យខ្មោចពុករួច មិនឃើញគាត់មកក្រវែលផ្ទះខ្ញុំទៀតទេ !...»

-«ហ្នឹង ប្រហែលជាគាត់មានការរវល់ ឬមួយក៏ទៅរៀបចំឱ្យឪពុកម្ដាយមកចូលស្ដីដណ្ដឹងរំដួលក៏មិនដឹង ?...»

-«យី...ចុះបងយស់ឯង ដឹងអីក៏ដឹងម្ល៉េះហ្ន៎ ?.... តែបើគាត់លួចស្រឡាញ់ខ្ញុំមែន ក៏ស្រឡាញ់តែគាត់ទៅ ចំណែកខ្ញុំគ្មានដែលបានគិតអីពីរឿងហ្នឹងទេ !...»

ម្ដងនេះ យស់ប្រែទឹកមុខ ដោយញញឹមស្ងួត ៖

-«...អីចឹង រំដួលគ្មានចិត្តស្រឡាញ់គាត់ទេអ្ហ៎ ?...»

រំដួលព្រែកហ្លួងមិនឆ្លើយ ហើយបែរមុខទៅសម្លឹងរលកទឹកដែលកំពុងបែករស្មីព្រាកៗ ក្រោមពន្លឺព្រះទិនកររហៀបអស្ដង្គត ។ ឃើញនាងនៅស្ងៀមដូច្នោះ យស់ក៏ឆ្លៀតសួរបន្ថែមទៀត ៖

-«ចុះខ្ញុំ រំដួលយល់យ៉ាងណាដែរ តាំងពីយូរណាស់មកហើយខ្ញុំមិនដែលឮរំដួល ឆ្លើយមកខ្ញុំវិញថាដូចម្ដេចសោះ.... តែខ្ញុំស្រឡាញ់រំដួលណាស់ណា៎ !... ពេលរំដួលទៅនៅឆ្ងាយពីខ្ញុំនេះ ខ្ញុំនឹករំដួលស្លាប់ហើយ រំដួលប្រហែលជាគ្មាននឹកដល់ខ្ញុំទេ ?...»

ពោមទេវី លើកខ្សែភ្នែកពីរលកទឹកក្នុងស្ទឹង សម្លឹងមើលទៅជើងមេឃ ដែលនៅសល់ពន្លឺក្រហមព្រឿងៗយ៉ាងខ្សោយបំផុតវិញ ហើយវាចាតិចៗ ដោយមិនងាកមុខ ៖

-«ធ្លាប់ស្គាល់ និយាយលេងជាមួយគ្នា ដូចជាបងយស់ឯងនេះ អ្នកណាមិនទឹកនោះ !... តែណ្ហើយ កាត់បិត្តខ្លះទៅ.... ផ្កាសង្កែ នៅមិនឆ្ងាយប៉ុន្មានទេ ជិះកង់ឬជិះទូកទៅដល់ទេតើ !... បើទឹកខ្លាំង ទៅលេងនឹងខ្ញុំទៅ !...»

ដោយមិនអាចមានពេលវេលាតទៅទៀត យស់ឆ្លៀតសួរមួយឃ្លា ជាចុងក្រោយថា ÷

-«ឆ្លើយប្រាប់មួយម៉ាត់សិនម៉ោ ! ខ្ញុំចង់ដឹងណាស់ ព្រោះយូរ មកហើយ ខ្ញុំរង់ចាំតែពាក្យហ្នឹង តើស្រឡាញ់ខ្ញុំទេ ? តើព្រមរៀបការ ជាមួយខ្ញុំទេ...?...»

ដោមស្រស់រំដួល កាលបើឮប្រុសកម្លោះ ដេញសួរចំៗដូច្នោះ នាងទឹកព្រឺព្រួច ខ្មាស់អៀនពន់ប្រមាណ ហើយនៅស្ងៀមយ៉ាងយូរ ហាក់ដូចកំពុងប្រើខួរក្បាលដោះស្រាយបញ្ហាអ្វីមួយនៅក្នុងបេះដូង ជា ហេតុធ្វើឱ្យយស់ទ្រាំមិនបាន ក៏ដេញសួររន្ថើនទៀត ÷

-«ឆ្លើយមក តើព្រមរៀបការជាមួយខ្ញុំទេ ខ្ញុំនឹងឱ្យម៉ែលក់ក្របី យកមកដណ្ដឹងរំដួលណា៎ !...»

ស្រាប់តែ ទឹកឃើញអ្វីមិនដឹង រំដួលបែរមុខយឺតៗមកឆ្លើយ ដោយអួលអាក់ថា ÷

-«បងយស់ !... ខ្ញុំអាណិតបងណាស់ !... ខំមើលខ្លួនឱ្យជា ជម្ងឺគ្រុនចាញ់សិនទៅ ! កុំលក់ក្របីអី !...»

យស់ ខំបន្ទរពាក្យដោយកន្ទុះរា ÷

-«អាណិត !... ខ្ញុំមិនចង់ឱ្យរំដួលអាណិតទេ គឺឱ្យស្រឡាញ់

ដូចជាខ្ញុំស្រឡាញ់រំដួលអីចឹងណាំ !..»

ជំនោរវេងស្ទឹង បក់ផាត់មួយមេមកសែនត្រជាក់ ហាក់ដូចជួយតៀងបង្ខំស្រីក្រមុំ ឱ្យត្រូវតែឆ្លើយប្រាប់ទៅប្រុសកម្លោះវិញ ។ ប៉ុន្តែជួនជានៅពេលដែលនាង រៀបនឹងរលាស់បបូរមាត់ឆ្លើយវាចា ស្រាប់តែមានកូនក្រមុំអ្នកភូមិឯទៀតជាច្រើន រត់ព្រួចុះមកមុជទឹកដែរ ធ្វើឱ្យស្រស់កញ្ញាអាក់ខានទៅវិញ ឯកម្លោះយស់ក៏ប្រញាប់គេចខ្លួនចូលទៅក្នុងគុម្ពត្រែងប្រេក រហ័សដូចទន្សាយ ។...

...**ស្អែក**ឡើង នៅប្រមាណជាម៉ោង ៩ កន្លះព្រឹក កញ្ញារំដួលក៏រៀបចំខ្លួន ធ្វើដំណើរជាមួយនាងឡឹង ដែលជាបងជីដូនមួយ ដើម្បីទៅរស់នៅឯផ្សារស្រុកសង្កែវិញ ។

មីងនួន បានជូនដំណើរកូនមកលើមាត់កំពង់ ដែលមានទូកដរនៅចាំ រួមជាមួយញាតិមិត្តប្រុសស្រីជាច្រើនទៀត ដែលមានខ្លះជួយកាន់វ៉ាលិសដាក់សំពត់អាវ និងកន្ទេលខ្នើយភួយមុងជាដើម ។

នៅពេលនោះ មីងនួនខំភ្នែកក្រឡេកមើលឆ្វេងស្តាំ ហើយងាកសួរទៅកូនស្រី ÷

-«នែ៎ រំដួល ម៉េចដូចជាមិនឃើញក្មួយយស់ តើវាទៅណាអេះ !.... មិនឃើញមកជួយជញ្ជូនអីវ៉ាន់ ជូនដំណើរឯង ?...»

រំដួល ធ្វើជាសំលឹងមើលនាយអាយដែរ ទើបបន្លឺដោយទឹកមុខស្មើ ÷

-«ប្រហែលជាគាត់គ្រុនហើយទៀតហើង ព្រោះប៉ុន្មានថ្ងៃនេះ ខ្ញុំឃើញគាត់ហត់នឿយណាស់.... ពេលជួយធ្វើបុណ្យខ្មោចពុក !..»

-« អឺុ បានវាហ្នឹងហើយ.... កុំអីក៏ម៉ែពិបាកដែរ តែពីព្រឹកមិញម៉ែឃើញវាឡើងដូង បេះបានមួយធ្លាយយកមកទុកឱ្យឯងផឹកតាមផ្លូវ តែឥឡូវស្រាប់តែគេចបាត់ !... ប្រហែលវាមិនស្រួល....ទៀតហើយដឹង ?...»

-« ម៉ែ !... ជួយរក...ថ្នាំ ឱ្យគាត់ផងទៅ !...»

-« អើ... មិនអីទេ !! ទៅនៅជាមួយបងឯងឱ្យបានសុខណាំកូន... ម៉ែប្រហែលប្អូនដប់ថ្ងៃទៀត ទៅលេងដែរ !...»

...ពេលនោះ ទោះបីគេមិនឃើញយស់មកជូនដំណើររំដួលក៏ដោយ ប៉ុន្តែនៅពេលទូកចេញដំណើរទៅ ឆោមកញ្ញាបានចោលភ្នែកទៅឃើញយស់ ឈរស្រងូតនៅក្រោមដើមអំពិលមាត់ច្រាំងឆ្ងាយពីគេ សម្លឹងមក...

❀

❀ ❀

# ៣

# អ្នកជួយរើសត្រី

**មាត់**ស្ទឹងសង្កែ ក្រុងបាត់ដំបងនាសម័យនោះ មានភោជនីយដ្ឋានមួយ ជាប់នឹងកំពង់ចម្លង ឆ្លងទៅវត្តពោធិវាលពីតកាបីនភ្លើង ដែលមានឈ្មោះដើមថា "អូ លីឡាប្លង់"(១) ។ ភោជនីយដ្ឋាននេះកើតមានតាំងតែពីមុនឆ្នាំ ១៩៥០ ថៅកែបារាំងជាអ្នកបង្កើត គឺសំរាប់ភៀវមន្ត្រីបារាំង-យួននៅក្នុងខេត្ត ឯអតិថិជនខ្មែរមិនសូវជាមានប៉ុន្មានទេ ។

(ក្រោយដែលអាណានិគមបារាំងចេញទៅ មិនយូរប៉ុន្មានភោជនីយដ្ឋាននេះ ក៏បង្កើតជាថ្មី ឈ្មោះថា បារសង្កែ(២) ហើយក្នុងជំនាន់ក្រោយៗមក ក៏ដូរមកជាបារស្ទឹងទៀវិញ) ។

នៅក្នុងស្ទឹង ចាប់ត្រឹមពីភោជនីយដ្ឋាននេះរហូតទៅដល់ខាងលើព្រែកមហាទេពបន្តិច មានសុទ្ធតែទូកតូចធំរបស់ប្រជាជនរស់នៅត្រៀបត្រា ប្រៀបដូចជាភូមិបណ្តែតទឹកមួយនៅឯមាត់ពាមទន្លេសាបព្រែកទាល់យ៉ាងនោះដែរ ។

ហើយនៅពេលរដូវទឹកសំរក គេតែងតែធ្វើស្ពានឈើប្រើនកន្លែង

១- Au Lilas blanc (ចូល ផ្កាម្លិះស) ។ ២- Bar Sangker

សំរាប់ឱ្យមនុស្សម្នា ដើរឆ្លងពីត្រើយម្ខាងមកម្ខាង តែបើដល់រដូវទឹកជំនន់ ដែលមិនអាចធ្វើស្ពានបាន គេក៏ប្រើទូកសំរាប់ចែវចម្លងមនុស្សចុះឡើងវិញ ដោយបង់ថ្លៃឈ្នួលទៅតាមកំណត់កម្លាំងពលកម្មរបស់អ្នកចែវ ។

ទូករបស់នាងឡឹង ចតនៅចំពីមុខរោងកុនអេដែន (បច្ចុប្បន្ននេះគ្មានទេ) ងាយចុះឡើងទៅកាន់ទីផ្សារ និងងាយប្រកបរបររកស៊ីទៀតផង ។ ក្រោយដែលប្ដីស្លាប់ទៅ ដើម្បីចិញ្ចឹមកូនប្រុសតូចៗពីរ នាងឡឹងបានរកស៊ីជាអ្នកលក់ផ្លែឈើគ្រប់មុខ គឺចាំទទួលទិញបន្លែ ផ្លែឈើដែលគេពីកតាមទូកយកមកពីចំការក្រោមតាមដងស្ទឹង ដូចជាត្រឡាចត្រសក់ ឪឡឹក និងផ្លែឈើផ្សេងៗទៀត ហើយយកទៅដាក់លក់នៅទីផ្សារជាប្រចាំ ដូចជាអ្នកលក់ដទៃទៀតដែរ ។

វណ្ណល បានទៅរស់នៅជាមួយបងជីដូនមួយ ដោយសុខដុមរមនាគ្មានបញ្ហាអ្វីស្មុគ្រស្មាញឡើយ ។ ប៉ុន្តែនាងឡឹង មិនដែលឱ្យកញ្ញាវណ្ណលចេញដើរទៅណារហេតរហូតទេ គឺឱ្យនៅតែក្នុងទូក គ្រាន់ដាំបាយដាំទឹក និងមើលការខុសត្រូវ ពេលដែលនាងជាប់រវល់ទៅលក់ដូរមួយពេលៗប៉ុណ្ណោះ ។

មកនៅបានប្រហែលជាកន្លះខែ ទឹកក៏ចាប់ផ្ដើមស្រកចុះស្រើតៗស្ទើរដល់បាតស្ទឹង ។ មានកន្លែងខ្លះមើលឃើញខ្សាច់ ជាហេតុធ្វើឱ្យអ្នកដែលមានផ្ទះនៅជិតៗមាត់ស្ទឹង ឧស្សាហ៍នាំគ្នាចុះមកមុជទឹក មកបោកគក់ខោអាវ ឯក្មេងៗតែងនាំគ្នាយកមុង ឬក្រមារអើរគៀរត្រីនៅក្បែរៗទូក កំសាន្តសប្បាយលេងទៀតផង ។

នៅត្រង់មាត់កំពង់ ក្បែរទូកនាងឡឹង រៀងរាល់ល្ងាចគេសង្កេតឃើញចាប់ពីម៉ោង ៥ទៅ តែងតែមានមនុស្សប្រុសស្រីចុះមកមុជទឹកមិនសូវស្ងាត់ទេ ប៉ុន្តែជនទាំងនោះ មិនដែលដឹងថា នៅលើទូកដែលមានដំបូលគ្របដូចផ្ទះនោះ មានកុលាបមួយទងកំពុងពួនរីកបើកស្រទាប់ ដ៏ស្រស់បំព្រងនោះឡើយ ។

ក្នុងចំណោមអ្នកមុជទឹកទាំងនោះ មានយុវបុរសម្នាក់អាយុប្រមាណ ៣០ឆ្នាំ មុខស្រស់ រាងសង្ហារដូចអ្នកកីឡា សម្បុរជ្រះស្លាគបាត ទំនងជាកូនអ្នកមានសម្បត្តិទ្រព្យពូជអំបូរខ្ពស់ ។ ឱ្យតែពេលណាចុះមកមុជទឹកម្តងៗ យុវជននេះតែងតែបណ្តែតខ្លួន ហែបហែលឆ្វែលចុះឆ្វែលឡើង ក្បែរៗទូកនាងឡឹង ទាល់តែអស់ចិត្តអស់ចង់ ទើបឡើងទៅលើវិញ ។

ដោយពិតនោះ សុផលមិនដែលបានឃើញមុខមាត់រំដួលម្តងណាឡើយ ព្រោះនាងសម្ងំពួននៅតែក្នុងទូក ជួនក៏មើលសៀវភៅ ជួនក៏ដេរប៉ាក់ ជួនកាលក៏បោសច្រាស់ ជូតក្តារឬជូតសំអាតរបស់ប្រព្យប្រើប្រាស់ផ្សេងៗ ។

តែផ្ទុយទៅវិញ រំដួលតែងតែមើលឃើញពួកអ្នកចុះមកមុជទឹកទាំងនោះច្បាស់ ព្រោះនាងលបមើលតាមចំរៀកប្រហោងជញ្ជាំងក្តារទូក ហើយចំណាំទាំងមុខយុវជនសុផល ដែលនាងបានលួចកត់សំគាល់ក្នុងចិត្តថា ជាបុរសមានសម្រស់ប្លែក និងមានស្នេហ៍មុខគួរឱ្យចូលចិត្តទៀតផង ។

តាំងពីយូរមកហើយ នាងមិនធ្លាប់ឃើញបុរសដែលមានសម្ផស្ស

ឆក់ទាញមនោសញ្ចេតនាបែបនេះទេ ទោះជាមេចោរត្រឡែ នាយយស់ ឬព្រិន្ទបាលឯកចំណាន ដែលតាមស្រឡាញ់នាងនោះ ក៏ស៊ូនឹងបុរសនេះមិនបានដែរ ។

ទោះយ៉ាងនេះក្តី ក៏រំដួលគ្រាន់តែកត់សំគាល់ក្នុងចិត្តប៉ុណ្ណោះ តែនាងមិនដែលអើតបង្ហាញមុខឱ្យយុវជននោះឃើញម្តងណាឡើយ ។ នេះគឺមកពីនាងមិនដែលស្គាល់ ហើយក៏គ្មានការសំខាន់អ្វី ដែលនាងត្រូវបង្ហាញមុខឱ្យជននោះឃើញដែរ ព្រោះពេលនេះនាងកំពុងតែលាក់ខ្លួន ក្រែងលោគេឃើញទៅ នាំបែកសាយាមោលេចឮចេញទៅឆ្ងាយ។

ប៉ុន្តែ ព្រហ្មលិខិតឬដំណើរជីវិតរបស់មនុស្ស មិនអាចអ្នកណាម្នាក់ទស្សន៍ទាយត្រូវជាមុនបានឡើយ សូម្បីតែមួយវិនាទីដែលមិនទាន់មកដល់ ក៏មិនដឹងថាត្រូវមានអ្វីកើតឡើងដែរ ? ។

...**ជួន**អីនៅថ្ងៃនេះ ប្រហែលជាម៉ោង៥ល្ងាច រំដួលបានលួចមើល ឃើញយុវជនមានស្នេហ៍មុខនោះ ចុះមកមុជទឹកទៀត តែពុំមានអ្នកផ្សេងចុះមកមុជជាមួយដូចសព្វមួយដងឡើយ ។

ហើយពេលនោះ នាងឡីងរវល់តែទៅស្ទាក់ទូកឱ្យឹកនៅឯព្រែកមហាទេពជាមួយកូននាងម្នាក់ ឯរំដួលក៏រៀបចំដាំបាយស្ងួរស្លកដូចសព្វមួយដង ជាមួយក្មួយប្រុសនាងម្នាក់ទៀត ដែលមានអាយុប្រមាណ ១២ឆ្នាំ កំពុងអង្គុយលេងត្រីក្រឹមនៅឯក្បាលទូក ។

រំដួលក៏ធ្វើត្រី លាងសំអាតរួចប្រុងនឹងកាត់ស្ងួរ តែពេលដែលនាងជះទឹករំអិលនិងកំទេចកាកស្រកាទៅក្នុងទឹក ក៏ប្រទាំជះដោយទាំងត្រីទៅជាមួយផង ធ្វើឱ្យនាងប្រហោងពោះធ្លុង អើតក្បាលចេញពីក្នុង

ទូក សម្លឹងតាមមើលត្រីដែលធ្លាក់ទៅក្នុងទឹក និងស្រែកហៅក្មួយថា ÷

-« អាភី !... ចុះមុជរាវរកត្រីបន្តិចម៉ោ !... អញប្រឡំជះធ្លាក់ទៅក្នុងទឹក... លឿនឡើង !...»

កុមារភី ក៏រត់តួងពីក្បាលទូក មកអើតមើលតាមនាងវិដ្ឋូលដែរ ហើយរអ៊ូ ÷

-« មីងអើយ ទឹកជ្រៅ ត្រឹមក្បាលខ្ញុំទៅហើយ ធើម៉េចរកឃើញទៅ ត្រីនោះវាផែលអណ្តែតទៅណាបាត់ទៅហើយ !...»

វិដ្ឋូល តឿនទៀតដោយព្រួយបារម្ភ ÷

-« ...វាមិនទៅណាទេក្មួយ វាប្រាកដជាធ្លាក់នៅត្រង់ហ្នឹង ចាំមីងយកពឹងពង់ដោត ឱ្យក្មួយឯងចុះរាវយកម៉ោ !... ត្រីរស់ធំដែរណាំស្តាយវា... កុំឱ្យបងឡឹងត្រឡប់មកវិញស្តីបន្ទោសថា មីងធ្វើការមិនប្រយ័ត្ន !...»

-« ណេ្អីយ !.. ចោលទៅ !... ម៉ែគាត់មិនថាអីទេ... ខ្ញុំខ្ជិលមុជរាវណាស់... បើរាវក៏មិនឃើញដែរ !...»

ទោះបីជាកុមារភី ក្រវៃជកវឹងរូសយ៉ាងណា ក៏នាងវិដ្ឋូលនៅតែងើបឈររកមើលពឹងពង់ ដែលដាក់នៅលើដំបូលទូក ដើម្បីដោតទៅក្នុងទឹក ត្រង់កន្លែងដែលត្រីធ្លាក់ ដោយនិយាយបណ្តើរ ÷

-« នែ៎ អាភី កុំរៀនខ្ជិល ចុះមុជរាវយកមួយភ្លែកម៉ោ ថ្ងៃរណេះហើយ ផ្សារគេឈប់លក់ ទៅរកទិញត្រីឯណាបានសួរទៅ បើមីងដាំទឹក ចិតបន្លែអីៗអស់ទៅហើយនោះ ?...»

ជូនជាមួយវិនាទី ដែលកុមារីកំពុងរារែក និងពេលដែលឆោម កញ្ញាប្រែខ្លួនក្រោករកមើលពិងពង់នោះ ស្រាប់តែមានសម្លេងដ៏ទន់ ត្រជាក់ បន្លឺមកពីក្នុងទឹក នៅក្បែរគែមទូកនោះថា ÷

-«...អ្នកនាង មិនបាច់ព្រួយបារម្ភពេកទេ នេះនែ៎ត្រី !...»

ឆោមទេវី ភ្ញាក់ព្រើត ងាកភ្នែត ឃើញយុវបុរសសុផលចំអើត ខ្លួនពីក្នុងទឹក ហុចត្រីរស់នោះមក ដែលចាប់បង្ខំធ្វើឱ្យនាងឆ្លើយសួរ ទៅកាន់ម្ចាស់ខ្សែភ្នែកដ៏មានស្នេហ៍នោះវិញ ទាំងនឹកឆ្ងល់និងអៀន ខ្មាស់ថា ÷

-«យី... ធ្វើម៉េច បានជាបងប្រុសរកឃើញត្រីនេះ ?...»

យុវបុរសមុខស្រស់ រលាស់បបូរមាត់ដ៏វៃឆ្លាតមកទៀត នៅទន្ទឹម ពេលដែលឆោមទេវីបន្ទន់ខ្លួន លូកដៃមកឈោងទទួលយកត្រី ដែល នៅក្នុងដៃគេនៅឡើយ ÷

-«ខ្ញុំមុជទឹកនៅក្បែរៗនេះ ស្រាប់តែឮអ្នកនាងស្រែកថាធ្លាក់ ត្រីទៅក្នុងទឹក ខ្ញុំក៏បន្ទិបខ្លួនស្រវាររាវចាប់បានភ្លាម ព្រោះត្រីធ្លាក់ អីចឹង វាមិនអណ្តែតទៅណាឆ្ងាយទេ ! តែខ្ញុំគេចពួនទៅម្ខាង មិន ទាន់ឱ្យ ចាំលបមើលអ្នកនាងជជែកគ្នាជាមួយក្មួយអ្នកនាងសិន !.»

ឮដូច្នោះ រំជួលព្រៃកហ្លួង ចងចិញ្ចើមរបៀបង៉ក់ងបន្តិច តាម ទម្លាប់ដែលនាងធ្លាប់និយាយលេងជាមួយមិត្តភ័ក្តិ ÷

-«ស្អប់ណាស់ រើសបានហើយ មិនប្រញាប់ឱ្យគេ នៅសម្ងំចាំ លបមើលគេទៀត... ខូចណាស់ !... ? »

សុផល ញញឹមតបនឹងកាយវិការគួរឱ្យក្នាញ់នោះ ÷

-«មិនឱ្យសម្ញុំចាំលបមើលម៉េច បើខ្ញុំមកមុជទឹកនៅកន្លែងនេះយូរពេលហើយ មិនដែលឮអ្នកណានិយាយពិរោះដូចអ្នកនាងសោះ ហើយមុខមាត់ក៏ស្អាតទៀត !... ស្អាតមែនតែម្តង !... ខ្ញុំមិនដែលឃើញទេ...! ណ្ហើយ បំណាច់នឹងបានជួយរើសត្រីឱ្យហើយ សុំស្គាល់ឈ្មោះផងបានទេ អ្នកនាង ?...»

បុត្រីមីងនួន ញញឹមលាក់គំនួចតាមបួកពាររមាយាស្រី ហើយរុញដៃមកមុខទៀត ÷

-«ងាប់ហើយ គ្រាន់តែរើសត្រីប៉ុណ្ណឹង អីក៏ទាមទារចង់ស្គាល់ឈ្មោះគេទៅហើយ ! ហ៊ឺ !... ឱ្យត្រីសិនម៉ោ !... ដាំទឹកពុះហើយណា៎ !... ចាំខ្ញុំប្រាប់ !...»

សុផល បន្ទរដៃបណ្តើរនិយាយបណ្តើរ ÷

-«អីចឹងហើយ ឱ្យរបស់ដែលរើសបាន ត្រូវតែមានសំណង បើមិនប្រាប់ មិនឱ្យទេ !...»

យុវបុរស រវល់តែនិយាយភ្លេចខ្លួន យុវនារីក៏លូកដៃមកកញ្ឆក់យកត្រីចូលទៅក្នុងទូកបាត់ ឥតឆ្លើយប្រាប់ថាដូចម្តេចសោះឡើយ ធ្វើយុវបុរសស្រងាកចិត្តក្រៃលែង ទើបរអ៊ូបណ្តើរ ÷

-«ឱ !... លេងស្ទៀតខូចរបៀបនេះ ចាំមើលណា៎ !... ថ្ងៃក្រោយបើជ្រុះរបស់អីទៀត ចាំរើសឱ្យ !... ស្បថ ?...»

ចំណែកកញ្ញារំដួលវិញ សែនទុញទើសក្នុងចិត្តជាខ្លាំង ។ នាងចង់ប្រាប់ឈ្មោះនាងដែរ តែខ្លាចបងស្រីនាងត្រឡប់មកវិញ ខឹងថាពេលដែលគេមិននៅ ហ៊ានប្រាប់ឈ្មោះឱ្យប្រុសដែលមិន ធ្លាប់ស្គាល់

គ្នា ទាំងដែលពេលនេះនាងកំពុងថិតនៅក្នុងសភាពសម្ងំលាក់ខ្លួន ។

ប៉ុន្តែ នាងគិតៗទៅ ទង្វើបែបនេះហាក់ដូចជាវាយឫកឆ្មើងឆ្មៃពេកហើយ ព្រោះពេលនោះ នាងលបមើលតាមប្រហោងក្តាជញ្ជាំងទូកទៅ ឃើញយុវបុរសនោះនៅតែហែលក្រឡឹងចុះឡើងក្បែរៗទូក និងបង្ហើរពាក្យតិចៗថែមទៀតថា ÷

-«កំណាញ់ណាស់ គ្រាន់តែឈ្មោះក៏មិនព្រមប្រាប់ ហើយលាក់មុខមិនចង់ឱ្យឃើញទៀត ?... ស្មានថាសម្ងំមិនចេញមកដាំស្ល នៅក្រោយទូកឬយ៉ាងម៉េចហ្នឹង ?...»

ជួនពេលនោះ កុមារភីស្ទុះពីក្បាលទូកមកវិញ ហើយស្រែកឡូឡាថា ÷

-«ហ្ន៎ !... បានត្រីមកវិញហើយតើ អ្នកណាជួយរើសមីងវ៉ដ្ឋល...? ចុះមីងឯងចាំអីទៀត មិនចេញមកស្ល ? ទឹកពុះចង់រីងហើយណា៎ !...»

វ៉ដ្ឋល មិនឆ្លើយតាមសំនួរនេះឡើយ បែរជាស្រែកបញ្ជាទៅក្មេងប្រុសវិញ ក្រោយដែលកាត់ត្រីជាកង់ៗហើយ ÷

-«នែ៎... អាភី យកត្រីទៅបង់ក្នុងឆ្នាំងទៅ គ្រឿងគ្រៅអីៗ មីងដាក់អស់ហើយ !...»

ក្មេងប្រុស លាន់មាត់ដោយងឿងឆ្ងល់ ÷

-«...ចុះមីងវ៉ដ្ឋលឯង មិនចេញទៅសួរខ្លួនឯង... មីងកើតអី... បានជារាងខ្មាចៗ... ខ្មាចអីហ្នឹង ?...»

ពេលនោះ សុផលក៏ស្រែកពីក្នុងទឹកមកថា ÷

-«ខ្លាចអី ? មីងរបស់ឯងខ្លាចពួណហ៎ា ព្រោះពូបានរើសត្រីឱ្យ ហើយសុំសួរឈ្មោះ តែមិនព្រមប្រាប់ !.... តែឥឡូវពូមិនភ័យទេ ទោះបីជាមិនប្រាប់ ក៏ពូស្គាល់ឈ្មោះហើយ ព្រោះពួឯងហៅអំបាញ់ម៉ិញថា រំដួលៗ !... អ្ហ៎ !... រំដួល... ឈ្មោះនេះពិរោះណាស់តើ គឺពិតជារំដួលស្ទឹងសង្កែ មែន !...»

ពូសុផលនិយាយបញ្ចើចឈ្មោះនាងផ្ទួនៗដូច្នោះ រំដួលក៏ប្រុងស្រែកតបមកវិញ ប៉ុន្តែជួនអីពេលនោះ ស្រាប់តែមានស្រីម្នាក់ដែលមានទូកនៅជិតនោះដែរ ដើរចុះពីលើមាត់ច្រាំងមក ហើយបន្លឺរសាយមកកាន់យុវបុរសនោះថា ÷

-«នែ៎ អ៊ើ ប្អូនសុផល ម៉េចនៅផ្ទះ ទឹកមិនចេញទេអ្ហិ... បានជាឧស្សាហ៍ឃើញមកមុជទឹកស្ទឹងនេះ ?...»

យុវបុរស ងាកទៅសើចដាក់នារីនោះវិញ ហើយឆ្លើយ ÷

-«...ផ្ទះខ្ញុំមានទឹកម៉ាស៊ីនគ្រប់គ្រាន់តើបងសំ តែពេលណាទឹកស្ទឹងស្រកនៅត្រឹមៗណោះ ខ្ញុំចូលចិត្តមកមុជទឹកស្ទឹងជាង វាត្រជាក់ស្រួល ៗហែលលេង !.... ហើយពេលណាមុជទឹកទៅ ពួសួរត្រីកំភ្លាញ ពិរោះស្តាប់ទៀតផង ខ្ញុំចូលចិត្តស្តាប់ត្រីកំភ្លាញយំណាស់បង !...»

-«ងាប់ហើយ ចូលចិត្តអីមិនចូលចិត្ត មកចូលចិត្តត្រីកំភ្លាញយំ... ទៅវិញ ? កុំភ្លេចពាក្យចាស់ពោលថា កំភ្លាញស្លាប់ពីព្រោះមាត់ណា៎ ប្អូនសុផល !...»

ដោយយល់ថា សម្លេងរបស់គេមុខជាពួទៅលេងនាងរំដួល ដែល

នៅសម្ងំក្នុងទូក ទើបសុផលធៀតម្សៀបខាយផ្ញើផ្កាបន្ថែមមកទៀតថា÷

-«តែខ្ញុំគិតថា ត្រីកំភ្លាញស្លាប់ពីព្រោះសម្រស់ទៅវិញទេ បងសំ ព្រោះខ្ញុំឃើញត្រីកំភ្លាញមួយនោះ អាងតែមានសម្រស់ស្អាតហែលគេចចុះគេចឡើង ទៅពួននៅក្រោមបាតទូក មិនព្រមឱ្យខ្ញុំចាប់លេងសោះ !.... តែមិនអីទេ កំភ្លាញមួយហ្នឹង មុខជាគេចមិនរួចពីថ្នងរបស់ខ្ញុំនៅថ្ងៃណាមួយទេ !...»

នាងសំ កាលបើឮសំដីសុផលប្លែកដូច្នោះ ក៏បើកភ្នែកធំៗ ÷

-«យី !... ត្រីកំភ្លាញមានសម្រស់ ? មិនដែលឮទេ ! »

-«មិនដែល ទើបប្រាប់បងសំឯងឱ្យឮហ្នឹងណាំ !...»

ដូចជាសុផលបានគិតមែន រំដួលដែលនៅពួនក្នុងទូក បានឮសំដីរបស់គេឆ្លងឆ្លើយជាមួយម្ចាស់ទូកនៅក្បែរនោះ គ្រប់ម៉ាត់ទាំងអស់នាងសែនទឹកខ្នាញ់ណាស់ ដែលបុរសនោះអាងតែជួយរើសត្រីឱ្យហ៊ានប្រដូចនាងទៅនឹងត្រីកំភ្លាញ នាងចង់តែឆ្លងឆ្លើយតបទៅវិញ តែខំទប់ចិត្ត ព្រោះមិនធ្លាប់ស្គាល់ជននោះជិតស្និទស្នាលផង នាំតែគេវាយតំលៃ ហើយជួនពេលនោះ នាងឮយុវបុរសឈ្មោះសុផល ចាប់ផ្ដើមនិយាយទៅកាន់នាងសំទៀតថា ÷

-«...ចុះខ្ញុំឮបងសំឯង និយាយប្រាប់ម្ដាយខ្ញុំថា ប្រុងលក់ទូកនេះ ទៅទិញដីសង់ផ្ទះនៅលើគោកជិតវត្តកណ្ដាលវិញ តើយ៉ាងម៉េចទៅហើយ រឺទៅថ្ងៃណា ?...»

នាងសំ យកដៃអេះក្បាលហើយឆ្លើយវិញ ÷

-«...មុនដំបូង គិតថាចង់រើដែរ តែគិតសព្វៗទៅ ខ្ជិលទៅនៅ

ឯណាឆ្ងាយ នៅទីនេះស្រួលជាង ព្រោះមានទឹកមុជស្រាប់ៗ ដូចជាប្អូនឯង ជាប់ចិត្តមកមុជទឹករាល់ថ្ងៃនេះដែរណា៎ ចោលទៅអោយរួច!

ទទួលឃ្លានេះ សុផលក៏ផ្លៀតនិយាយផ្លែផ្កាទៅឱ្យកញ្ញាជួរពេញទៀត ÷

-«អ្ហូ... បើអីចឹង ពិតជាវាសនារបស់ខ្ញុំខ្ពស់ហើយ បើបានបងសំងងនៅទីនេះយូរតទៅទៀត ខ្ញុំពិតជាចុះមកមុជទឹកមិនអផ្សុកទេ ជីវិតខ្ញុំមុខជាបានរីកស្រស់បំព្រងរហូតមួយជីវិតហើយ !...»

នាងសំ ទំនងជានឹកឆ្ងល់ជាងមុនទើបផ្លាយសំដីចេញមកទៀត ÷

-«អ្ហ៎...! ប្អូនសុផល ថ្ងៃនេះនិយាយដូចជាប្លែកៗណាស់ ! អីចឹងតើ សិស្សវិទ្យាល័យនិយាយពិរោះៗ ស្ទើរតែស្ដាប់មិនបាន !... អ្ហូ... នែ ចុះបងឮគេនិយាយថា ពីថ្ងៃទៀតមានធ្វើបុណ្យធំនៅវិទ្យាល័យព្រះមុនីវង្ស ដែលប្អូនឯងរៀននោះ តើមែនឬមិនមែន ?..»

មុននេះបន្តិច រំដួលដូចជាធុញទ្រាន់នឹងពាក្យផ្អែមល្ហែមបញ្ចៀតបញ្ចៀងរបស់យុវជនសុផលពេកណាស់ តែពេលដែលឮនាងសំនិយាយថា យុវបុរសនោះរៀននៅវិទ្យាល័យព្រះមុនីវង្ស នាងដូចជាមានចិត្តចង់ដឹងចង់ឮតទៅទៀត ទើបសម្ងំចាំស្ដាប់យុវជននោះឆ្លើយតបមកវិញ ÷

-«មែនហើយបង គេធ្វើបុណ្យចែករង្វាន់ដល់សិស្សដែលប្រលងជាប់ប្រចាំឆ្នាំណា៎ ហើយមានលេងសិល្បៈល្ខោនរបស់ក្រុមសិស្សទៀតផង !...»

-«ចុះគេមានបើកឱ្យអ្នកស្រុកចូលទៅមើលផងទេ ?...»

-«បើក ! គេបើកឱ្យទៅមើលគ្រប់គ្នា ដូចជារៀងរាល់ឆ្នាំអីចឹង ហើយគេមានសំដែងរឿងមួយ ល្អមើលណាស់បង !... បងឯងទៅមើលនឹងគេទៅ ហើយបបួលហៅអ្នកទូកនៅជិតខាងបងនេះ ទៅមើលឱ្យបានច្រើនគ្នាណាំ !...»

-«កុំភ័យ បងមុខជាបបួលគេឯង ទៅមើលឱ្យបានច្រើនគ្នាហើយ ! យី ចុះគេលេងរឿងអីទៅ អាចប្រាប់ឱ្យបងដឹងផង បានទេ ?...»

-«ហ៊ីក៏មិនបាន គឺគេលេងរឿងស្នឹងសម្ងាត់ណាំបង !...»

តាំងពីពេលឮថាយុវជននេះ រៀននៅវិទ្យាល័យព្រះមុនីវង្សរំដួលព្រែកហ្លួង ស្តាប់ដូចកាន់តែចូលត្រចៀកច្រើនឡើងៗ ហើយសមឮថាគេមានលេងសិល្បៈល្ខោនរឿង ស្នឹងសម្ងាត់ទៀតផងនោះ នាងក៏ចង់មើលណាស់ទៅទៀត ព្រោះនៅឯស្រុក នាងមិនសូវបានមើលសិល្បៈណា ក្រៅពីល្ខោនរាមកេរ្តិ៍ដែលគេទៅលេងម្តងម្កាលនោះឡើយ ។

នៅពេលដែលឆោមទេវី នឹកអរព្រួចៗនោះ ស្រាប់តែនាងឮយុវជននោះពោលខ្លាំង ទៅកាន់នាងសំទៀតថា ÷

-«ហើយបងសំឯងដឹងថា អ្នកណាជាតួឯកប្រុស នៅក្នុងរឿងស្នឹងសម្ងាត់នោះទេ ?... គឺខ្ញុំហ្នឹងណាំ !...»

ពេលនោះ នាងសំភ្ញាក់ស្ទើរថ្ងាកខ្លួនធ្លាក់ទៅក្នុងទឹក ហើយលាន់មាត់ ÷

-«យី !... ងាប់ហើយ ប្អូនឯងនិយាយលេងឬមែនហ្នឹង ? »

-«ខ្ញុំមិននិយាយកុហក់ទេ ខ្ញុំហាត់រាល់តែថ្ងៃហ្នឹង បើមិនជឿចាំ

មើល ដល់ថ្ងៃស៊ីដែងមុខជាឃើញហើយ !...»

នៅពេលនោះ បុត្រីមីងទួន ប្រែជាស្រងាកចិត្តយ៉ាងខ្លាំង កាល បើឮថាយុវជននោះ ជាតួឯកក្នុងរឿងស្ទឹងសង្សាត់ ។ នាងមិនមែន ស្អប់ខ្ពើមឬមើលងាយទេពកោសល្យរបស់គេនោះទេ ប៉ុន្តែនាងដូចជា នឹកអៀនជួស ហើយដូចជាមិនដឹងសំរេចចិត្តថា ទៅមើលឬយ៉ាង ណាផង ? ។

នៅពេលដែលរំដួលព្រែកហ្លួង សម្លុំគិតម្នាក់ឯងនោះ គេឃើញ សុផលឱ្យបខៀវជាមួយនាងសំ លួមតែឮពីរនាក់ថា ÷

-«នៅក្នុងទូកជិតនោះ មានស្រីម្នាក់ស្អាតណាស់បង ឈ្មោះថា រំដួល ! នាងកាត់សក់ផ្កាថ្កូវ ស្អាតប្លែកតែម្តង !... ខ្ញុំគ្រាន់តែឃើញ បង់ស្មូត !... ចាំបងជួយសើុបសួរមើល៍ តើនាងជាកូនចៅអ្នកណា នៅភូមិស្រុកណា ? ហើយកុំភ្លេចនិយាយទាក់ទងបបួលនាងឱ្យទៅ មើលល្ខោននោះផងណា៎ !...»

នាងសំ ជ្រួញចិញ្ចើម ÷

-«...ប៉ុន្មានថ្ងៃនេះ បងរវល់តែរឿងចង់លក់ទូក បានជាមិន បានចាប់ភ្លឹកថា មានអ្នកណាចេញចូលមកនៅថ្មី អិនអីទេ បងស្គាល់ ម្ចាស់ទូកនេះដែរ ចាំបងសើុបសួរឱ្យ ប្រហែលជាបងប្អូនកូនក្មួយគេ ហើយ !...»

# ៤

## អក្ខរាយោធាឃុំ

**យប់**នេះ បុត្រីមីងទួន ដូចជាមានអារម្មណ៍គិតដល់សិស្សវិទ្យាល័យ ដែលជួយរើសត្រីឱ្យនាងនោះជាខ្លាំង ។ មុខមាត់ រាងរៅគេស្រស់សង្ហារគួរឱ្យចូលចិត្តណាស់ ទាស់តែបូកពាររាងក្រឡេមក្រឡឹម ហើយមាត់ដាចបន្តិច ។

ស្អែកឡើង ប្រមាណជាម៉ោង ១២ ថ្ងៃត្រង់ ពេលដែលនាងឡឹងត្រឡប់មកពីលក់បន្លែ ផ្លែឈើវិញដូចសព្វមួយដង នាងសំក៏ឆៀតយកសម្ងរមួយចានមកឱ្យ និងសំណេះសំណាលលេងតាមនិស្ស័យជាអ្នកជិតខាង ដែលធ្លាប់រាប់អានគ្នាយូរមកហើយ ÷

-«អរគុណហើយ ប្អូនសំ !...» នាងឡឹងពោលឡើង «....បានយកសម្ងរមកឱ្យ ចុះប្អូនដប់ថ្ងៃកន្លះខែនេះ ប្អូនសំឯងរវល់ទៅណា បានដូចជាមិនឃើញ ?...»

នាងសំនិយាយដោយចោលភ្នែកមើលនាងរំដួល ដែលយកចានមកចាក់ផ្ទេរសម្ងរ «...អ៊ូ... ខ្ញុំចាចង់លក់ទូក ទៅនៅលើគោកវិញ បានបេះតែដើរទាក់ទងគេ តែឡូវសំរេចចិត្តថាលែងលក់វិញហើយ !.. យី !... ចុះ...នាង...នេះ ត្រូវជាអ្វីនឹងបងឡឹងឯងដែរ... ស្អាត....

បាតណាស់ !...? »

នាងឡឹងនិយាយនៅពេលដែលរំដួល យកចានឆ្នាំងសំទៅលាង នៅខាងក្រោយទូក ÷

-« ចា៎ះ វាត្រូវជាប្អូនជីដូនមួយរបស់ខ្ញុំ ជាកូនអោយ៉ុំព្រែកហ្លួង! ឪពុកវាទើបនឹងស្លាប់ ប្រហែលជាងកន្លះខែនេះ ព្រោះពួកចោរព្រៃបាញ់ !... ហើយឥឡូវ ម្តាយវាបានផ្ញើមកឱ្យនៅជាមួយខ្ញុំ គ្រាន់ជួយមើលការខុសត្រូវមួយរយៈ ព្រោះនៅឯណោះ ពួកព្រៃចេះតែអុកឡុកពេក !...»

នាងសំ ខំដាក់មនោសញ្ចេតនា ទៅតាមរបេកសំនៀងពាក្យរបស់នាងឡឹង ហើយឆ្ងៀតបន្ថែមតិចៗ ÷

-« អូ៎... អីចឹង នាងមិនទាន់មានគ្រួសារទេ ចា៎ះ ?..»

-« នៅទេ !...» នាងឡឹងឆ្លើយតាមធម្មតា ដោយគ្មានចាប់ភ្ញីកអ្វី ...តែមានគេចង់បានច្រើនណាស់ !...»

-« នៅក្រមុំ ស្អាតរបៀបនេះ ជៀសមិនផុតពីគេចោមស្រឡាញ់ទេ បងអើយ !...»

នាងសំ ទំនងជាចង់និយាយអ្វីបន្តទៀត តែដោយរំដួលកាន់ចានត្រឡប់មកប្រគល់ឱ្យវិញ នាងក៏អាក់ខាន គ្រាន់តែញញឹមទទួលដោយការរាប់អានប៉ុណ្ណោះ ។

....អាស្រ័យដោយមាននាងសំ ជាអ្នកនាំពាក្យចុះឡើង សុផលក៏បានដឹងពីខ្សែជីវិតសង្ខេបរបស់នាងរំដួល ហើយរំដួលក៏បានដឹងពីសំបុកទ្រយុកគ្រួសារសុផលវិញដែរ គឺសុផលជានិស្សិតថ្នាក់ទី ១

ទំនើបជាតិ នៅវិទ្យាល័យព្រះមុនីវង្ស ហើយជាកូនម្ចាស់ហាងលក់ថ្នាំពេទ្យដ៏ធំមួយ ឈ្មោះឱសថស្ថានស្ទឹងសង្កែ ដែលមានទីតាំងនៅជាប់រោងកុនអេដែននោះដែរ ។

ក្រៅពីហាងលក់ថ្នាំពេទ្យនេះ ឪពុកម្ដាយរបស់សុផលនៅមានភូមិករ ដីធ្លី ស្រែចំការជាច្រើនហិកតាទៀត សំរាប់ជួលឱ្យគេបង្កបង្កើនផលផ្សេងៗ ដូចជាស្រូវជាដើម ហើយតែងបានទទួលផលគាប់ប្រសើរជារៀងរាល់ឆ្នាំ ។ ព្រមជាមួយនោះ បើតាមសំដីនាងសំ ថាឪពុកម្ដាយសុផល នៅមានដាក់ក្រុមហ៊ុនធ្វើឡូតិនេសាទ និងអាជីវកម្មត្បូងនៅបរប៉ៃលិនទៀតផង គឺផលទុន ដែលបានមកទាំងអស់ទុកសំរាប់ជាកេរមត៌កឱ្យសុផល ដែលជាកូនទោលតែមួយ ជាត្រួយបណ្ដូលប្រចាំវង្សត្រកូលតែប៉ុណ្ណោះ ។

ដោយសារសំដីរបស់នាងសំ ដែលលបលួចមកបង្កើបនិយាយឱ្យបខ្សៀវប្រាប់នាងរំដួល នៅពេលបន្ទាប់មួយទៀត ដែលបងនាងមិននៅ ជាប់រវល់ទៅទិញផ្លែឈើនោះ ធ្វើឱ្យបូជាព្រែកហ្លួងបណ្ដែតអារម្មណ៍គិតវែងឆ្ងាយ ហើយមមៃនឹកថា បុរសដែលនាងតែងគិតស្រមៃ ថាត្រូវជ្រើសរើសមកធ្វើជាគូស្រករប្រចាំជីវិត សំរាប់កសាងសុភមង្គលទៅថ្ងៃអនាគតនោះ គឺបុរសប្រភេទសុផលនេះឯង ព្រោះនាងចូលចិត្តអ្នករៀនសូត្រ អ្នកចេះដឹង ចេះរកស៊ី ធ្វើការងារនៅទីក្រុង មិនមែនជាមេឧទ្ទាមចោរព្រៃ ដូចនាយត្រឡែឬនាយទាហានកាចសាហាវដូចព្រិន្ទបាលឯកបំណាន និងកូនទាហានឃុំរបៀបនាយយស់នោះឡើយ ។

ស្មើរពេញមួយយប់នោះ រំដួលតែងដេកស្រមៃគិតម្នាក់ឯងថា សុផលនិងនាង ប្រហែលជាគូព្រេងពីជាតិមុនទេដឹង បានជាព្រហ្មលិខិតកំរិតឱ្យមកជួបគ្នាដោយចៃដន្យដូច្នេះ ? ។

ហេតុតែជាស្រីក្រមុំ ដែលមិនធ្លាប់ជួបប្រុសណា ពេញចិត្តពេញថ្លើមដូច្នេះ រំដួលហ៊ានរហូតដល់ទៅចោទសួរខ្លួនឯងបែបនេះថា បើសិនសុផលស្រឡាញ់នាង ដូចជាសំដីខ្សែបខាយរបស់គេមែននោះ នាងប្រហែលជាមានវាសនាខ្ពស់ណាស់ ! ព្រោះនឹងបានក្លាយទៅជាកូនប្រសារអ្នកមាន សមដូចចិត្តគំនិតរបស់ម្ដាយនាងដែរ ! ប៉ុន្តែមិនដឹងថាតើ សុផលគេស្រឡាញ់នាងពិត ឬមួយក៏គេមានគូកំណាន់ចិត្តមុនទៅហើយ ? ។

៙ ៙ ៙

ស្អែកឡើង ពេលដែលនាងឡើងចេញទៅលក់ដូរ និងកូនៗនាងទៅរៀនអស់ រំដួលរសាប់រសល់ជាខ្លាំង ចង់សួរអីៗដល់នាងសំទៀត តែនាងសំក៏មិនទៅ ឃើញបិទទ្វារទុកចោល ។

លុះដល់ពេលល្ងាច ក៏មិនឃើញសុផលចុះមកមុជទឹកដូចមុនដែរ ឃើញតែអ្នកដទៃ ធ្វើឱ្យរំដួលកាន់តែក្អក់ខ្នាញ់កន្ទក់កន្ទេញក្នុងចិត្តទ្វេឡើង នឹកថាប្រហែលជាសុផលេ មិនខ្វល់គិតដល់នាងទេ បានជាគេលែងមកមុជទឹក ឱ្យនាងបានឃើញមុខទៀត ។

ដល់ពេលព្រលប់ ទើបនាងលបមើលទៅឃើញនាងសំត្រឡប់មកវិញ តែនាងមិនហ៊ានទៅសួរនារីនោះ ពីរឿងដែលមិនឃើញ

សុផលមកមុជទឹកនោះឡើយ ដោយខ្លាចបងស្រីនាងអឹងរឿង ម៉្លោះហើយនាងទ្រាំដេកខ្វល់ចិត្តស្ទើរពេញមួយយប់ ដោយបេះតែនឹកថាសុផលដែលឈប់មកមុជទឹកនេះ ប្រាកដជាអន់ចិត្តនឹងនាង ដែលកញ្ឆក់យកត្រីពីដៃគេមក ដោយមិនព្រមប្រាប់ឈ្មោះទៅវិញនោះមែនហើយ ? ។

តែព្រឹកព្រលឹមឡើង នៅពេលដែលនាងឡើងចេញទៅលក់ផ្លែឈើផុត ស្រាប់តែនាងសំបានឡៀតមកប្រាប់ ដោយមិនចាំបាច់រំឭលសួរមុនថា «សុផលដែលមិនបានចុះមកមុជទឹកនេះ មិនមែនគេអាក់អន់ចិត្តនឹងនាងនោះទេ គឺគេជាប់រវល់ហាត់ល្ខោនខ្លាំងពេក ព្រោះត្រូវចាប់សំដែងនៅយប់នេះហើយ គឺហាត់ដល់យប់ៗជ្រៅទើបត្រឡប់មកផ្ទះ ក៏អស់ពេលចុះមកមុជទឹកដូចមុនៗ ! តែសុផលសូមផ្ដាំថាទោះបីយ៉ាងណា នាងត្រូវតែទៅមើលល្ខោនរឿងស្នឹងសម្ងាត់របស់គេជាដាច់ខាត បើនាងមិនទៅមើលទេ ឈ្មោះថានាងស្អប់ខ្ពើមគេ ហើយគេច្បាស់ជាលែងហ៊ានចុះមកមុជទឹក នៅក្បែរទូកនាងទៀតហើយ » ។

ដំណឹងនេះ ធ្វើឱ្យបូផាព្រៃកហ្លួងធូរចិត្តយ៉ាងច្រើន និងបានឡៀតប្រាប់ទៅនាងសំវិញថា «សូមកុំឱ្យសុផលព្រួយឱ្យសោះ ទោះបីយ៉ាងណា នាងត្រូវតែសុំបងជីដូនមួយរបស់នាង ទៅមើលល្ខោននោះឱ្យទាល់តែបាន ! » ។

តែជួនអី នៅប្រមាណជាម៉ោង ១០កន្លះ ពេលដែលរំឭលរៀបចំដាំបាយធ្វើម្ហូប មីងន្ទួនក៏បានធ្វើដំណើរមកពីព្រៃកហ្លួងតាមទូកដរ

មកលេងនឹងកូន ដែលធ្វើឱ្យកញ្ញារំដួលស្វាគមន៍ទទួលម្តាយ ដោយសេចក្តីរីករាយជាខ្លាំង ÷

-« ម៉ែ... ខ្ញុំនឹកម៉ែណាស់ !...» រំដួលវាចាឡើង ដោយអររខិបរខុប «... ខ្ញុំគិតថា បើមិនឃើញម៉ែមកទេ បួនប្រាំថ្ងៃទៀត ខ្ញុំសុំបងទៅលេងហើយ ព្រោះខ្ញុំនឹក...! »

-«...អឺុ.... មិនបាច់ទៅទេ !...» មីងនួននិយាយដោយទាញកន្ត្រកអីវ៉ាន់ មករើបង្ហាញកូនបណ្តើរ «... ម៉ែចង់មកតាំងតែពីប៉ុន្មានថ្ងៃមុនមកម្ល៉េះ តែនៅជាប់ធ្វើផ្អក ម៉ាំ និងត្រីប្រៃមកធ្វើ !... អឺុ នេះនែ៎ ត្រីបែកចុំ អាយស់វាបេះមកធ្វើកូនឯង និងដូងតឹកកែមួយធ្លាយទៀត...ហ្ន៎ះ !....»

និយាយផង មីងនួនក៏ដកយកសំបុត្របិទស្រោមមួយចេញពីហោប៉ៅអាវ នៅខណ្ឌមពេលដែលរំដួលសួរថា ÷

-« ម៉ែ !... បងយស់គាត់សុខសប្បាយទេម៉ែ ? គាត់បាត់គ្រុនចាញ់ហើយនៅ ?...»

មីងនួន ឆ្លើយបណ្តើរ ហុចសំបុត្រមកកូនបណ្តើរ ÷

-« អឺុ... វាផឹកថ្នាំឈើដែលម៉ែរកឱ្យ បានគ្រាន់មែនទែនហើយ! នេះនែ៎ គេធ្វើសំបុត្រនេះមកកូនឯងទៀតផង !...»

រំដួលប្រែទឹកមុខបន្តិច មិនទាន់ហ៊ានទទួលសំបុត្រទើបសួរ ÷

-« សំបុត្រអីហ្នឹងម៉ែ ? មានការអី ម៉េចគាត់មិននិយាយផ្តាំតាមម៉ែ ចាំបាច់ធ្វើសំបុត្រ ធ្វើអី...អីបឹង ! តើមានអាថ៌កំបាំងអីទៅ ?...»

មីងទួនសំឡឹងមុខកូន ហើយពោលដោយញញឹម ÷

-« អ៊ើ,,, ម្រហែលវាអៀនខ្មាស់ មិនហ៊ាននិយាយផ្ដាំផ្ញើតាមម៉ែណា៎ !,,, កូនមើលទៅមើល៍ បើតាមអញយល់ ថាប្រហែលជាវាលួចស្រឡាញ់កូនឯងហើយ !,,,»

វ៉ដ្ឋូល ប្រែទឹកមុខ ធ្វើដូចជាមិនដឹងអីទាំងអស់ ÷

-« ម៉ែ !,,, បងយស់,,,គាត់ស្រឡាញ់ខ្ញុំ ម៉េចក៏ម៉ែដឹង ?»

-« អ៊ើ,,, ម៉ែចាស់ហើយ អារឿងហ្នឹង ម៉ែរហ័សមើលដឹងណាស់ !,,, គ្រាន់តែម៉ែមិននិយាយ ?,,, មើល៍ ហែកសំបុត្រវាមើលទៅ !,,, ម៉េចៗគង់ដឹង,,,ទេ !!,,,»

វ៉ដ្ឋូលក៏ហែកសំបុត្រយស់ អាននៅចំពោះមុខម្ដាយភ្លាម ÷

**ជូនចំពោះ វ៉ដ្ឋូល !**

តាំងពីវ៉ដ្ឋូលឃ្លាតចេញពីឃុំព្រែកហ្លួងមក ខ្ញុំតែងនឹករលឹកមកដល់វ៉ដ្ឋូលទាំងថ្ងៃទាំងយប់ គ្មានលោះពេលណាទេ ។ វ៉ដ្ឋូលប្រហែលជាយល់ចិត្តខ្ញុំហើយ ថាខ្ញុំស្រឡាញ់វ៉ដ្ឋូល ចង់រៀបការជាមួយវ៉ដ្ឋូល តែស្ដាយណាស់វ៉ដ្ឋូលមិនទាន់បានឆ្លើយតបប្រាប់មកខ្ញុំវិញ ថាវ៉ដ្ឋូលស្រឡាញ់ខ្ញុំឬយ៉ាងណានោះទេ ? ខ្ញុំចង់បានចម្លើយពីវ៉ដ្ឋូលណាស់ សូមវ៉ដ្ឋូលឆ្លៀតសរសេរសំបុត្រ ផ្ញើតាមលោកអ៊ំទៅប្រាប់ខ្ញុំផង កុំឱ្យខ្ញុំអស់សង្ឃឹមឱ្យសោះ ! ។

ឥឡូវនេះ ខ្ញុំបានជាជម្ងឺគ្រុនចាញ់ហើយ ខ្ញុំមានសុខភាព

ល្អវិញហើយ នៅពេលណាដែលរំដួលត្រឡប់ទៅវិញ ខ្ញុំមានសមត្ថភាពគ្រប់គ្រាន់នឹងការពាររំដួល មិនឱ្យពួកចោរព្រៃមកប្រមាថមើលងាយរំដួលបានឡើយ ។

ខ្ញុំគ្មានអ្វីផ្ញើមករំដួលទេ ក្រៅពីផ្លែត្របែកទុំមួយចង្កោម និងដូងតឹកកែមួយធ្លាយ ដែលខ្ញុំខំឡើងបេះព្រោះយល់ថារំដួលចូលចិត្តផ្លែឈើទាំងពីរមុខនេះណាស់ ។

មិនតែប៉ុណ្ណោះ វាជាដំណាងនូវបេះដូងដ៏បរិសុទ្ធនិងស្មោះត្រង់បំផុតរបស់ខ្ញុំចំពោះរំដួល ។

ពីខ្ញុំដែលរង់ចាំ !

**យស់**

រំដួលអានចប់ នៅស្ងៀមដោយទឹកមុខស្មើ ឯមីងនួនក៏សួរដោយញញឹមស្ងួតថា ៖

-«ប្រាប់ម៉ែតាមត្រង់មើល៍ កូនមានដែលឮយស់វានិយាយរឿងនេះផ្ទាល់ជាមួយឯងទេ ?...»

ដោយគិតថាមិនត្រូវលាក់នឹងម្ដាយតទៅទៀត ទើបរំដួលប្រញាប់ឆ្លើយដោយមិនអឹមអៀនថា ៖

-«ខ្ញុំធ្លាប់បានជួបសំដីផ្ទាល់នឹងគាត់ម្ដងដែរ នៅកំពង់ទឹកមុនមួយថ្ងៃ ដែលខ្ញុំចេញដំណើរមកនៅជាមួយបងឡឹងនេះ ! គាត់និយាយដូចក្នុងសំបុត្រនេះឯង គឺគាត់ចង់ឱ្យខ្ញុំឆ្លើយថាស្រឡាញ់គាត់វិញ.... តែខ្ញុំមិនឆ្លើយ ! ឥឡូវបើម៉ែដឹងយ៉ាងនេះហើយ គិតយ៉ាង

ម៉ែចទៅ ?...»

មីងនួន ពោលដោយអារម្មណ៍ត្រជាក់ ÷

-«....ការពិត ម៉ែមិនស្អប់វាទេ អាយស់នោះ សព្វថ្ងៃបើកុំតែបានវាជួយការពារផ្ទះសំបែង ក៏ពិបាកដែរ ! តែទាស់ត្រង់អាយស់វាក្រពេក បើឱ្យវារៀបការនឹងឯងទៅ អ្នកស្រុកព្រៃកហ្លួងគេមុខជាសើចរយះមាត់ហើយ ! ខ្វះណាស់ ចៅកែៗ គេចង់បានគរគោក !...មិនឱ្យ បែរជាទៅឱ្យអាកូនទាហានឃុំ ដែលមិនដឹងជាប្រាក់ខែ ប្រាក់ង៉ៃនៅឯណាផងហ្នឹង ?....»

វណ្ណលដកដង្ហើមធំ ទើបពោលដោយសម្លឹងមុខម្តាយ ÷

-«ចុះក្រែងគេនិយាយថា ឱ្យតែស្រឡាញ់គ្នាដោយស្មោះ ទ្រព្យរបស់នឹងកើតក្រោយទេ ហ្នឹង ?...»

មីងនួន សម្លឹងមុខកូន ដោយខ្សែភ្នែកប្លែក ÷

-«អឺ... វាអីចឹងមែនហើយ តែបើក្រពេករបៀបអាយស់ដែលមានតែក្របីមួយនឹម និងដីមួយអំពកនោះ មិនដឹងជាធ្វើយ៉ាងណាឱ្យមានបានឆាប់ យិតយោងត្រួសាររួចទេ ! ហើយបើក្រតើមានសុភមង្គលពីណាម៉ោ ? បន្តិចទៅ មានកូនមានចៅ តើអ្នកណារកស៊ីចិញ្ចឹមអ្នកណា ? ម៉ែឃើញច្រើនគ្នាហើយ ពេលស្រឡាញ់ក៏ស្រឡាញ់ មិនគិតវែងឆ្ងាយ ទីបំផុតបានត្រឹមតែទឹកភ្នែកជូតក្បាលជង្គង់ប៉ុណ្ណោះ តែម៉ែក៏អាណិតវាដែរ វាពិតជាស្រឡាញ់ឯងដោយស្មោះហើយ !...»

វណ្ណលអោនមុខបន្តិច ទើបងើបវាចាដោយទឹកមុខស្រងូត ÷

-«...និយាយអីចឹង ចុះអាមេចោរត្រខ្មែរ ម៉ែមានបានដឹងអ្វីពីវាខ្លះទេ ពេលដែលខ្ញុំមិននៅនេះ ?...»

មីងនួន ចាប់ផ្ដើមបៀកម្លូរស្លាញាត់មាត់យ៉ាងទូញ ដោយពោលបណ្ដើរទំពារបណ្ដើរ ÷

-«អឺ... រឿងអាត្រខ្មែរនោះ បើតាមអាយស់វានិយាយថា មានគេឃើញកូនចៅវាមកក្រវែលៗផ្ទះយើង ពីប្អូនដងដែរ ហើយក្រោយដែលដឹងថា កូនឯងមិននៅ វាក៏បានពាំនាំយកសំដីអាត្រខ្មែរមកផ្សព្វផ្សាយថា វាដាច់ខាតត្រូវតែយកកូនឯងធ្វើជាប្រពន្ធឱ្យបាន តែវាមិនមកឯស្រុកសង្កែនេះទេ ដោយវាខ្លាចគេចាប់ វាបានឱ្យដឹងថា វានឹងចូលសារភាពធ្វើជាប្រជាជនស្លូតត្រង់ធម្មតាវិញ ហើយវានឹងមករកឯងជាក្រោយ !...»

វ៉ដ្ឋូល រាងចងចិញ្ចើមបន្តិច ហើយសួរបញ្ជាក់ទៅវិញ ÷

-«ចុះ វាចូលសារភាពហើយនៅ ម៉ែ ?...»

មីងនួន ស្ដោះទឹកមាត់ស្លាប្រូច ទៅក្នុងទឹកស្ទឹងក្រហមច្រាល ហើយតបក្រោយពីទាញយកក្ងួនកន្សែងក្រហមមកជូតមាត់ ÷

-«នៅទេ !... វាគ្រាន់តែព្រលយពាក្យតាមកូនចៅវាប៉ុណ្ណោះ! បើវាចូល ម៉ែចក៏លោកចំណានមិនដឹងនោះ ?...»

វ៉ដ្ឋូល ក៏ប្រែទឹកមុខទៅតាមសាច់រឿងថ្មី ÷

-«...មែនហើយ !... ចុះ ! ចុះ !... លោកព្រិន្ទបាលឯកនោះ មានឃើញជិះសេះទៅក្រវែលដូចមុនទេ ម៉ែ ? »

មីងនួន សម្លឹងចំមុខកូន ហើយពោលយើតៗច្បាស់ៗ ហាក់ដូច

រឿងនេះមានសារៈសំខាន់ពន់ពេកណាស់ ÷

-« លោកចំណាននោះ តាំងពីពេលកូនឯងចេញមក ជាត់មុខរហូត ទើបតែឃើញទៅលេងម្សិលមិុញនេះឯង ហើយប្រាប់ម៉ែថាគាត់រវល់ទៅលេងស្រុក ដែលនៅឯខេត្តពោធិសាត់ ដើម្បីទៅប្រាប់ឪពុកម្ដាយឱ្យមករៀបចំស្ដីដណ្ដឹងកូន ហើយថា គេនឹងមកលេងនឹងកូននៅថ្ងៃស្អែកឬខានស្អែកនេះហើយ ! នេះ ម៉ែថាតាមតែពាក្យគេ អឹងជាគេនិយាយមែន ឬកុហក ?...»

វណ្ណលឮដូច្នោះ ប្រែទឹកមុខជាស្លូតបន្តិច ទើបសួរម្ដាយវិញ ÷

-« ចុះបើសិនជាលោកចំណាននោះមកដណ្ដឹងខ្ញុំមែន តើម៉ែយល់យ៉ាងណាដែរ ?...»

មីងនួន ដកដង្ហើមធំ បែរមុខចំវណ្ណល ÷

-« បើនិយាយពីបុណ្យស័ក្តិអំណាចរបស់គេ អ្នកណាក៏ប្រាថ្នាចង់បានមកធ្វើជាកូនប្រសារដែរ ព្រោះថ្ងៃក្រោយបុណ្យស័ក្តិគេនឹងឡើងធំទៀត ! កាលណាស័ក្តិកាន់តែធំ ទ្រព្យសម្បត្តិក៏កាន់តែសម្បូរណ៍ដូច្នេះមិនបាច់ព្រួយខ្វល់អីពីរឿងនេះឡើយ គឺភ័យព្រួយតែម៉្យាងក្រែងគេមានប្រពន្ធកូនហើយប៉ុណ្ណោះ !...»

វណ្ណលព្រែកហ្លួង វាចាដោយលាក់គំនួចជាប់ក្នុងកែវភ្នែក ÷

-« ...ខ្ញុំមិនព្រួយពីរឿងនេះទេ តែខ្ញុំមិនចូលចិត្តទាហាន ដែលមាននិស្ស័យកាចសាហាវរបៀបលោកហ្នឹង ! ខ្ញុំឮគេថាពួកជល់មាន់ឬលេងល្បែង សុទ្ធតែត្រូវគាត់ចាប់យកទៅគោះក្បាលហើយធាក់ទម្លាក់ទៅក្នុងទឹក ! មនុស្សចិត្តយក្សរបៀបហ្នឹង ដល់មានប្រពន្ធទៅ

មុខជារាំយធ្វើបាបប្រពន្ធ ដូចជាពួកនោះមិនខានឡើយ !... ខ្ញុំខ្លាចណាស់ !....»

មីងនួន ឮដូច្នោះ ក៏នឹកចង់សើច ÷

-« អើ !... ក្រែងគេធ្វើបានតែមនុស្សល្ងើសនឹងច្បាប់ ឯប្រពន្ធកូន គេស្រឡាញ់ថ្នាក់ថ្នមណាំ !...»

-« ខ្ញុំមិនទុកចិត្ត.... ទេ !...»

ម្ដាយនិងកូនជជែកគ្នាដល់ត្រឹមណោះ ស្រាប់តែនាងឡឹងនិងកូនៗត្រឡប់មកដល់ ក៏លែងនិយាយអ្វីតទៅទៀត ។

នាងឡឹងមានសេចក្ដីត្រេកអរ គ្រាដែលឃើញម្ដាយមីងមកលេង ក៏បន្លឺដោយរាក់ទាក់ថា ÷

-« មីង !... មិនបាច់យកអង្ករ ផ្អក ម៉ាំ មកទេ នៅឯណោះមានសព្វគ្រប់ហើយ គិតតែមីងឯណោះទៅ ក្រែងខ្វះខាត !..»

-« អើ !... ឯងមិនមែនសម្បូរណ៍ ដូចកាលប្ដីឯងនៅរស់ពីកាលណា ត្រូវតែជួយគ្នាយ៉ាងនេះហើយ !...»

ម្ដងនេះ ស្រាប់តែនាងឡឹងបន្លឺដោយញញឹមរីករាយទៀត ÷

-« មីងមកចំពេលនេះ ត្រូវម៉ាប់ ! ព្រោះនៅសាលាលីស្សេគេមានលេងល្ខោនកូនសិស្សយប់នេះ... ខ្ញុំឮអ្នកផ្សារគេនិយាយគ្រប់គ្នា !... ខ្ញុំគិតថា មីងនិងវិរំដួលត្រូវនាំគ្នាទៅមើលនឹងគេទៅ មិនងាយបានឃើញទេមីង !..»

មីងនួន មិនទាន់ឆ្លើយថាដូចម្ដេចផង ស្រាប់តែនាងសំស្មុះចេញពីទូកដែលនៅជិតនោះ ចៅរ៉ៅចូលមក ហើយបន្លឺដោយញញឹម

ញញ្ញែមមកកាន់នារីទាំងបីថា ៖

-«អ៎ូ !... លោកមីងជាម្ដាយរបស់ប្អូនវំដួល អញ្ជើញមកលេងជាការប្រសើរហើយ លោកមីងនាំប្អូនវំដួលទៅមើលនឹងគេទៅ ឱ្យបានធូរស្បើយល្ហើយចិត្ត ឮថាគេសំដែងរឿងស្ទឹងសម្ងាត់ ហើយឮថាតួឯកប្រុសដែលលេងក្នុងរឿងហ្នឹង គឺជាប្អូនសុផល កូនចៅកែហាងលក់ថ្នាំពេទ្យ នៅក្បែររោងកុនអេដែន មុខទូកយើងនេះដែរណា! »

គ្រាន់តែឮប៉ុណ្ណឹង នាងឡឹងក៏ស្រែកឡើងដោយភ្ញាក់ផ្អើល ៖

-«អ៎ូ !... ប្អូនសុផលហ្នឹង ខ្ញុំធ្លាប់ឃើញដែរតើ ពេលខ្ញុំទៅទិញថ្នាំពេទ្យម្ដងៗ ! ហើយធ្លាប់ចុះមកមុជទឹកលេងនៅក្បែរៗទូកយើងនេះទៀតផង ប្អូនកម្លោះហ្នឹងស្រស់សង្ហារណាស់ អីចឹងបានគេឱ្យដើរតួឯក... អ៎ូ !... ល្អមើលងាប់ហើយ !.... ខ្ញុំត្រូវតែទៅមើលខានមិនបានទេ !...»

នៅពេលដែលវំដួលញញឹមខ្ចិប ព្រោះត្រូវគ្រប់គ្នានិយាយសរសើរដល់មនុស្ស ដែលនាងកំពុងពេញចិត្តនោះ មីងទួនក៏និយាយដោយញញឹមស្ងួត ទៅកាន់អ្នករាល់គ្នាថា ៖

-«អ៊ើ !... ក្មួយឡឹង នាំប្អូនទៅមើលចុះ មីងមិនបាននៅទេ មីងត្រូវត្រឡប់ទៅវិញតាមទូកដរ ដែលគេនៅចាំ ហ៎ះ !...»

វំដួលក៏ប្រែទឹកមុខ សួរម្ដាយដោយឆ្ងល់ ៖

-«ម៉ែ... អីក៏ប្រញាប់ម្ល៉េះ.... នៅសំរាកលេង... មើលល្ខោននឹងគេមួយយប់សិនទៅ ស្អែកសិមទៅក៏បាន គ្មានទាស់អីទេ !..»

នាងឡឹង ជួយបន្ថែម ៖

-«មែនហើយ អីក៏ប្រញាប់ម្ល៉េះមីង មកលេងមិនបានប៉ុន្មានផង ស្រាប់តែទៅវិញភ្លាម !...»

មីងទួន នៅតែប្រកែក ៖

-«...អ៊ើ... មីងមិនអាចបោះបង់ផ្ទះបានទេ.... ពេលនេះ ! ចាំថ្ងៃក្រោយសឹមនៅយូរ ! នែះ បើកុំតែមានការត្រូវមកប្រាប់រឿងឯណេះរំដួលផង ប្រហែលជាមិនទាន់មកទេ !... មិនអីទេ... យប់នេះនាំប្អូនទៅមើលចុះ ដើម្បីកុំឱ្យគ្នាអផ្សុក មីងមិនថាអីទេ !....»

ក្រោយពីនិយាយលេងពីនេះពីនោះ មួយសន្ទុះទៀត មីងទួនក៏លាក្មួយនិងកូនឡើងទូកដរ ជិះត្រឡប់ទៅព្រែកហ្លួងវិញ ប៉ុន្តែមុននឹងចេញទៅ រំដួលបានឆ្លៀតនិយាយផ្តាំផ្ញើជាសម្ងាត់ប្រាប់ម្តាយថា ៖

-«ម៉ែ !... ផ្តាំទៅបងយស់ផង... ថាខ្ញុំអរគុណហើយ ដែលគាត់បានធ្វើត្របែកនិងដូងឱ្យខ្ញុំ ! ខ្ញុំនឹកគាត់ណាស់ដែរ តែខ្ញុំមិនអាចឆ្លើយប្រាប់គាត់បានទេពីចិត្តរបស់ខ្ញុំ... សូមគាត់តស៊ូ អត់ធ្មត់សិនចុះ !...»

*

* *

# ៥

# វាចាដួងចិត្ត

**ទោះ**បីយ៉ាងណាក៏ដោយ ក៏បុរសដែលចោមរោមស្រឡាញ់នាងទាំងប៉ុន្មាននៅឯឃុំព្រែកហ្លួង គឺចិតនៅក្រៅខ្សែភ្នែករបស់នាងទាំងអស់ ។ រីឯបុរសដែលចិតក្នុងក្ដីស្រមៃរបស់នាងវិញនោះ គឺមានតែកម្លោះសុផលប៉ុណ្ណោះ ទោះបីជាមកទល់ពេលនេះ នាងមិនទាន់បានដឹងចិត្តគេយ៉ាងណាក៏ដោយ ។

ប៉ុន្តែ ក្នុងយប់ដែលនាងបានទៅមើលល្ខោន នាងបានកត់សំគាល់ឃើញថា យុវជននេះពិតប្រាកដជាស្រឡាញ់នាងមែន ព្រោះអាកប្បកិរិយាទាំងប៉ុន្មាន ដែលគេសំដែងមកលើនាង ដូចជានៅពេលដែលនាងទៅដល់ក្លោងទ្វារចូលនៃវិទ្យាល័យ ជាមួយនាងឡឹងជាបង ដោយមានក្មួយប្រុសនាងទាំងពីរ និងនាងសំអមដំណើរជូនទៅផងនោះ សុផលដែលមិនទាន់ដល់ពេលសំដែង បានមកឈរចាំស្វាគមន៍រាក់ទាក់ទទួលនាង ហើយពោលតិចៗដោយក្ដីរំភើបរីករាយមកក្បែរត្រចៀកនាងថា ÷

-« យប់នេះ ដួងតារានៃក្ដីសង្ឃឹម បានរះតាំងពីក្បាលល្ងាច

អ្វីៗពិតជាត្រូវរស់ស្រស់បំព្រង នៅក្នុងបេះដូងរបស់តួឯកប្រុសនៃរឿងស្នឹងសម្ងាត់នេះហើយ !...»

សំដីដែលប្រកបដោយអត្ថន័យ ដ៏ផ្អែមល្ហែមត្រជាក់របស់យុវបុរសដ៏ប៉ិនប្រសប់នោះ មិនត្រឹមតែធ្វើឱ្យបេះដូងដ៏ក្មេងខ្ចីរបស់បូផាព្រែកហ្លួង កំរើករញ្ជួយលំអងទងស្រទាប់ប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យនាងឡើង រំពឹងយល់បានភ្លាមថា យុវបុរសនោះពិតជាមានចិត្តប្រតិព័ទ្ធមកលើប្អូនពីដូនមួយរបស់នាងហើយ ។

ប៉ុន្តែ ស្រីមេម៉ាយនេះ ហាក់ដូចជាគ្មានប្រតិកម្មអ្វីប្រឆាំងរាំងរានឹងទំនាក់ទំនងរវាងកម្លោះក្រមុំនេះឡើយ ផ្ទុយទៅវិញនាងកាន់តែមានកំស្តួលចិត្តត្រេកអរទៅវិញទេ បើពិតជាសុផលស្រឡាញ់ប្អូននាងមែននោះ ។

ព្រោះ ទោះបីជាមិនចាំបាច់នាងសំព្រាប់ ក៏នាងបានដឹងជាយូរមកហើយថា ថៅកែហាងលក់ថ្នាំពេទ្យស្នឹងសង្កែនោះមានកូនប្រុសតែមួយ មានសម្បត្តិទ្រព្យច្រើន ហើយកូនក៏រៀនបានខ្ពស់ទៀត ស្រីក្រមុំណាក៏ប្រាថ្នាចង់រៀបការជាមួយប្រុសកម្លោះនេះដែរ ។

ពេលនោះ សុផលមិនត្រឹមតែរាក់ទាក់ទទួលនៅមាត់ខ្លោងទ្វារចូលប៉ុណ្ណោះទេ គឺគេបានស្ទុះស្ទារឆ្វេងស្តាំ នាំនាងរំដួលនិងបងប្អូនទៅរកកន្លែងអង្គុយដោយស្រួល ហាក់ដូចពួកនាងជាភ្ញៀវមានកិត្តិយសមិនពិបាកឈរមើលដោយជើង ដូចអ្នកខ្លះនោះឡើយ ។

កាយវិការយកចិត្តទុកដាក់របស់ប្រុសកម្លោះ ធ្វើឱ្យយុវនារីសក់ផ្កាថ្កូវកក់ក្តៅក្នុងចិត្តជាខ្លាំង រហូតដល់ពេលគេឡើងទៅសំដែងលើ

ភាកទៀត ក៏សុផលនៅតែលួចឆ្លៀតចោលកន្ទុយភ្នែកមករកនាងស្ទើរគ្រប់ពេលវេលាទាំងអស់ ធ្វើឱ្យបូផាព្រែកហ្លួង មិនសូវដឹងសាច់រឿងប៉ុន្មានឡើយ ដោយរវល់តែតាមសំលឹងមើលកាយវិការដើរចុះឡើងរបស់ប្រុសកម្លោះ គ្រប់ដង្ហើមចេញចូល ។

ល្ខោនរឿងស្នឹងសម្ងាត់ បានខាបស្រូបយកដួងព្រលឹងរបស់បុត្រីមឹងនួន ឱ្យអណ្តែតត្រសែតទៅក្នុងភពផែនដែនវិប្បយោគមួយ អស់រយៈពេលពីរម៉ោង តាមរលកចំរៀងភ្លេងជីវិតដ៏សែនពិរោះ ដែលកម្លោះតួឯកបានបញ្ចើរសំនៀងបញ្ជិតបញ្ចៀងមករកនាង ធ្វើឱ្យនាងកាន់តែព្រឺព្រួចជាងពេលណាទាំងអស់ ។

យប់នោះ រំដួលព្រែកហ្លួងនិទ្រាពោរពេញដោយចិត្តសុខភិរម្យពន់ប្រមាណ ដោយអ្វីៗដែលកូនកម្លោះអ្នកលក់ថ្នាំពេទ្យសំដែងលើភាក និងសំដែងមកកាន់នាងទាំងប៉ុន្មាន បានសណ្ឋិតជិតចូលទៅក្នុងសុបិននាងរៀងរហូតទើសភ្លឺ ។

....**នៅ**វេលាម៉ោង ៥ល្ងាច សុផលបានចុះមកមុជទឹកនៅក្បែរទូកនាងឡើង ហើយបានដើរសរសៀរទៅខាងក្រោយទូក ឃើញស្រស់កញ្ញាកំពុងដាំស្ល ក៏សួរថា ÷

-« បងស្រីអ្នកនាង មិននៅទេអ្ហី ?...» -

រំដួល តបដោយប្លែមត្រជាក់ ÷

-« គាត់នៅស្នាក់ទូកឪឡឹក នៅឯព្រែកមហាទេពបាត់ទៅហើយបងសួររកគាត់មានការអី ?...»

-« បាទ !... ខ្ញុំចង់មកសូមទោសគាត់ ក្រោយពេលដែល

ល្ខោនចប់ហើយ ខ្ញុំមិនបានចេញមកជូនដំណើរ ត្រឡប់មកវិញ ! ព្រោះអ្នកដឹកនាំរឿងល្ខោន រវល់ប្រមូលប្រជុំតួសំដែងទាំងអស់ !... ម៉្លោះហើយខ្ញុំរំលៀកខ្លួនមកមិនរួច !...»

ឆោមទេពី បង្ហើរខ្សែញញឹមតបទៅវិញព្រមដោយសំនៀង ÷

-«...អ្ហូ !... មិនបាច់មកសូមទោសអីទេ បងគ្មានខុសត្រង់អីទេ ការពិត បងបានជួយសម្រួលពួកខ្ញុំច្រើនណាស់ហើយ ពេលដែលទៅមើលល្ខោនយប់ម្សិលមិញនេះ ?...»

សិស្សវិទ្យាល័យ ខំប្រឹងបំអើតខ្លួនឱ្យខ្ពស់ពីទឹកស្ទួរមកទៀត ÷

-«និយាយអីចឹង ល្ខោនយប់មិញនេះ យ៉ាងម៉េចដែរ ?...ខ្ញុំអៀន... រឹងខ្លួនអស់ហើយ សឹងតែលេងមិនកើត មិនដឹងជាអ្នកនាងសើច ពេបមាត់យ៉ាងណាទេ !...»

រ៉ដ្ឋល វាចារបៀបមាយា ÷

-«បើដឹងថារឹងខ្លួន ចង់លេងមិនកើត ម៉េចក៏ខំអន្ទងបបួលហៅខ្ញុំឱ្យទៅមើលធ្វើអី ?...»

-«មែន !.. ខ្ញុំគិតខុស !... តែមិនដឹងជាយ៉ាងម៉េច បានជាបណ្ដាលឱ្យខ្ញុំ ចង់តែហៅអ្នកនាងឱ្យទៅមើល ?.... តែការពិត ខ្ញុំទើបយល់ច្បាស់នៅពេលនេះថា អ្នកនាងគឺជាកម្លាំងចិត្តដ៏ធំធេងណាស់ សំរាប់ជំរុញឱ្យខ្ញុំសំដែងបានល្អជាងពេលណាទាំងអស់ !...»

ឆោមទេពី តបពាក្យពេញដោយគំនួចចិត្ត ÷

-«កុំនិយាយអីចឹង ការពិតបងសំដែងបានល្អតាមសមត្ថភាពរបស់បងទេតើ !... គិតទៅគួរឱ្យអាណិតតួប្រុសផលហើយ៉ា មិនគួរ

ត្លូស្រីក្បត់ចិត្តទៅមានប្ដីទៀត ធ្វើឱ្យតួប្រុសយំសោកបោកខ្លួននៅមាត់ស្ទឹង រហូតដល់ស្លាប់ខ្លួនយ៉ាងនោះសោះ ស្រីអីក៏ដាច់មេត្តាយ៉ាងហ្នឹង ?...»

សុផល ចងចិញ្ចើមបន្តិចទៀត ÷

-«អីចឹង អ្នកនាងអាណិតតួប្រុសនោះខ្លាំងណាស់មែនទេ !... អ្នកនាងមានស្រក់ទឹកភ្នែកទេ ពេលដែលខ្ញុំឈរច្រៀងកំសត់នៅមាត់ស្ទឹងនោះ ?...»

-«ចេះនិយាយអីចឹង អ្នកណាដែលស្រណោះអាណិត ហើយមិនស្រក់ទឹកភ្នែកនោះ ?...»

-«បើអ្នកនាងជាតួអង្គស្រីនោះវិញ ប្រហែលមិនធ្វើបាបតួប្រុសឱ្យគ្នាស្ដោកស្រពោនដួងចិត្ត ដូចរឿងនោះទេ មែនទេ ?...»

វំដួល អោនមុខចុះ រួចទើបងើបនិយាយទៅទីផ្សេង ÷

-«ម៉េចក៏ចង់ឱ្យខ្ញុំឆ្លើយអីភ្លាមៗយ៉ាងនេះ តែខ្ញុំដែលអាណិតតួប្រុសនោះ មកពីឃើញបងឈរច្រៀង បទនោះកំសត់ពិរោះពេក !... ខ្ញុំចង់ចេះដល់ហើយ តើបទនោះឈ្មោះអីទៅ បងអាចបង្ហាត់ឱ្យខ្ញុំចេះច្រៀងផងបានទេ... ? »

សុផល ខំឆ្លើយតបដោយញញឹមស្ងួត ÷

-«អូ៎ អ្នកនាងយល់ច្រឡំហើយ ខ្ញុំមិនចេះច្រៀងពិរោះដល់ថ្នាក់ហ្នឹងទេ គឺមានគេច្រៀងពីក្នុងឆាកបន្ទរជំនួសខ្ញុំទេតើ ឯខ្ញុំគ្រាន់តែបង្ហើបមាត់តិចៗប៉ុណ្ណោះ !...»

វំដួល ឮដូច្នេះនឹកចង់សើច ÷

-«គិតទៅតួអង្គប្រុសនេះ ចេះល្បិចបោកបញ្ឆោតផងហ្ន៎ ធ្វើឱ្យខ្ញុំខូចអារម្មណ៍ ខាតទឹកភ្នែកអស់មិនតិច !...»

សុផល ក៏តបដោយញញឹមស្ងួតវិញដែរ ៖

-«ហ្នឹងជាបច្ចេកទេសសិល្បៈណា៎ អ្នកនាង តែសំរាប់បេះដូងរបស់អ្នកដើរតួអង្គនោះវិញ ពិតជាស្មោះត្រង់មិនចេះបោកបញ្ឆោត....ទេ !...»

រំដួលក៏នឹកថា យុវជននេះ ពិតជាស្មោះត្រង់គួរឱ្យទុកចិត្តណាស់ ព្រោះដូចជារឿងច្រៀងសំដែងតួ គេអាចនឹងអួតថា គេចេះច្រៀងពិរោះបានមែន ដោយគ្មានខ្លាចនាងដឹងឡើយ ! ហេតុអ្វី គេបែរជាមកប្រាប់នាងតាមត្រង់ ដោយគ្មានទឹកមុខខ្មាស់ដូច្នេះទៅវិញ ? ។

គិតរួច ទើបទេវីផងស្ទឹង បន្ទរទៅភ្លាមថា ៖

-«ទុកណាជាគេច្រៀងពីក្រោយឆាកក៏ដោយ ក៏គង់បងចេះចាំបទនោះដែរ ! កត់ទំនុកវាឱ្យខ្ញុំរៀនច្រៀងផងបានទេ ព្រោះពាក្យពេចន៍នោះមានន័យពិរោះណាស់ បទនោះឈ្មោះថា ស្ទឹងសម្ងាត់មែនទេបង ?...»

សុផល ប្រញាប់ឆ្លើយដោយមិនលោក់ ៖

-«ត្រូវហើយ គឺបទផងស្ទឹងសម្ងាត់ ទំនុកច្រៀងខ្ញុំតែង ឯបទភ្លេងរបស់គេ ! មិនអីទេ បើអ្នកនាងពេញចិត្តបទនេះ ចាំស្អែកខ្ញុំកត់យកមកឱ្យ...! តែបើចង់ចេះច្រៀងផង ទាល់តែខ្ញុំជួយបង្ហាត់ !...»

យុវនារី ញញឹមដោយក្ដីពេញចិត្ត ៖

-«...ខ្ញុំចង់ឱ្យបងជួយបង្ហាត់ហ្នឹងណា៎ គ្រាន់ទុកច្រៀងលេងកំដរ

អផ្សុកទៅថ្ងៃក្រោយ !..»

នឹកឃើញអ្វីមិនដឹង សិស្សវិទ្យាល័យព្រះមុនីវង្ស បន្ទឹបន្ថែមទៀត ÷

-«ខ្ញុំជួយបង្ហាត់បាននៅថ្ងៃទំនេរ តែបើខ្ញុំឡើងទៅបង្ហាត់លើទូកដូចជាមិនសម ចាំមានឱកាស អ្នកនាងទៅលេងចំការក្រូចខ្ញុំ... នោះខ្ញុំមានកន្លែងស្ងាត់ ជួយបង្ហាត់អ្នកនាង !... ចំការខ្ញុំសប្បាយណាស់ណា ចាំបបួលទាំងបងអ្នកនាងនិងបងសំ ទៅលេងដែរ !..»

វិដ្ឋូល កាន់តែញញឹមស្រស់ជាងមុន ÷

-«មែនហើយ... ខ្ញុំចង់ទៅលេងណាស់... បងទំនេរថ្ងៃណាទៅហ្ន៎... ចាំខ្ញុំប្រាប់បង...ខ្ញុំ... ? »

ជួនអី ពេលដែលសុផលរៀបឆ្លើយនឹងសំនួរចុងក្រោយនេះស្រាប់តែផ្សែងចង្ក្រានហុយពុង ចេញពីខ្ទះចៀនត្រី វិដ្ឋូលលាន់មាត់ថា ÷

-«អ៊ូយ រវល់តែនិយាយជាមួយបង ខ្លោចត្រីចៀនទៅហើយ! »

សុផល សើចហើយក៏មុជផ្លិបទៅក្នុងទឹកបាត់ឈឹង.... ។

....ស្រាប់តែ នៅពេលដែលបេះដូងនាង កំពុងពោរពេញដោយអារម្មណ៍រីករាយសប្បាយ ព្រោះបានចរចារជាមួយយុវបុរសជាទីពេញចិត្តនោះ លោកព្រិន្ទបាលឯកចំណាន បានជិះសេះមកឈប់នៅក្រោមដើមអំពិល នៅត្រើយម្ខាង ហើយដើរចុះតាមស្ពានឈើ ឆ្លងកាត់ស្ទឹងសំដៅមកទូកនាងឡើង ដែលពេលនោះ វិដ្ឋូលបានក្រឡេកឃើញមុន ។

ទោះបីនាង មិនសូវចាប់អារម្មណ៍នឹងនាយទាហាននេះប៉ុន្មានក៏

ដោយ ក៏នាងនៅតែញញឹមស្រស់ស្ងោះស្ញុំត្រគាក់ទាក់ ហៅចំណានឱ្យឡើងលើទូក និងរៀបចំក្រាលកន្ទេល ដាក់ទឹកទទួលសមរម្យតាមឋានៈរបស់គេ ។

ចំណាន គ្រាន់តែឃើញអោមកញ្ញាភ្លាម ក៏អរស្ទើរបិទមាត់មិនជិត ហើយបន្ទឹថា ÷

-« ប្អូនដប់ថ្ងៃនេះ ខ្ញុំរវល់សុំច្បាប់ទៅលេងស្រុក ដើម្បីប្រាប់ឱ្យឪពុកម្ដាយខ្ញុំ រៀបចំចូលមកស្ដីដណ្ដឹងរំដួលក្នុងពេលឆាប់ៗនេះ !.. ស្រាប់តែត្រឡប់មកវិញ មិនឃើញរំដួល លោកមឹងប្រាប់ថាមកនៅទីនេះ ខ្ញុំក៏ប្រញាប់មកភ្លាម !... តែស្ដាយណាស់ មិនគួររំដួលបារម្ភអ្វីសោះ អាត្រឡៃវាមិនហ៊ានមករំខានអ្វីទេ បើកាលណាមានទ័ពខ្ញុំបោះប្រចាំការនៅទីនោះ !..»

-« តែម្ដាយខ្ញុំគាត់មិនទុកចិត្ត ទើបឱ្យខ្ញុំភៀសមកនៅទីនេះមួយរយៈសិន ! ប៉ុណ្ណឹងហើយ នៅតែវាបោះសំដីទៀតថា វាដាច់ខាតត្រូវតែមកយកខ្ញុំ ធ្វើជាប្រពន្ធឱ្យបាន កាលណាវាចូលសារភាពហើយ !...»

ព្រិន្ទបាលឯក សើចកំឡា ÷

-« វាមិនទាន់ខ្ញុំទេ ព្រោះខ្ញុំនឹងចូលដណ្ដឹងរំដួលឆាប់ៗនេះហើយ ហើយបើវាចូលសារភាព វាគោងតែចូលតាមរយៈខ្ញុំ ! នោះខ្ញុំនឹងមានវិធានការណ៍ចំពោះវា មិនឱ្យវាធ្វើអ្វីបានឡើយ ! ឥឡូវ !... នៅតែរឿងមួយប៉ុណ្ណោះ ដែលខ្ញុំបារម្ភព្រួយ គឺរឿងរំដួលនេះផ្ទាល់ គឺបើខ្ញុំចូលដណ្ដឹង តើរំដួលប្រកែក ឬព្រមហ្នឹង ?...»

បុត្រីមីងទួន ឆ្លើយហាក់ដូចមិនភ្ញាក់ផ្អើលប៉ុន្មានឡើយ ÷

-« រឿងនេះ ស្រេចលើម៉ែខ្ញុំទេ ប៉ុន្តែ !...»

វិដូល ប្រុងនិយាយអ្វីខ្លះទៀត តែត្រូវនាយទាហានឆ្លើយកាត់ ÷

-« តែ... យ៉ាងម៉េច ប្អូនវិដូលខ្លាចខ្ញុំជាទាហាន មានចិត្តសាហាវកាចឃោរឃៅ... ?....អូ៎ !... (បំណានអស់សំណើច) កុំខ្លាចអី ខ្ញុំកាចបំពោះតែមនុស្សខូចទេ តែបំពោះវិដូល កាលណារៀបការហើយ ខ្ញុំមុខជាថ្នមដូចកែវភ្នែកអីចឹង !...»

-« មិនមែនរឿងនេះទេ តែខ្ញុំគិតថា គួរលោកកុំអាលប្រញាប់ពេកអីង ព្រោះខ្ញុំចង់កាន់ទុក្ខឪពុកខ្ញុំ ឱ្យបានគ្រប់១០០ថ្ងៃសិន ! »

បំណាន ងក់ក្បាល ÷

-« បុះមានទាន់រៀបការភ្លាមៗឯណា គឺគ្រាន់តែដណ្តឹងប្រកាន់ទុកឱ្យហើយ ក្រែងមិនទាន់គេ ព្រោះនាងស្អាតរបៀបនេះ ជៀសមិនរួចពីគេតាមស្រឡាញ់នោះទេ !... លាក់ចាំងអី ទាហានខ្លះអាងអំណាចស្រឡាញ់កូនគេ អាងតែចាប់ អាងតែជំរត់ ឯខ្ញុំមិនធ្វើឆ្កួតយ៉ាងហ្នឹងទេ គឺខ្ញុំត្រូវធ្វើទៅតាមច្បាប់ប្រពៃណីខ្មែរ... សូមវិដូលកុំព្រួយឱ្យសោះ !...»

ភោមកញ្ញា អង្គុយបត់ជើងស្តាប់នាយទាហានរៀបរាប់ដោយក្តីអៀនអន់ពន់ប្រមាណ ប៉ុន្តែចិត្តនាងវិញនោះ មិនប្រាកដថានៅក្នុងខ្លួននោះឡើយ គឺវាអណ្តែតផុតឆ្ងាយទៅហើយ !.... ទៅរក... យុវបុរសម្ចាស់បទដងស្ទឹងសម្ងាត់ឯណោះ ដែលនាងកំពុងសន្យាថា នឹងឱ្យគេបង្ហាត់ច្រៀងនៅក្នុងពេលស្ងាត់ណាមួយ ។......

**ស្អែក**ឡើង រំដួលព្រែកហ្លួង រង់ឱ្យតែដល់ល្ងាចឆាប់ ដើម្បីបាន ជួបនឹងយុវជនមុខស្នេហ៍នោះមករកនាងទៀត ពិសេសគឺយកពាក្យ ពេចន៍ទំនុកច្រៀងមកឱ្យនាង ប៉ុន្តែដល់ពេលណាត់ បែរជាឃើញនាង សំ កាន់សំបុត្រមួយមកឱ្យនាងវិញ ដោយនិយាយមើលឆ្វេងមើលស្តាំ ថា ÷

-«...បងឡឹង ទៅណាហើយ ?...»

រំដួល ប្រញាប់ឆ្លើយភ្លាម ដោយសម្លឹងមើលសំបុត្រនៅលើដៃ នាងសំភ្លៀកៗ ÷

-«ថ្មើរៗណោះ បងខ្ញុំគាត់មិនដែលនៅទេ ហើយក្មួយៗវានាំគ្នា ទៅលេងឯណាអស់ហើយ !... ចុះមីងកាន់សំបុត្រអីមកហ្នឹង ? »

-«អ៊ើ... អំបាញ់មិញ បងដើរឆៀងក្បែរហាងស្ទឹងសង្កែ ស្រាប់ តែឃើញប្អូនសុផល ហុចសំបុត្រនេះ ពឹងឱ្យបងយកមកឱ្យប្អូនឯង គេថានេះជាទំនុកច្រៀងស្ទឹងសម្ងាត់ ល្ខោនដែលយើងទៅមើលនោះ អី ! គេថារំដួលចង់បាន ទើបគេប្រញាប់យកមកឱ្យ តែល្ងាចនេះ គេមិនបានចុះមកមុជទឹកទេ... គេមានការ !...»

រំដួល ទទួលយកសំបុត្រនោះដោយញញឹម ហើយនៅពេល ដែលនាងសំចេញផុត នាងក៏ប្រញាប់ហែកមើលភ្លាម ស្រាប់តែ ឃើញមានក្រដាស់ពីរសន្លឹកដោយឡែកពីគ្នា គឺក្រដាសមួយសន្លឹកជា អត្ថបទទំនុកច្រៀង ឯមួយសន្លឹកទៀតជាលក្ខណៈសំបុត្រសុទ្ធសាធ តែជាពាក្យកាព្យជូនរណ្តំ ។

ដោយក្តីរំភើបរំជួលចិត្ត ភោមនារីក៏ស្ទុះរឹងទៅលាតសំបុត្រនោះ

សម្ងំអាន នៅលើដំណេករបស់នាងថា ÷

ចំពោះរំដួលស្រស់ភិមភ្ញង
បូជាព្រៃកហ្លួងលំអងខ្ចី
តាំងពីរៀមបានឃើញចរណៃ
យប់ថ្ងៃហប្ញទ័យសែនខ្វាចផ្សា ។

អូនល្អពេកពិតឥតមានទាស់
បងលង់សម្រស់ឆោមជីវ៉ា
សំណាងបងបានរើសមច្ឆា
ឱ្យស្រស់កន្និដ្ឋា ដោយថៃជន្យ ។

ឱ ស្ទីងសង្កែខ្សែជីវិត
តើជារឿងពិត ឬសុបិន ?
ហេតុអ្វីរាល់យប់រូបមាសឆ្អិន
នៅក្នុងសុបិនបងជានិច្ច ? ។

បងសូមសច្ចាពេលថ្ងៃរះ
បងសូមសំពះពេលថ្ងៃលិច-
ប្លុងស្ងួងសូមស្រីកុំកែគេច
បំភ្លេចពាក្យបងផ្ញើមកស្ងួន ។

បងពិតជាស្នេហ៍ពៅពេកពន់
សូមស្រស់តូចតន់អូនដឹងខ្លួន
ឆ្លើយប្រាប់ទៅវិញកុំគេចពួន
បងរង់ចាំសួនផ្តល់ដំណឹង ។

ស្នេហ៍បងពិតជាស្នេហ៍ភក្តី
សូមស្រស់ពិសីកុំបីខឹង
បងនឹងរៀបចំចូលដណ្តឹង
ឱ្យតែព្រលឹងឆ្លើយថាព្រម ។

លោកនេះមានតែរូបអូនម្នាក់
ដែលបងសូមស្ម័គ្រស្មោះថ្នាក់ថ្នម
តែបើសិនជាអូនមិនព្រម
បងនឹងរីងស្គមស្គាំងលុះក្ស័យ ។

ឱ អូនរំដួលឈួលក្លិនស្នេហ៍
ផលបុណ្យបុព្វេផ្ញើរនិស្ស័យ
ហេតុតែគូព្រេងពីអតី
ទើបបងជួបស្រីនៅលើទូក ។

បងស្នេហ៍អូនពេកដេកស្រមៃ
ថាបានអោបស្រីដេករាល់ [illegible]

ភ្ញាក់ឡើងបាត់អូនបងសែនសោក
ទឹកភ្នែកជន់ជោកលើឱរា ។

បងសង្ឃឹមថាស្រស់វរមិត្ត
មេត្តាអាណិតផលរៀមរ៉ា
កន្ទង់រង់ចាំតែបូជា
ឆ្លើយថា "ស្នេហា" មកវិញខ្មី !! ។

ពីបងដែលរង់ចាំ !

**សុផល**

ដោយអក្សរានេះ មានន័យប្លែមល្អែមលើសពីចំរៀងស្ទឹងសម្ងាត់នោះទៅទៀត រំដួលក៏លើកលិខិតនោះថើបបីបួនដង ហើយឱ្យបតិចៗដាក់ក្រដាសថា ÷

-«...មិនអីទេ អូននឹងឆ្លើយទៅបងវិញ ថាអូនព្រម !..»

ហេតុតែជាកូនរបស់មេឃុំជំនាន់ចាស់ ដែលធ្លាប់បានបួសរៀនសាលាវត្ត ចេះចាំស្ទាត់នូវក្បួនខ្នាតអាចីកំបាំង នៃការតាក់តែងល្បើកឆន្ទគណៈ កំណាព្យកាព្យឃ្លោង រំដួលក៏បានចេះចាំខ្លះៗមកពីខ្មោចឪពុក ដែលពេលនោះស្រស់ទេវី ចាប់សាកល្បងសរសេរផ្ញើទៅសុផលវិញថា ÷

ឱ បងសុផល និមល បិត្ត
អូនបានយល់ពិត អក្សរាថ្លៃ
ពាក្យបងផ្អែមល្ហែមក្លែមអត្ថន័យ
ធ្វើឱ្យអូនស្រីរំភើបពេក ។
អូនជាម្ចាស់ត្រីដែលថ្លៃពិស
បិត្តមិនទុញទើសរឹងដូចដែក
អូនសូមឆ្លើយភ្លាមមិនចាំស្អែក
ថាអូនស្នេហ៍ពេក ចំពោះថ្លៃ ។
តែបងត្រូវឆាប់ដណ្តឹងអូន
តាមបែបបទក្បួនប្រពៃណី
អូនមិនប្រកែកឡើយចរណៃ
ព្រោះអូនស្នេហ៍ថ្លៃខ្លាំងក្រៃណា ។
អូនចង់ជួបបងដោយផ្ទាល់មាត់
ដើម្បីស្បែស្បថស័ព្ទសច្ចា
បើបងពិតជាស្នេហ៍អូនរ៉ា
សូមប្រុសជីវ៉ាណាត់ពេលមក ! ។
ពីបូជាព្រែកហ្លួង **រ៉ដួល**

ក្រោយដែលតែងអក្សរានេះចប់ហើយ រំដួលក៏បានលួចលាក់ពីងពាក់នាងសំ ឱ្យយកទៅឱ្យសុផលវិញក្នុងថ្ងៃជាបន្ទាប់មក ។

# ៦

# ស្នេហា ឬ តណ្ហា ?

**ដោយ**សារអត្ថភាពឆ្លើយឆ្លងនេះ កម្លោះក្រមុំទាំងទ្វេក៏បានយល់ចិត្តថ្លើមគ្នាមួយអន្ទើ តាមកម្លាំងរេក់ទាញ នៃរលកបេះដូងដ៏ក្ដៅពុះកញ្ជ្រោលរោលរាល ។ ក្រោយនោះ សុផលក៏ឆ្លៀតពេលមកបបួលវណ្ឌលឱ្យទៅលេងចំការរបស់ខ្លួន ដោយមានទាំងនាងឡឹង នាងសំនិងក្ដួយប្រុសទាំងពីរទៅជាមួយដែរ ។

យុវបុរសបានយកឡានស៊ីត្រូអែនខ្មៅរបស់ឪពុកគេ មកបញ្ជិះនារីទាំងបីនិងកូន ឆ្ពោះទៅអន្លង់វិល ហើយបត់ចូលទៅកាន់ចំការក្រូចរបស់គេ ដែលមានទេសភាពត្រឈឹងត្រឈៃ គួរជាទីមនោរម្យ ។

ដោយសប្បាយនឹងឃើញដើមឈើស៊ីផ្លែជាច្រើន ដែលផុះជាជួរជាសង្កាត់ខ្វាត់ខ្វែង នាងឡឹង នាងសំក៏នាំគ្នាអង្គុយលេងនៅក្រោមដើមដូង ព្រមទាំងរៀបចំធ្វើម្ហូបអាហារទៀតផង ។ ឯសុផលបាននាំវណ្ឌលនិងក្ដួយនាងដើរបេះផ្លែក្រូច ល្មុត មង្ឃុត សេដា យកមកប្រគល់ឱ្យស្រីទាំងពីរ បានពីរបីកន្ត្រក ហើយគេនាំគ្នាបរិភោគដោយក្ដីរីករាយសប្បាយ ។

ក្រោយពីស្រស់ស្រូបបាយថ្ងៃត្រង់រួច នាងឡឹង នាងស៊ំ នាំគ្នាសំរាកលេងនៅក្រោមម្លប់ឈើ ឯសុផលក៏បន្ទឺថា ÷

-«ខ្ញុំសូមនាំវ័ត្តលទៅដើរលេងក្រោយចំការបន្តិច ព្រោះវ័ត្តលនាងចង់ឱ្យខ្ញុំបង្ហាត់ច្រៀងបទល្ខោន ស្ទឹងសម្ងាត់នោះ !...»

វ័ត្តល វាចាបន្ថែម ÷

-«...បទហ្នឹងពិរោះណាស់បង ទាល់តែកន្លែងស្ងាត់ទើបបង្ហាត់ច្រៀងឆាប់ចេះ ?...»

នាងឡឹង បែរមើលនាងស៊ំ ហើយងាកមកសម្លឹងវ័ត្តលវិញដោយបន្ទឺដោយញញឹម ÷

-«មានទាស់ខុសអី... នាំគ្នាទៅដើរលេងចុះ ចាំល្ងាចបន្តិចសិមត្រឡប់ទៅវិញ !...»

ហាក់ដូចជាបានទទួលការបើកដៃ សុផលក៏បាននាំស្រីស្រស់វ័ត្តល ដើរនិយាយលេងហួរហែ សំដៅទៅកាន់ខ្ទមមួយដែលនៅខាងក្រោយចំការ ÷

-«បងសុផល អ្នកមិនដឹងថា បងប៉ិនប្រសប់សរសេរសំបុត្រជាកំណាព្យយ៉ាងនេះសោះ ?...»

-«នេះជាលើកទីមួយសំរាប់ជីវិតបងហើយ ៗបងខំសរសេរសំរាប់តែអូនម្នាក់ប៉ុណ្ណោះ តែទោះបីយ៉ាងណាក៏ពាក្យពេចន៍របស់បងប្រៀបនឹងសំបុត្ររបស់អូនមិនបានដែរ !...»

ណោមទើរី យកដៃខ្ទប់មាត់ប្រុសស្នេហ៍ ហើយបង្អើរសំនៀងស្រួយឮ្ងារ ÷

-«បងចូលចិត្តតែបញ្ឆោរអូន !... បញ្ឆោរយ៉ាងនេះហើយបានជាធ្វើឱ្យអូនស្លុតវិញ្ញាណអស់ !... ហ្នឹងប្រាកដជាស្រលាញ់អូនមែនទែន ឬយ៉ាងម៉េច ?...»

យុវបុរសទុចជំហានឈប់ គ្រាដែលដើរមកដល់ក្រុងកន្លែងស្ងាត់មួយ ហើយបែរមកប្រឈប់ស្មាឆោមទេពី ÷

-«អូនចង់ឱ្យបងវះពោះយកបេះដូង មកឱ្យអូនមើលអ្វី ? បងពិតជាស្រលាញ់អូនស្មោះណាំ ហើយបងនឹងឱ្យឪពុកម្តាយមកស្តីដណ្តឹងអូនក្នុងពេលឆាប់ៗនេះ !...»

ស្រីស្រស់ បញ្ឈាំងរស្មីនេត្រាចំភ័ក្ត្រាបុរស ហើយតប ÷

-«ចុះឪពុកម្តាយបង គាត់ដឹងរឿងយើងទាំងពីរស្រឡាញ់គ្នាហើយឬនៅ ?...»

ប្រុសកម្លោះ ឆ្លើយដ៏គួរឱ្យទុកចិត្ត ÷

-«ចាស់ៗគាត់រហ័សដឹងណាស់ អីចឹងហើយបានជាថ្ងៃនេះគាត់អនុញ្ញាតឱ្យបងយកឡានមកបើកបញ្ជិះអូនដើរលេង !..... ហើយអាទិត្យក្រោយៗ បើអូនទំនេរ បងនឹងនាំអូនទៅលេងសេកសកពេជ្រចិន្តា និងទៅដល់ប៉ៃលិនទៀត !...»

-«ហ៊ី... គួរឱ្យសប្បាយណាស់ គ្រាន់តែឮបងនិយាយ !...»

ក្រោយមក សុផលក៏បាននាំយុវនារី ទៅដល់ខ្ទមឈើមួយរបស់អ្នកចាំចំការ ហើយគេនាំនាងចូលអង្គុយលេងនៅទីនោះ ។ ឆោមនារី ដកក្រដាស់ចំរៀងចេញមកបង្ហាញដោយសួរសុផលបណ្តើរ ÷

-«បង បង្ហាត់អូនច្រៀងបន្តិចម៉ោ តែ !... ខ្ញុំមើលទៅទំនុក

ច្រៀងនេះ ដូចជាខុសពីបទស្នឹងសម្ងាត់នោះ ចុះម៉េចក៏យ៉ាងហ្នឹងបង ?...»

យុវបុរសសើចតិចៗ ទើបនិយាយ ÷

-«ព្រោះបទនោះ លែងសម្ងាត់ទៅហើយ តាំងពីក្រោយល្ខោនសំដែងហើយ មានគេពីងឮច្រើនគ្នា !... ទើបបងតែងទំនុកច្រៀងថ្មី សំរាប់រឿងយើងនេះវិញ ហើយបទនេះ ទើបមានឈ្មោះថាស្នឹងសម្ងាត់មែន ព្រោះគ្មានអ្នកណាពឹង ក្រៅពីយើងពីរនាក់នេះទេ ! »

-«បងប៉ិនប្រសប់ណាស់ មើលបងច្រៀងឱ្យអូនស្ដាប់មើល៍ តើពិរោះយ៉ាងណាទៅ ?...»

ដោយស្មោះស្ម័គ្រចំពោះប្រុសស្នេហ៍ រំដួលព្រែកហ្លួងអង្គុយយ៉ាងប្រកៀកប្រកិត ជិតជាប់ខ្លួនប្រុសកម្លោះ ដើម្បីចាំស្ដាប់គេច្រៀងដែលមានសម្លេងរងុំៗដូចតទៅ ÷

- បងជួយចាប់ត្រី ឱ្យស្រីតួចតន់
  នាពេលសាយណ្ហ មាត់ស្ទឹងសង្កែ
  បងតើបពីទឹក ចិត្តនឹកដល់ស្នេហ៍
  និស្ស័យបុព្វេ មាសមេជួបបង ។
- បងសិស្សសាលាព្រះមុនីវង្ស
  ស្រីស្រស់ជំទង់រំដួលព្រែកហ្លួង
  ផ្កាថ្ពរកេសា រំយ៉ាដក់ភ្លួង
  ស្រីខ្មែរទាំងពួងល្អពុំស្មើអូន ។

- បងរៀនតែងកាព្យស្នងស្នាបចិត្តស្រី
រ៉ម្លួលប្រណីឱ្យបងគោងក្បួន
បងធ្វើសំនៀងច្រៀងបំពេរអូន
សណ្ដោងសណ្ដួនលើក្បួនវាសនា ។
- ជាតិនេះស្ម័ក្ស័យដើម្បីស្រីរតន៍
សូមស្នឹងសម្ងាត់ជួយកត់វាចា
ខ្ទមអន្ទង់វិលកុំមន្ទិលថា
បងជាភ្ញមរាក្សត់ផ្កាសោះឡើយ ។

រ៉ម្លួល បណ្ដែតអារម្មណ៍អស់មួយសន្ទុះ ទៅតាមរលកសំលេងលើកដាក់លោកញាក់ញ័ររបស់សិស្សវិទ្យាល័យ ហើយវាចាភ្លាមឡើងនៅពេលចំរៀងចប់ ៖

-«ព្រះអើយ បងច្រៀងពិរោះប៉ុណ្ណឹងហើយ ម៉េចក៏ចាំបាច់ឱ្យគេច្រៀងជំនួសទៀត ! ហើយទំនុកបទនេះថ្លែងចំរៀងយើងទាំងពីរតែម្ដង បងបំជាប៉ិនប្រសប់មែន !...»

-«តែបងច្រៀងពិរោះ ឬប៉ិនប្រសប់នេះ សំរាប់តែអូនរ៉ម្លួលម្នាក់ប៉ុណ្ណោះ !... ឥឡូវ និយាយគ្នាសិន បើបងបង្ហាត់ច្រៀង តើអូនបានអ្វីឱ្យបងជារង្វាន់ ?...»

រ៉ម្លួលព្រែកហ្លួង ហេតុតែមានចិត្តស្រឡាញ់គេលើសលប់ ក៏ភ្លេចកេរ្តិ៍ខ្មាស់អស់លើង ហើយហុចថ្ពាល់ទៅឱ្យយុវបុរស វាចាដោយធ្វើ

ភ្អែកព្រិមៗថា ÷

-«អូនគ្មានអ្វីឱ្យបងទេ មានតែ... នេះនែ៎ !...»

សុផល ហាក់ដូចជារង់ចាំឱកាសនេះយូរហើយ ក៏ចាប់ក្រសោបអោបថើបនាងភ្លាម ហើយថើបតាំងពីកញ្ចឹងក គុម្ពត្រចៀក បបូរមាត់ ត្រាតែធ្វើឱ្យបូផាស្រស់ខ្ចី ព្រឺព្រួចស្ទើរផុតវិញ្ញាណ ។

មួយសន្ទុះ ទើបនាងប្រឡេះដៃបុរសចេញ ហើយថ្ងូរពណ្ដំ ÷

-«...បង ! បានហើយ.... ប្រយ័ត្នគេឃើញ !... អីក៏រហ័សម្ល៉េះ មិនទាន់ចូលដណ្ដឹងខ្ញុំផង... ធ្វើអីចឹងក្រែង...មិនសមណាំ ! »

សុផល នៅតែប្រនៀលច្រមុះ លើថ្ពាល់ដ៏រលោងរបស់ឆោមទេវីមិនទាន់ដកចេញភ្លាមៗឡើយ ដោយរលាស់បបូរមាត់បពេភ្ពីរ ÷

-«បងមុខជាចូលដណ្ដឹងឆាប់ៗនេះហើយ អូនកុំបារម្ភ !... ហើយពេលនេះគ្មានអ្នកណាឃើញទេ...! បងរបស់អូនក៏គាត់ពេញចិត្តឱ្យបងបង្ហាត់ចម្រៀងអូនដែរ !...»

ក្រមុំជនបទមុខក្រហមព្រឿងៗ ដោយអារម្មណ៍រំភើបស្រើបស្រៀវ ព្រោះទើបបានត្រូវប្រុសកម្លោះអោបរឹតជាលើកដំបូង ÷

-«គាត់ឱ្យតែបង្ហាត់ច្រៀងទេតើ !... មិនមែនឱ្យបង្ហាត់អី... អី.. ចឹង... ទេ !...»

សុផល ដកច្រមុះចេញ ហើយធ្វើបួកជាងឿកងបន្តិច ÷

-«ចុះក្នុងសំបុត្រអូនថា ព្រមស្រឡាញ់បងនោះ គ្រាន់តែប៉ុណ្ណឹង មានទាស់ខុសអី ឬមួយអូនមានគូបញ្ចាំចិត្តរួចហើយ ?..»

ឃើញអាកាវៈមាយារបស់យុវបុរស បូផាស្រស់ខ្ចីក៏ប្រញាប់ឆ្លើយ

គាត់ភ្លាម ÷

-« អូនគ្មានគូកំណាន់បញ្ចាំបិត្តឯណាទេ បើទុកជាមានគេស្តី ដណ្តឹងអូនមុន ក៏អូនមិនព្រមដែរ ព្រោះអូនស្រឡាញ់តែបងម្នាក់! »

-« បើស្រឡាញ់តែបង ចុះគ្រាន់តែប៉ុណ្ណឹង អីក៏កំណាញ់ម៉្លេះ បងមិនទាន់ធ្វើអ្វី ឱ្យហួសឯណា !...»

យុវបុរសធ្វើជាញញឹមវិញ ហើយចាប់បន្ទឹសាជាថ្មី ÷

-« អីចឹង ចាំស្តាប់បង ច្រៀងមួយឃ្លាម្តងៗ ហើយអូនចាំ ច្រៀងតាមបងណាំ !...»

ធោមនរីងក់ក្បាលដោយអារម្មណ៍អន្ទះសា ព្រោះនៅពេលដែល សុផលច្រៀងមួយឃ្លាៗ ដើម្បីឱ្យនាងច្រៀងតាម ដៃម្ខាងរបស់គេ ដែលសល់ពីកាន់ក្រដាស់ចំរៀងនោះ បានចាប់ផ្តើមមានសកម្មភាព រស់រវើកឡើងទៀត ។

សុផល ហាក់ដូចជាយល់ថា ពេលនេះមិនត្រូវបណ្តោយឱ្យរស ជាតិជីវិតយុវវ័យរបស់គេ រំលងចោលទៅដោយគ្មានប្រយោជន៍នោះ ឡើយ ព្រោះវាទុកដូចជាឱកាសល្អបំផុត ដែលត្រូវតែគេសាកល្បង បំពេញអារម្មណ៍ត្រេកត្រអាលពីធម្មជាតិរបស់គេ ដែលពីយូរណាស់ មកហើយ គេមិនធ្លាប់ជួបប្រទះសោះនោះ ។

ចំណែកបុត្រីមីងន្ទួន ហេតុតែស្រឡាញ់គេពេក ក៏នឹកខ្លាចគេខឹង ម្តងនេះ ទោះបីជាប្រុសកម្លោះប្រើដៃរាវច្រចាច់អ្វីក៏ដោយ នាងសម្ងំ ស្ងៀមមិនហ៊ានរើបំរះឡើយ ។ ឃើញស្រីតូចនៅស្ងៀម ប្រៀបដូចជា កូនកណ្តុរសម្ងំនៅក្រោមក្រញាំជើងខ្លែង សុផលកាន់តែបានចិត្ត ។

ទន្ទឹមនឹងមាត់ច្រៀងយឺតៗ ឱ្យនាងច្រៀងតាម គេក៏វារប្រពាច់សុដន់ដ៏ក្រពុំរបស់នាងពីក្រៅអាវស្តើរបែកខ្នង ហើយមិនអស់ចិត្តក៏លូកវារចូលទៅប្រពាច់ក្នុងអាវទ្រនាប់ទៀត ធ្វើឱ្យយុវនារីកាន់តែស្រៀវស្រើប ស្ទើរស្ទះខ្យល់ដកដង្ហើម ។

មាត់នាងដែលច្រៀងតាមចំនុករបស់ប្រុសកម្លោះនោះ បានច្បាស់តែប៉ុន្មានឃ្លាមុនដំបូងប៉ុណ្ណោះ ក្រោយដែលត្រូវបុរសប្រើដៃវារប្រចាច់បពោសអង្អែលកាន់តែខ្លាំង នាងក៏ច្រៀងលែងកើត គឺបានត្រឹមតែធ្វើមាត់ម្លុបៗ ដូចត្រីកំភ្លាញឡើងយកទឹកតែប៉ុណ្ណោះ ឯភ្នែកក៏ស្រឹងដូចមនុស្សត្រូវថ្នាំសណ្តំជិតដេកលក់ ។

ក្រោមជំនោរខ្យល់ នៅចុងចំការត្នោតពេលរសៀល រំដួលត្រូវម្រាមដៃប្រុសកម្លោះ លូកវារហូតមកដល់ក្បាលពោះ និងបង្អួសចុះមកដល់ត្រលែងសេកមាស ដែលអមដោយផ្ការភ្នំ លាតសន្ធឹងចាំងលង្វែកព្រៃដីទួលទំនាប ដុះរៀងរាបដោយស្មៅចិញ្ចៀនទន់ល្មួតល្មើយ។

នៅពេលនោះ គេហាក់ដូចជាលែងឮអោមនារីថាតាមពាក្យចំនុកទៀតហើយ គឺនាងប្រែជាថ្ងូររណ្តំដូចព្រាបទេវិញ រហូតដល់របូតដៃជ្រុះក្រដាស់ចំរៀងទៅដី ។ ឯសុភេកាន់តែរាងព្រហើន ក៏សង្កត់ផ្តួលខ្លួននាងទៅលើរនាបរានឬស្សី ដើម្បីត្រៀមបើករណសិរ្សថ្មីវាយលុកសមរភូមិក្តៅ ។

ប៉ុន្តែ នៅពេលដែលបុត្រីមីងទួត ត្រូវរលកតណ្ហាបោកបក់ស្ទើរលិចបាត់ទៅក្នុងមហាសមុទ្ររាគីនោះ ស្រាប់តែមានផ្លែដូងជ្រុះលើបន្ទះស័ង្កសីមួយបន្ទះ ដែលប្រក់នៅចុងខ្ទម ឮស្នូរផាំង ! ដូចស្នូរកាំភ្លើង

ផ្ទុះ ធ្វើឱ្យឆោមទេវីភ្ញាក់ក្រញ៉ាង ប្រមូលស្មារតីឡើងវិញ ហើយច្រានទ្រូងយុវជនចេញយ៉ាងរហ័ស ÷

-« ឈប់សិន !... ធើអី...អីចឹងទេ ប្រយ័ត្នបងខ្ញុំឃើញណា! »

ថាហើយ នាងក៏ស្ទុះក្រោកអង្គុយភ្លាម ដោយរៀបចំសំពត់អាវឱ្យមានរបៀបរៀបរយឡើងវិញ ÷

-« អ៊ូយ ខ្ញុំខំតែភ័យ !... ស្មានតែអ្នកណាមកបាញ់អី ! លោះព្រលឹងអស់រលីង !... ចុះបងភ័យទេ ?...»

សុផល បន្ទរដង្ហើមបន្តិច ទើបពោលកំឡាចិត្ត ÷

-«ភ័យអី !... បើបងធ្លាប់ដឹងច្រើនដងមកហើយ គ្រាន់តែមានការសោកស្ដាយ.....!»

ឆោមកល្យាណី សម្លក់ប្រុសកម្លោះដោយខ្នាញ់ ÷

-« អស់បានបេះប្រៀងហើយ.... រវល់តែ...! »

ម្ដងនេះ សុផលប្រាស់ខ្លួនដេកទៅលើរនាបវិញ ហើយទាញខ្លួនឆោមនារីឱ្យដេកនៅក្បែរ ដោយពោលបណ្ដើរ ÷

-« ...រៀនប្រៀងដេកក៏បានដែរ មិនបាច់អង្គុយទេ នាំតែពិបាកមើលអ្វីជ្រុះមិនឃើញ !...»

ដោយពិតនោះ រំដួលមិនត្រឹមតែស្រឡាញ់គេក្រុល និងខ្លាចគេខឹងប៉ុណ្ណោះទេ ថែមទាំងនាងចង់ឱ្យគេបបោសអង្អែលដែរ ។ ថ្វីបើនាងបានដឹងអស់ពីក្រិត្យច្បាប់ស្រី និងវិន័យប្រពៃណីខ្មែរ ប៉ុន្តែច្បាប់ធម្មជាតិមានថាមពលខ្លាំងជាង ។ ពេលដែលនាងស្រឡាញ់គេលើសលប់យ៉ាងនេះហើយ នាងពិតជាចង់ដឹង តើរសជាតិស្នេហានោះ រាំ

ដូចពាក្យគេនិយាយមែន ឬមិនមែន... ? តើនាងគួរបណ្តោយខ្លួនឱ្យគេសាកល្បងឱ្យស្រេចនៅពេលនោះ ឬយ៉ាងណា ? ឬមួយក៏បានសុខតែមួយភ្លែត មានផលវិបាកទៅថ្ងៃក្រោយ ? ។

នៅពេលដែល បូផាដងស្ទឹងរំពឹងគិតមិនដាច់ស្រេច ប្រៀបដូចទូកនៅកណ្តាលទន្លេនេះ ស្រាប់តែសុផលចាប់ក្រសោបអោបថើបនាងសាជាថ្មី ដោយយកដើមទ្រូងទ្រោបសង្កត់ពីលើនាងជាប់ ។

ឆោមនិមល ព្យាយាមរើបំរះតិចៗ ព្រោះមិនទាន់ច្បាស់លាស់ក្នុងចិត្ត ហើយខំរាំថា ÷

-« បងសុផល.... កុំធ្វើអីចឹង !...»

ប្រុសកម្លោះ មិនស្តាប់ក៏ចាប់ប្រយាចំដោះនាងទៀត ហើយសើយសំពត់នាងយឺតៗ ដោយខ្សឹបដាក់ត្រចៀកនាងទៀតថា ÷

-« រំដួល បងស្រឡាញ់អូនណាស់ ! ចុះអូនមានស្រឡាញ់បងទេ ?...»

យុវនារី ខំឆ្លើយមកវិញដោយរំភើបចិត្ត ÷

-« បើអូនមិនស្រឡាញ់ មិនមែនអូនឱ្យបងអោបថើបយ៉ាងនេះទេ!»

-« ពេលនេះ បងទ្រាំនឹងសម្រស់អូនមិនបានទេ នៅឱ្យស្ងៀមកុំរើបំរះណា៎ បងនឹងនាំអូន... ឡើងស្ថានសួគ៌ ដែលជាសេចក្តីសុខពិតរបស់ជីវិតមនុស្សលោកត្រូវការ !...»

-« អូនចង់បានសេចក្តីសុខជាមួយបងណាស់ !... ប៉ុន្តែអូនខ្លាច !.... គេ...ថា ស្លែបហើយ មុខជាមានកូនណា៎ បើមានកូនម្តាយអូនគាត់ពិបាកចិត្តស្លាប់ហើយ !.. បងកុំអាល...អីង !..»

-«អូនកុំភ័យ...! ផ្ទះបងលក់ថ្នាំពេទ្យ !... មានថ្នាំគ្រប់ !... ថ្នាំទប់មិនឱ្យមានកូន ក៏មានដែរ... អូនកុំភ័យ !... ចាំត្រឡប់ទៅវិញ បងនឹងឱ្យអូនលេប !... នៅឱ្យស្ងៀមណា !...»

-«បង ! និយាយយ៉ាងនេះ អូន... ដូចជាវង្វេងវង្វាន់អស់ហើយ !... បង !... បង !...»

នៅពេលដែលរំដួលខំប្រកែកយ៉ាងស្រាលៗនោះ ដៃរបស់សុផលបានលូកដល់ខោស្ទីបរបស់នាងទៅហើយ គេប្រញាប់ញីអង្អែលទួលពោធិមួយសន្ទុះ ទើបទាញខោនោះចុះក្រោមយ៉ាងរហ័ស !...។

ប៉ុន្តែ នៅពេលដែលតួឯកល្ខោនរឿងស្នឹងសម្ងាត់ រៀបនឹងសំរេចបំណងដ៏ស្រេកឃ្លាននោះ ស្រាប់តែឮសូរសម្លេងនាងឡឹង លាន់ឮមកពីចម្ងាយ ÷

-«រំដួល !... អឺ... រំដួល...! ល្ងាច ល្មមត្រឡប់ទៅវិញហើយ !...បងប្រញាប់ទៅស្នាក់ទូកបន្ទែ...ផង !...»

គ្រាន់តែឮសម្លេងនាងឡឹង រំដួលក៏ភ្ញាក់កន្ត្រាក់ស្លុតចិត្ត ខំស្រវារទាញខោស្ទីបមកស្លៀកវិញ ធ្វើឱ្យសុផលរាងខកចិត្តជាខ្លាំង ហើយរសាយចេញពីគ្នាភ្លាម ។.....

...ស្នេហាកញ្ចក់កណ្តៀត នៅក្នុងខ្ទមចុងចំការក្រូចអន្ទង់វិលមិនបានបង្កើតអនុសាវរីយ៍មត្រជាក់ ឱ្យបេះដូងយុវវ័យទាំងគូចប់ចុងចប់ដើមឡើយ ប៉ុន្តែគេខំទប់ចិត្តយ៉ាងនឹងនរ នៅពេលវិលត្រឡប់មកផ្ទះវិញ ដោយបានសម្ងំលាក់ក្នុងបេះដូងយ៉ាងសម្ងាត់រៀងខ្លួន មិនឱ្យអ្នកណាដឹងទាល់តែសោះ ។

ចាប់ពីថ្ងៃនោះមក ប្រមាណមួយអាទិត្យ សុផលមិនដែលចុះមកមុជទឹកដូចមុនទៀតទេ ។ ប្រហែលគេរៀនខ្លាសរំជួល ឬមួយក៏ក្អក់ខ្នាញ់ខឹងមាយា ព្រោះមិនបានសំរេចបំណងតណ្ហានោះក៏មិនដឹង ។ ចំណែកបុប្ផាព្រែកហ្លួងវិញ ទោះបីជាដឹងថា អំពើដែលសុផលធ្វើទាំងប៉ុន្មានមកលើនាង កន្លងមកថ្មីៗនេះ ជាការខុសឆ្គងចំពោះសីលធម៌ប្រពៃណីខ្មែរក៏ដោយ ក៏នាងមិនហ៊ានបន្ទោសគេធ្ងន់ធ្ងរដែរ ព្រោះនាងខ្លាចគេមិនស្រឡាញ់វិញ ។

ទោះបីយ៉ាងនេះក្ដី កម្លោះក្រមុំទាំងពីរនៅតែលួចធ្វើសំបុត្រចុះឡើង តាមរយៈនាងសំ ដើម្បីថែរក្សាពន្លកស្នេហាយុវវ័យនោះ មិនឱ្យស្លោកស្រពោនទៅវិញបានឡើយ ។

ជួនជាពេលដែលស្រស់ស្រីកំពុងតែនឹកព្រួចៗ គួចគិតទៅដល់សិស្សវិទ្យាល័យព្រះមុនីវង្សនោះ ថ្ងៃនេះពេលដែលបងស្រីនាងទៅលក់ដូរផុត នាងឃើញព្រិន្ទបាលឯកចំណាន ជិះសេះមកឈប់នៅក្រោមដើមអំពិលត្រើយម្ខាង ហើយដើរឆ្លងស្ពានមករកជួបនាងទៀត។

ចំណាន មកពេលនេះ គឺមកផ្ដល់ដំណឹងថា មេចោរត្រឡៃដែលតាំងខ្លួនជាមេឥស្សរៈស្នេហាជាតិនោះ បានសុំចុះចូលសារភាពហើយ តែមិនចូលមកតាមអង្គភាពទ័ពគេទេ គឺចូលទៅតាមរយៈរដ្ឋអំណាចស្រុកសង្កែទៅវិញ ។

ចំណាន បានបញ្ជាក់បន្ថែមថា តាមមើលទៅអាត្រឡៃ ប្រហែលនឹងចូលមកដណ្ដឹងនាងក្នុងពេលឆាប់ៗ ដូច្នេះគេមិនអាចបង្អង់បានទេ គេត្រូវតែរៀបចំមកស្ដីដណ្ដឹងនាងឱ្យបានមុននាយត្រឡៃនោះ សូម

នាងទទួលពាក្យគេកុំប្រកែកឱ្យសោះ ! ។

ក្រោយដែលបានទទួលពត៌មានដូច្នោះ រំដួលមានក្តីបារម្ភជាខ្លាំង ទើបនិយាយយ៉ាងខ្ជីថា ÷

-«ខ្ញុំថា សុំកាន់ទុក្ខឪពុកខ្ញុំបានបីខែសិន ម៉េចក៏លោកប្រញាប់ម្ល៉េះ ?...»

ព្រិន្ទបាលឯក ឆ្លើយកាត់ ÷

-«មិនប្រញាប់...មិនបានទេ !... ព្រោះមានគេចង់ប្រជែង! »

ពោលតែត្រឹមណោះ នាយទាហាននេះក៏ត្រឡប់ទៅវិញយ៉ាងលឿន រកតែរំដួលនិយាយអ្វីទៀតក៏មិនទាន់ ។

ក្រោយនោះ បុត្រីមឹងនួនក៏សរសេរសំបុត្រមួយ ផ្ញើតាមនាងសំឱ្យយកទៅឱ្យសុផល ក្នុងន័យចង់ឱ្យសុផលមកជួបនាង ដើម្បីនិយាយពីរឿង សុំឱ្យគេចូលស្តីដណ្តឹងនាងក្នុងពេលឆាប់បំផុត ឱ្យបានមុនបុរសទាំងពីរ ដែលនាងមិនស្រឡាញ់នោះ ។

ប៉ុន្តែ ពីរបីថ្ងៃកន្លងទៅ តាំងពីទឹកស្រកល្មមៗ រហូតស្រកដល់បាតស្ទឹង ក៏មិនឃើញសុផលចុះមករកនាងឡើយ សូម្បីតែសំបុត្រក៏មិនឃើញតបត្រឡប់មកវិញដែរ ។

ស្ទឹងសង្កែ ពេលរដូវទឹកស្រកមែនទែន ទំហំផ្ទៃទឹកកាន់តែរួញតូចទៅ នៅតែមួយប្រឡោះកណ្តាល សំរាប់ឱ្យទូកធ្វើដំណើរចុះឡើងប៉ុណ្ណោះ តែមិនអាចចែវបានទេ គឺបានតែអុំនិងរុញ ព្រោះទីណាក៏មើលឃើញតែវាលខ្សាច់រកេតរកូត ដែលពួកអ្នកនៅទូកទាំងប៉ុន្មានតែងនាំគ្នាលើកទូកដាក់លើបង្គង ដើម្បីផ្លុសជុលឬកោសលាបជ័រពរ

ពាសសាជាថ្មី ។

ក្នុងស្ថានភាពដូច្នេះ ពួកអ្នកចុះមកមុជទឹក ឬបោកគក់ខោអាវ តែងតែនាំគ្នាទៅមុខនៅឯកណ្ដាលវិញ មិនតែប៉ុណ្ណោះ គេតែងនាំគ្នាយកក្អម ឬថ្លាងចោះប្រហោង ទៅកាយបង្កប់ក្នុងខ្សាច់ ដើម្បីច្រោះចំរាញ់យកទឹកត្រជាក់បរិសុទ្ធ សំរាប់ប្រើប្រាស់ផ្សេងៗទៀតផង ។

ជួនជាថ្ងៃដន្យ យប់នោះ នាងឡឹងបានទៅស្នាក់ទូកឪឡឹក ដើម្បីទិញទុកលក់ព្រឹក នៅឯមុខមន្ទីរពេទ្យខេត្តជាមួយក្មួនប្រុសច្បង តាំងពីក្បាលព្រលប់ ទុកតែក្មួនពៅឱ្យនៅកំដរនាងរំដួល ក្នុងទូកដែលចិតលើបង្គង ។

ប្រមាណជាម៉ោង ១០ យប់ស្ងាត់ជ្រៀប នៅក្នុងលង្វែកដងស្ទឹង នាងឡឹងមិនទាន់ត្រឡប់មកវិញនៅឡើយ ។ ពេលនោះ នាងរំដួលដេកមើលសៀវភៅរឿងព្រេងនិទាន នៅមិនឆ្ងាយពីកុមារភី ដែលទើបបិទសៀវភៅរៀនស្ងាបហិមៗ បិទភ្នែកដេកសន្សឹមៗ ដោយអាការៈងោកងុយ ។

បន្តិចនោះ ឮស្នូរដូចជាជើងមនុស្សដើរក្បែរទូក ហើយបោះរមូរក្រដាសតូចមួយទៅក្បែរចង្កៀងប្រេងកាត ។ រំដួលភ្ញាក់ព្រើត ចាប់រមូរក្រដាស់នេះលាតអានជាបន្ទាន់ ព្រោះនាងនឹកភ្នកសង្ស័យភ្លាមថាពិតជារបស់សុផល ÷

រំដួល !... ប៉ុន្មានថ្ងៃនេះ បងរវល់ពេក មិនបានចុះមករកអូន !... អូនកុំខឹងអី !.... បងនៅតែនឹកដល់អូនជានិច្ច !

សូមអូនចុះទៅជួបបង នៅឯមាត់ទឹកកណ្ដាលស្ទឹង ក្នុងពេលឥឡូវនេះជាប្រញាប់ ដើម្បីបងចង់ប្រាប់អូនពីរឿងចូលស្ដីដណ្ដឹង !!

កុំភ្លេច ! ឱ្យសោះ ! បងរង់ចាំ !

**សុផល**

គ្រាន់តែយល់អត្ថន័យ ក្នុងកូនសំបុត្រនេះពេលណា រំដួលក៏រំភើបត្រេកអរពន់ពេក ហើយប្រញាប់លបៗចុះពីទូកទៅភ្លាម ក្រោយដែលមើលទៅ ឃើញកុមារីកំពុងដេកលក់ស៊ប់ ។

នាងបោះជំហានយ៉ាងលឿន ក្រោមស្រមោលព្រះច័ន្ទ ១២កើតលើផ្ទៃខ្សាច់សើមៗ បានទៅជួបនឹងយុវបុរសកំពូលស្នេហ៍ ដែលកំពុងឈរចាំនៅក្បែរទូកលាតមួយ ចិតលើបង្គងអែបមាត់ទឹក ដែលចោលទទេគ្មានមនុស្សនៅ ប្រៀបដូចជាជញ្ជាំងបាំង មិនឱ្យអ្នកណាឃើញឡើយ ។

បរិយាកាសរាត្រី មិនជាងងឹតប៉ុន្មានទេ ព្រោះរស្មីព្រះច័ន្ទដែលឆ្លុះស្រមោលទៅក្នុងខ្សែទឹក បានជះពន្លឺមកវិញ ធ្វើឱ្យកម្លោះក្រមុំទាំងពីរ បានឃើញគ្នាច្បាស់ ហើយស្ទុះរត់រកគ្នាស្រវាំរអោបរិត កៀកកើយ ថើបជញ្ជក់យ៉ាងត្រេកត្រអាលស្ងួរឈាម ក្រោយពីបានដង្ហោយស្រែកហៅគ្នាតិចៗ តាំងពីចម្ងាយ ៖

-« រំដួល... អូន !...»

-« បង.... សុផល... អូន...នឹកបងណាស់ !...»

លុះអោបរិតគ្នាស្ទើររលាយសាច់មួយ អស់មួយសន្ទុះមក ទើប សុផលងើបមុខឡើង និយាយថា ÷

-«បងក៏នឹកអូនណាស់ដែរ តែប៉ុន្មានថ្ងៃនេះ រវល់អង្វរឪពុកម្ដាយបងខ្លាំងណាស់ !... គឺបីថ្ងៃទៀត គាត់ព្រមចូលស្ដីដណ្ដឹងអូនហើយ !...»

វ៉ុល្លល ចើបថ្ពាល់សង្សារបណ្ដើរ ហើយបន្លឺដោយអររខិបរខុប ÷

-«ឱ !...អូនត្រេកអរណាស់បង !... ព្រោះអូនមិនចង់ឱ្យអ្នកដទៃចូលមកស្ដីដណ្ដឹងអូនមុនបងទេ !...»

នៅក្នុងរង្វង់ដៃចាក់ស្រេះដដែល សុផលនិយាយហាក់ដូចជាអន្ទះអន្ទែងខ្លាំងណាស់ ÷

-«អូនកុំភ័យ !.. បងថាម៉េច គឺអីចឹងហើយ !.. អូនវ៉ុល្លល តើអូនភ្លេចរឿងនៅខ្ទមចុងចំការក្រូចនោះហើយនៅ ?...»

មាណវីតបដោយរំភើបចិត្ត ÷

-«...មិនទាន់ភ្លេចទេបង !...»

យុវបុរស ខ្សិបដាក់ត្រចៀកនាងទៀតថា ÷

-«...បើមិនទាន់ភ្លេច !... នេះនែ៎ !... បងយកថ្នាំការពារនេះមកឱ្យអូន !... កាលណារួចហើយត្រឡប់ទៅវិញ អូនលេបចុះការពារប៉ុន្មានដងក៏មិនមានកូនដែរ អូនកុំភ័យ !!...»

វ៉ុល្លល ទទួលយកកញ្ចប់ថ្នាំតូចទៅដាក់ក្នុងហោប៉ៅអាវ ប្រុងនឹងហាមាត់និយាយអ្វីបន្ថែមទៀត។ ប៉ុន្តែ និយាយមិនទាន់ផង សុផលក៏ចាប់ផ្ដួលនាងភ្លាម ទៅលើភួយដែលក្រាលលើខ្សាច់ ត្រៀមរួចជា

ស្រេប ។...

ពេលនោះ ទោះជាបុត្រីមីងនួន ចង់ការពារព្រហ្មចារីយ៍ ដែលមានតម្លៃស្មើជីវិត ឱ្យបានល្អបរិសុទ្ធសំរាប់ដល់ពេលរៀបមង្គលការយ៉ាងណាក៏ដោយ ក៏នាងគ្មានលទ្ធភាពនឹងរារាំងដែរ ព្រោះពេលនោះអាការៈរបស់សុផល មិនខុសពីព្រាននារីប៉ុន្មានទេ ហើយគួបផ្សំខ្លួននាងក៏ត្រេកត្រអាល ពុះកញ្ជ្រោលរោលរាលដោយភ្លើងតណ្ហាខ្លាំងក្លា មិនអាចទប់ចិត្តបានផងនោះ នាងក៏បណ្តោយខ្លួនឱ្យសុផល ធ្វើអ្វីតាមចំណង់ចិត្ត ។

នៅក្នុងជ្រលងដងស្ទឹងដ៏សែនស្ងាត់ ស្តេចនាគចម្លែកមួយដ៏មានរោមស្រម៉ូវ បានលូនចូលសន្សឹមៗ... រហូតទៅដល់កណ្តាលកោះកេរ្តិ៍ទេពនិម្មិត បង្កើតជាព្យុះភ្លៀងបោកបក់រលកផ្ទប់ច្រាំង ហើយស្រូបឆក់យកព្រលឹងធីតាម្ចាស់កោះកែវ ឱ្យហោះអណ្តែតត្រសែត.... រហូតទៅដល់ឋានសួគ៌ ៧ជាន់ ដែលជាទីបញ្ចប់នៃសុបិនកាមកិលេសដ៏តក្កលាហល ។

គ្រានោះ ក្រៅតែពីជំនោរខ្យល់ពេលរាត្រី និងខ្សែទឹកសម្ងាត់នៃដងស្ទឹងសង្កែ ប្រហែលជាគ្មានអ្នកណាដឹងពីវាសនារបស់បុប្ផាព្រៃកហ្លួង ដែលកន្លងមកធ្លាប់មានគេកោតសរសើរស្ញើរគ្រប់មាត់ថា ជាកុលធីតាប្រកបដោយគន្លងធម៌ល្អប្រពៃនោះ ត្រូវធ្លាក់ក្នុងចង្កូមគ្រចាក់ខាំទំពាររបស់កម្លោះចិត្តព្រើល ដល់កំរិតណាទេ ។ គេគ្មានឮអ្វីក្រៅតែពីដង្ហើមថ្ងូររណ្តំរបស់នាង និងសម្លេងអង្វរខ្សាវៗ នៅក្បែរត្រចៀកបុរសថា ៖

-« បងសុផល !... អ្វីៗអូនបានប្រគល់ជូនបងហើយ សូមបង កុំបំភ្លេចអូនឱ្យសោះ !..»

យុវបុរស ដែលទើបបានស្តាប់ស្តាប់ស្រងល់ក្នុងចិត្តនោះ យក ចុងអណ្តាតលិទ្ធគុម្ពត្រចៀកនាងស្រាលៗ ព្រមដោយពាក្យលួងលោម ដ៏ផ្អែមត្រជាក់ថា ÷

-« ជាតិនេះស្ស៊ូក្ស័យដើម្បីស្រីរតន៍ សូមស្នឹងសម្ងាត់ជួយកត់វាចា ខ្ញុំមអន្ទងវិលកុំមន្ទិលថា បងជាភ្ញមរាក្សត់ផ្កាសោះឡើយ !..»

វិរៈ ដែលទើបងើបពីសន្ទប់កណ្តាលព្យុះតណ្ហានោះ កាលបើឮ ពាក្យដ៏ផ្អែមល្ហែមនេះទៀត នាងស្ទើរតែមិនដាច់ចិត្តក្រោកចេញពី ក្រោមលង្វែកទ្រូងប្រុសស្នេហ៍ពេលនោះឡើយ ប៉ុន្តែជួនជានៅអាត់ កំពង់ត្រើយម្ខាង មិនជាឆ្ងាយប៉ុន្មាន មានស្រមោលមនុស្សចុះមកមុជ ទឹក សុផលនិងវិរៈខ្លាចគេឃើញ ក៏ម៉្នម្នាប្រឡេះដៃចេញពីគ្នាភ្លាម ប៉ុន្តែមុននឹងបែកទៅ វិរៈឆ្លៀតអង្វរប្រុសកម្លោះទៀតថា ÷

-« បងសុផល... កុំភ្លេច ! អូន...ឱ្យ...សោះ !...»

សុផល អោនថើបសង្សារជាគ្រាបឆ្លើយ ÷

-« បទចំរៀងស្នឹងសម្ងាត់ បញ្ជាក់ប្រាប់អូនហើយតើ អូននៅ ភ័យអីទៀត ?...»

...**យប់**នោះ ជាយប់ដ៏មានរសជាតិបំផុតសំរាប់ជីវិតជាស្រីក្រមុំ របស់នាងវិរៈ ដែលធ្វើឱ្យនាងយល់សប្តិឃ្លើតទល់ភ្លឺ... ។

✻

✻ ✻

# ៧

## កុំជឿចិត្តប្រុស !

**បី**ថ្ងៃក្រោយ មិនឃើញឪពុកម្តាយសុផលចូលមកស្តីដណ្តឹងរំដួលដូចពាក្យអះអាងរបស់យុវជននេះឡើយ ។ ប៉ុន្តែនៅយប់នោះ សុផលបានធៀតមកណាត់ពេលជួបជាមួយរំដួល នៅមាត់ស្ទឹងសម្ងាត់នោះទៀត ដោយបញ្ជាក់ប្រាប់ពីហេតុដែលឪពុកម្តាយគេមិនបានចូលមកតាមថ្ងៃសន្យានេះ មកពីហោរាទស្សន៍ទាយថា ថ្ងៃនេះជាថ្ងៃជ័យបូករាសីមិនល្អ ។

ឥឡូវ សុផលបានកំណត់សាជាថ្មី ជាក់លាក់ថា គឺមួយអាទិត្យទៀត ឪពុកម្តាយគេនឹងចូលមកមែនទែនហើយ សូមកុំឱ្យរំដួលព្រួយបារម្ភឱ្យសោះ ។

បុត្រីមីងនួន គ្មានរង្កៀសចិត្តឬមន្ទិលសង្ស័យអ្វីឡើយ ព្រោះអាកប្បកិរិយា ទឹកមុខ និងពាក្យពេចន៍ដែលសុផលនិយាយទាំងប៉ុន្មានគួរឱ្យទុកចិត្តពន់ពេកណាស់ មិនតែប៉ុណ្ណោះ នៅពេលយុវបុរសនេះសុំសាងសេចក្តីសុខជាមួយនាងជាលើកទីពីរ នាងក៏ព្រមប្រគល់ខ្លួនឱ្យគេទៀតដោយឥតប្រកែក ដោយទុកចិត្តថាគេនឹងក្លាយជាអនាគតប្តី

នាង ក្នុងពេលឆាប់ៗនេះទៅហើយ តើនាងនៅកំណាញ់ខ្លួនប្រាណធ្វើអីទៀត ? ។ មិនតែប៉ុណ្ណោះ គ្មានរឿងអ្វីដែលគួរបារម្ភឡើយ ព្រោះសុផលបានផ្តល់ថ្នាំការពារឱ្យនាងថែមទៀត គឺនាងអាចស្វែងរកថានសួគ៌ឃើញយ៉ាងងាយៗស្រួលបំផុត ជាមួយបុរសកំពូលស្នេហ៍នេះ

បន្ទាប់ពីនាងបានជួបគ្នាជាលើកទីពីរ នៅលើឆ្នេរខ្សាច់ក្នុងពាតស្ទឹងសម្ងាត់នោះមក អារម្មណ៍របស់រំដួលដូចកាន់តែពុះកញ្ជ្រោលជាងមុនទៅទៀត ព្រោះសុផលបានធ្វើឱ្យនាងនឹកឃើញគេ និងចង់ចិតនៅជិតគេជានិច្ច ។

នាងហាក់ដូចជាភ្លេចភ្លាំងអ្វីអស់ ហើយទន្ទឹងចង់តែជួបជាមួយយុវបុរសសំណពច្រើនដងទៀត នៅកន្លែងស្ងាត់នោះ ដោយភ្លេចគិតថា ក្នុងពេលជាមួយគ្នានេះ ព្រិទ្ធបាលឯកចំណាន បានធ្វើអ្វីខ្លះចំពោះនាងនោះឡើយ ។

ស្រាប់តែនៅរសៀលថ្ងៃនោះ ម្តាយនាងបានមកពីព្រែកហ្លួង ដោយបាននាំនាំដំណឹងពិសេស មកប្រាប់នាងថា ព្រិទ្ធបាលឯកចំណាន បានឱ្យអ្នកផ្លូវចៅមហា ចូលមកស្តីដណ្តឹងនាងហើយ ។គាត់ក៏បានសំរេចទទួលពាក្យព្រមព្រៀងហើយដែរ ។

រំដួលឮដំណឹងនេះ ក៏ធ្លាក់ទឹកចិត្តជាខ្លាំង តែខំរក្សាឥរិយាបថមិនឱ្យម្តាយសង្ស័យបានឡើយ ដោយគ្រាន់តែពោលថា ÷

-« ម៉ែចក៏ប្រញាប់ម្ល៉េះ ខ្ញុំបានអង្វរគាត់ថា ចាំឱ្យខ្ញុំកាន់ទុក្ខខ្មោចពុក បានរួចរាល់ហើយសិន !..»

-« តែគេថា គេដណ្តឹងទុក !...» មីងទួនតបដោយស្ទង់ចិត្តកូន

«...ប្រហែលពីរបីខែទៀត ទើបបានរៀបការ !... ម៉ែមិនបានឱ្យដំណឹងមកកូនទាន់ទេ ព្រោះគេទៅនោះ ម៉ែមិនបានដឹងជាមុន តែម៉ែគិតថា ទោះបីយ៉ាងណាក៏កូនពិតជាយល់តាមម្ដាយ ដូចដែលម្ដាយធ្លាប់ប្រាប់កូនពីថ្ងៃមុន !..»

ឆោមទេវី ទ្រហោរយំក្នុងចិត្ត ឥតឱ្យម្ដាយដឹង ហើយសម្លឹងមុខគាត់ សួរពីរបីម៉ាត់ទៀត ÷

-«ស្រេច...លើម៉ែចុះ !.... តែ... តើបងយស់... គាត់យ៉ាងម៉េចដែរ ពេលនោះ ?...»

-«យស់ វាមិននៅទេ វាទៅជាមួយទាហានស្រុក ទៅតាមចាប់អាត្រខ្មៅ នៅឯព្រៃរនាម !.... ឮថា គេប្រហែលជាបាញ់សម្លាប់បានអាត្រខ្មៅនោះហើយ !...»

ឆោមទេវី រាងដូចជាភ្ញាក់បន្តិច ÷

-«ចុះ លោកចំណានមកប្រាប់ខ្ញុំថា វាចូលសារភាពហើយ?»

មីងនួន ញញឹមស្ងួត ÷

-«វាចេះតែបោះពាក្យថាយ៉ាងហ្នឹង តែមានទាន់ចូលឯណា ថែមទាំងដើរធ្វើបាបឆក់ប្លន់ កាប់សម្លាប់អ្នកស្រុកកាន់តែខ្លាំងឡើង ឥឡូវគេរួមគ្នាកំទេចវាហើយ...! ឯលោកចំណានបានលេសហ្នឹង ដើម្បីបង្កំចូលមកដណ្ដឹងកូន ! មើលទៅ គេស្រឡាញ់កូនពិតហើយ ចូរកូនថែរក្សាខ្លួនឱ្យល្អ សំរាប់ចូលរោងការជាមួយគេណា ! ព្រោះម៉ែមានសង្ឃឹម តែលើកូនម្នាក់នេះឯង ជាដង្ហើមចុងក្រោយ !...»

៚ ៚ ៚

**មឹង**នួន មកលេងនឹងកូនបានពីរថ្ងៃ ក៏ត្រឡប់ទៅព្រែកហ្លួងវិញ ដោយឥតបានដឹងរឿងស៊ីជម្រៅ របស់កូនស្រីជាមួយកូនប្រុសអ្នកលក់ថ្នាំពេទ្យនោះឡើយ ។ ចំណែកនាងឡឹងក៏មិនហ៊ានប្រឆាំងនឹងបំណង របស់មឹងនួនដែរ ទោះបីជានាងមានទំនោរ ចង់ឱ្យរំដួលរៀបការជាមួយសុផលក៏ដោយ ។ ទើបនៅពេលដែលមឹងនួនចេញផុត នាងឡឹងបានខ្សឹបសួររំដួលថា ÷

-«បងមើលទៅ ឯងនិងសុផលដូចជាស្រឡាញ់គ្នា ! អ៊ី !.. ចុះម៉េចក៏មិនប្រាប់ឱ្យសុផល គេចូលមកស្តីដណ្តឹងឯងឱ្យឆាប់ទៅ ? ទាល់តែគេដណ្តឹងមុនផុត គួរឱ្យស្តាយណាស់ !...»

រំដួល តបដោយលាក់គំនួច ÷

-«ខ្ញុំបានប្រាប់គាត់ដែរ តែមិនដឹងយ៉ាងណាបានជាយឺតយ៉ាងនេះ ?...»

....**ទោះ**បីជាបានដំណឹងថា ចំណានចូលដណ្តឹងនាងហើយក៏ដោយ ក៏រំដួលសង្ឃឹមថា នៅតែបីបួនថ្ងៃទៀត សុផលពិតជាមកដណ្តឹងនាងមិនខកខានឡើយ ។ ហើយពេលនោះ នាងនឹងទៅអង្វរម្តាយនាង ឱ្យសុំដកពាក្យពីចំណានវិញ ទោះជាមានបញ្ហាអ្វីក៏ដោយ ក៏នាងតស៊ូប្រឈមមុខ មិនខ្លាចអ្វីទាំងអស់ ព្រោះនាងស្រឡាញ់តែសុផលម្នាក់ប៉ុណ្ណោះ ។

ចំណែកសុផលវិញ ប្រហែលមកពីចាប់ចំណុចខ្សោយរបស់បុប្ផាព្រែកហ្លួងបាន ថានាងស្រឡាញ់គេដោយឈ្ងក់វង្វេងនោះហើយ ទើបបានជាមុនដល់ពេលកំណត់ គេបានលួចពេលទៅជួបបុប្ផាស្នេហ៍ពីជា

មួយស្រីស្រុកស្រែ ចំនួនពីរដងទៀត នៅពេលស្ទឹងសម្ងាត់ដូចមុន ។ ដែលព្យាយាមយកចិត្តគេថែម ដោយធ្វើយ៉ាងណាឱ្យគេកាន់តែមាន សេចក្ដីសុខ ដើម្បីឆាប់បានចូលមកដណ្ដឹងនាង ។ ប៉ុន្តែ ក្រោយពី បានខ្លួននាងចំនួន ៤ដង យ៉ាងឆ្អែតស្កប់ស្កល់នោះមក សុផលក៏បាត់ ដំណឹងរហូត ទោះបីជាមកដល់ថ្ងៃណាត់ថាចូលដណ្ដឹងហើយ ក៏នៅ តែមិនឃើញគេដែរ ។

មួយអាទិត្យ ដប់ថ្ងៃ ម្ភៃថ្ងៃ រហូតមួយខែ ក៏នៅតែមិនឃើញ សុផលនាំឪពុកម្ដាយគេ មកស្ដីដណ្ដឹងរំដួល ដូចពាក្យដែលគេបាន អះអាងនោះដែរ ។ ហើយមិនត្រឹមតែមិនឃើញលេចមុខប្រុសកម្លោះ នេះ មកមុជទឹកដូចមុនប៉ុណ្ណោះទេ សូម្បីតែនាងសំក៏មិនឃើញដែរ គឺទូកនាងបែរជាមានម្ចាស់ថ្មីមកនៅ ទំនងជានាងបានលក់ទូកនេះ ហើយទៅទិញផ្ទះ នៅលើគោកទៅហើយ ។

រំដួល ចាប់ផ្ដើមមានអារម្មណ៍ស្រងូតស្រងាត់ ជារៀងរាល់ថ្ងៃ ដោយចិត្តគួចទឹកទៅដល់សុផល គ្មានលោះពេលមួយវិនាទីឡើយ ។ ទន្ទឹមនោះ នាងដូចជាដាច់ខ្សែរយៈទំនាក់ទំនងអស់រលីង ព្រោះមិន ដឹងផ្ដាំផ្ញើពាក្យទៅសួរសុផលតាមអ្នកណា ។ តាមពិត នាងមិនដែល ចុះឡើងទៅកាន់ផ្ទះលក់ថ្នាំពេទ្យនោះ ម្ដងណាសោះ គឺនៅតែក្នុង ទូករហូត តាំងពីមកនៅជាមួយបង ទើបតែឡើងទៅមើលល្ខោននៅ សាលាពិសេស្យពេលយប់ និងទៅលេងអន្លង់កែវពេលថ្ងៃប៉ុណ្ណោះ ។

នឹកម្ដងៗ នាងចង់ប្រើក្មួយប្រុសនាង ឱ្យយកសំបុត្រទៅឱ្យ សុផល តែក្រែងមិនជួប នាំតែបែករឿងអាស្រូវវែងឆ្ងាយ ។

នៅទន្ទឹងនឹងពេលដែលនាងទៅកាន់ផ្ទះសុផល រំដួលក៏តែងទទួលបំណានមកលេងជាញយៗ ពីព្រោះគេក៏គិតរកថ្ងៃរៀបការរបស់គេ ដែលប្រហែលជាបីបួនខែក្រោយពីថ្ងៃនេះហ្នឹង គេនឹងសូមរៀបការជាមួយនាងហើយ ។

មីងនួន ក៏មានបំណងចង់នាំប្អូនត្រឡប់ទៅនៅឯព្រែកហ្លួងវិញដែរ តែនាងសុំនៅលេងជាមួយបងតទៅទៀត រហូតដល់ថ្ងៃរៀបការ ដែលនេះគ្មានអ្វីក្រៅពីលេស ដើម្បីចាំជួបបុរសជាទីស្រឡាញ់របស់នាងនោះឡើយ ។

គិតពីផ្ទះលក់ថ្នាំពេទ្យស្ទឹងសង្កែ ទៅកាន់ផ្ទះដែលនាងស្នាក់នៅ មិនជាឆ្ងាយប៉ុន្មានសោះ ប៉ុន្តែហាក់ដូចជាមានឧបសគ្គអ្វីរាំង ឱ្យប្រែក្លាយទៅជាឆ្ងាយរាប់រយយោជន៍ទៅវិញ ។

ជាងកន្លះខែកន្លងទៅទៀត រំដួលព្រែកហ្លួងមានអាការៈប្រែប្រួលក្នុងខ្លួនជាខ្លាំង គឺនាងចេះតែស្រៀវចិត្តញាក់ រមួលពោះក្អួតចង្អោរ ហើយដង្ហើមក៏រត់ប្រដេញគ្នាស្ទើរតែដាច់ប្រាណម្ដងៗ ជាហេតុធ្វើឱ្យនាងឡើងមានការសង្ស័យ តាមការជាប់ជាកិច្ច រហូតដល់ថ្ងៃមួយ នាងឈ្លបសួរប្អូនថា ÷

-«រំដួល... ឯងយ៉ាងម៉េចហ្នឹង ? ពុ... មើលទៅ ឯងប្រាកដជាមានផ្ទៃពោះហើយ !...»

ក្រោយដែលឮនាងឡើង ចុចចំចំណុចខ្សោយដូច្នេះ រំដួលក៏សារភាពប្រាប់បងតាមត្រង់ ពីអ្វីៗ ដែលនាងបានភាន់ច្រឡំកន្លងមកជាមួយសុផល ហើយនាងសូមអង្វរឱ្យនាងឡើងជួយជូននាងទៅជួប

សុផល ដើម្បីសួរបញ្ជាក់ ថាមូលហេតុអ្វីបានជាគេកុហក់នាង ថាមក ស្ដីដណ្ដឹង តែប្រែជាបាត់សូន្យឈឹងយ៉ាងនេះ ? ។

វណ្ណលព្រែកហ្លួង បានបន្ទឺទាំងទឹកភ្នែកបន្ថែមទៀតថា ÷

-« គេបានកុហក់ខ្ញុំ ថាមានថ្នាំការពារ...! ហេតុតែខ្ញុំស្រឡាញ់ គេពេក និងជឿថាគេស្រឡាញ់ខ្ញុំដោយស្មោះវិញនោះ ខ្ញុំក៏ព្រមប្រគល់ ខ្លួនឱ្យគេ...! សូមបងជួយលាក់រឿងនេះ កុំអាលឱ្យម៉ែដឹងអី !...»

ដោយអាណិតប្អូនពេក នៅពេលព្រលប់ៗនៃថ្ងៃនោះ នាងឡឹង ដាច់ចិត្តនាំវណ្ណលទៅជួបសុផលដោយស្ងាត់ៗ នៅហាងលក់ថ្នាំពេទ្យ ស្ទឹងសង្កែ ។ ប៉ុន្តែ មិនបានជួបសុផលតាមបំណងឡើយ គឺជួបតែ ឪពុកម្ដាយគេ ដែលមានអាក្បារៈជាមនុស្សវ៉ាយប្ញកឆ្មើងឆ្មៃ ទាំងប្ដីទាំង ប្រពន្ធ ហើយភាប់មើលងាយអ្នកដែលក្រខ្សត់ខ្សោយជាងខ្លួនទៀតផង។

ដោយធ្លាប់ឃើញនាងឡឹង ចូលទៅទិញថ្នាំនៅហាងរបស់ខ្លួនជា ញឹកញាប់ដែរ អ្នកស្រីម្ចាស់ហាងក៏សួរមុនថា ÷

-« អ៊ើ... ម៉េចអ្នក មកចង់ជួបសុផលនោះ វ៉ាមិននៅទេ មាន ការអី ផ្ដាំផ្ញើត្រឹមខ្ញុំមកបានទេ ?...»

នាងឡឹង ក៏ចាប់រៀបរាប់រឿងវណ្ណលជាមួយសុផលភ្លាម ÷

-« ខ្ញុំចង់មកជំរាបអ្នកស្រីថា បើកូនអ្នកស្រីមានការពាក់ព័ន្ធជា មួយប្អូនស្រីខ្ញុំដល់ថ្នាក់មានពោះពុងយ៉ាងនេះហើយ តើគួរគិតយ៉ាង ណាទៅ...? ខ្ញុំជឿថា លោកប្រុសអ្នកស្រី ប្រាកដជាបានដឹងរឿង នេះដែរ ព្រោះសុផលគេប្រាប់ថា អ្នកស្រីព្រមចូលទៅស្ដីដណ្ដឹងប្អូន ខ្ញុំ !...»

ឪពុកម្ដាយសុផល ពេលនោះពាក់មុខយក្សភ្លាមមួយរំពេចហើយ ប្រាស់មកវិញដូចមាន់ ដោយបញ្ចេញឫក ការពារកូនយ៉ាងពេញទំហឹង ៖

-«ខ្ញុំគ្មានទទួលដឹងរឿងនេះទេ ព្រោះកូនខ្ញុំនៅតែដប់ថ្ងៃទៀត ត្រូវរៀបការជាមួយគូដណ្ដឹងវាហើយ ។គ្មានហេតុផលអ្វី ដែលថាវាទៅស្រឡាញ់ប្អូនអ្នកនោះទេ រឿងនេះចាំជួបជាមួយវា ដោះស្រាយជាមួយវាទៅ ខ្ញុំមិនដឹងអីទាំងអស់ !...»

រំដួល ចាប់ផ្ដើមមានបេះដូងរំជួលក្ដៅផ្សាពន់ប្រមាណ នៅពេលដែលឮឪពុកសុផលឆ្លើយឃ្មាំងៗទៀតថា ៖

-«ម៉េច ឃើញកូនខ្ញុំរៀនខ្ពស់ ចង់គោងទាមដើម្បីឱ្យបានកេរមត៌កពីខ្ញុំអ្ហ៎ !... ឥតអំពើទេ !! ទៅដើរលេងមានប្រុសឈ្មោលឯណាមិនដឹងមុខ មិនដឹងបាត បែរជាចង់មកក្លាវកូនខ្ញុំទៅវិញ...ចេញពីមុខផ្ទះខ្ញុំឱ្យឆាប់ទៅ !...»

គ្រាន់តែឮសំដីទាំងពីរឃ្លានេះភ្លាម រំដួលក៏បបួលនាងឡឹងត្រឡប់មកទូកវិញ ដោយឈឺចាប់ក្ដៅក្រហាយស្ទើរតាំងបេះដូងស្លាប់ ។

ស្រីអភ័ព្វយំរហូតមិនឃ្លានបាយឃ្លានទឹក ដោយទ័លប្រាជ្ញាមិនដឹងធ្វើយ៉ាងណាស្រាយបញ្ហានេះរួច ៖

-«បងមិនដឹងជួយឯងយ៉ាងណាកើតទេ រំដួល មានតែប្រាប់មីងឱ្យដឹង ! » នាងឡឹងផ្ដើមគំនិត «....ព្រោះគេអាង គេមានទ្រព្យសម្បត្តិ.... គេមិនខ្លាចយើងទេ !...»

រំដួលអង្វរបងជីដូនមួយ ទាំងអួលអាក់ ៖

-« កុំអាលប្រាប់ម៉ែអីបង ព្រោះខ្ញុំចង់ជួបបងសុផលឱ្យអស់ចិត្តសិន តើគាត់ជិតរៀបការមែនឬមិនមែន តែគាត់បានស្បថសច្ចាថាស្រឡាញ់ខ្ញុំពិត !... ខ្ញុំក្រែងឪពុកម្ដាយគាត់ចេះតែថា ឱ្យស្ដែបពីមាត់ទៅ !...»

.....**មួយ**អាទិត្យក្រោយមកទៀត....

ស្រាប់តែនាងឡឹង បានជួបនឹងនាងសំដើរទិញបន្លែ ក៏បានឱ្យបប្រាប់រឿងរំជួលទាល់តែអស់ ហើយនាងសំក៏ស្ទុះរឹងមកជួបរំជួលនៅឯទូកជាបន្ទាន់ ។

ស្រីអភ័ព្វ គ្រាន់តែឃើញនាងសំក៏ទឹកអរភើត ទើបដេញសួរភ្លាមថា ÷

-« បងសំ ធើម៉េចបានជួបបងសុផលទៅ... បងមានដឹងថាគាត់នៅឯណាទេ ខ្ញុំចង់ជួបគាត់ណាស់ !...? »

នាងសំ បែរជាមានទឹកមុខមាំ ហើយសួរមកវិញ ÷

-« បងឡឹងបានប្រាប់រឿងរំជួលឯង ឱ្យបងដឹងអស់ហើយ ! ហ៊ីគួរឱ្យក្ដៅណាស់ បងមិនដឹងថាចិត្តគេយ៉ាងនេះសោះ កឡូវយើងនៅស្ងៀមមិនបានទេ រឿងដល់ថ្នាក់នេះហើយ ត្រូវតែប្ដឹងតុលាការឱ្យរកខុសត្រូវឱ្យ..! ចុះសំបុត្រ ដែលគេធ្វើមករំជួលឯង មានបានរក្សាទុកទេ ?...»

-« សំបុត្រទាំងនោះ នៅទាំងអស់ទេបង !... តែ ស្ដាប់ខ្ញុំសិនខ្ញុំមិនចង់ប្ដឹងប្ដល់អីទេ ព្រោះខ្ញុំមិនចង់ឱ្យគាត់ស្រឡាញ់ខ្ញុំ ដោយការបង្ខំពីអ្វីមួយឡើយ !... សំខាន់គឺខ្ញុំចង់តែជួបគាត់ផ្ទាល់ប៉ុណ្ណោះ សូម

បងស្វះស្វែងរកគាត់ឱ្យឃើញ !... ហើយប្រាប់ឱ្យគាត់មកជួបខ្ញុំមួយភ្លែត មុនដែលគាត់រៀបការនេះ ហើយគំរាមគាត់ថា បើគាត់មិនមកប្រយ័ត្នខ្មាស់គេនៅពេលរៀបការនោះ ?...»

នាងសំ ជញ្ជឹងគិតបន្តិច ទើបឆ្លើយ ÷

-«មិនអីទេ បើឯងយល់យ៉ាងនេះ... ចាំបងខំ...រក និងជួយប្រាប់ឱ្យ !...»

ដោយការខ្នះខ្នែងរបស់នាងសំ យប់នោះ ស្រាប់តែលេចមុខសុផលមកជួបនឹងរំដួល នៅឆ្នេរខ្សាច់បាតស្ទឹងដូចមុន បន្ទាប់ពីបាត់ពីរខែ ដែលគេបានបែកពីនាង ÷

-«...រំដួល អូនកុំខឹងនឹងបងឱ្យសោះ ការពិត បងបានប្រាប់ឪពុកម្ដាយបងឱ្យមកដណ្ដឹងអូនមែន តែមិនដឹងជាយ៉ាងម៉េច គាត់បែរជាទៅដណ្ដឹងកូនអ្នកដទៃទៅវិញ ? បងដឹងរឿងនេះ ក្ដៅក្រហាយណាស់ ទើបគេចមុខពីគាត់រហូត ប៉ុន្តែឥឡូវ បងត្រូវតែរៀបការបំពេញមុខមាត់គាត់បានពីរបីថ្ងៃសិន បងនឹងមកនាំអូនរត់ ទៅនៅស្រុកឆ្ងាយហើយ សូមអូនជឿចិត្តបងចុះ បងមិនភ្លេចអូនទេ !...មិនភ្លេចអ្វីទាំងអស់ ដែលយើងបានសាងរួមគ្នា នៅក្នុងដងស្ទឹងសម្ងាត់នេះ !...»

មិនដឹងជារំដួល ជឿឬមិនជឿយ៉ាងណានោះទេ ប៉ុន្តែនាងផ្ដេកក្បាលទៅលើដើមទ្រូងគេ រួចពោលពេញដោយទឹកភ្នែកថា ÷

-«អូនតែងតែជឿបង ជឿរហូតដល់លះបង់ខ្លួនប្រាណឱ្យបងទៀត ហើយជឿថាថ្នាំដែលបងឱ្យនោះ អាចការពារអ្វីៗបាន ប៉ុន្តែ...

ពេលនេះ អូនចាប់មានផ្ទៃពោះហើយ !..»

សុផល ធ្វើដូចជាភ្ញាក់ ហើយពោលយ៉ាងខែងរ៉ែងទៀត ÷

-«ទេ ថ្នាំនេះ មានប្រសិទ្ធភាពណាស់ណាំ ម៉េចប្រែទៅជាយ៉ាងហ្នឹងទៅវិញ ឱ ! ប្រហែលជាវាហួសដីឡេ !... បងប្រទ្បំមិនបានពិនិត្យហ្មត់ចត់ ប្រញាប់យកមកឱ្យអូន !... តែមិនអីទេ បើទើបនឹងចាប់ផ្ដើមយ៉ាងនេះ អូនអាចឱ្យគេយកចេញក៏បាន គ្មានបញ្ហាអ្វីទេ ប៉ុន្តែបើអូនស្ដាយ ព្រោះគេមកចាប់កំណើតហើយ ៗវាជាចំណងដៃស្នេហ៍របស់យើងទាំងពីរផងនោះ បងត្រូវតែទៅតវ៉ា ប្រាប់រឿងនេះដល់ឪពុកម្ដាយបងឱ្យដឹង ដើម្បីឱ្យគាត់ទទួលស្គាល់អូន ដែលត្រូវបង្កើតចៅឱ្យគាត់ទៅថ្ងៃមុខ !..»

វណ្ណល នៅតែខ្សឹកខ្សួលជាប់រហូត ÷

-«...រឿងនេះ អូនគ្មានសង្ឃឹមលើអ្នកណាទេ សូមបងជួយគិតអូនផង !..»

សុផល លើកដៃអង្អែលសក់ស្រីស្រស់ ហើយប្ដេជ្ញាសាជាថ្មី ÷

-«មិនអីទេ ! ឥឡូវអូនប្រគល់សំបុត្របងទាំងប៉ុន្មាន មកឱ្យបងវិញមក ដើម្បីបងយកទៅធ្វើភស្តុតាង សំរាប់ចាប់បង្ខំពួកគាត់ឱ្យទទួលស្គាល់អូន និងឱ្យជឿជាក់ថាបងពិតជាមានទំនាក់ទំនងជាមួយអូនមែន !... អូនកុំភ័យ បងនឹងតស៊ូពុះពារគ្រប់យ៉ាងដើម្បីអូន! »

ដោយជឿជាក់ថាសុផល ពិតជាយកសំបុត្រនោះ ទៅធ្វើជាភស្តុតាងសំរាប់ដោះស្រាយបញ្ហាតានតឹងនោះមែន បូផាព្រែកហ្លួងក៏ព្រមប្រគល់សំបុត្រទាំងអស់របស់សុផល ដែលផ្ញើមកនាងទាំងប៉ុន្មានត្រឡប់ក្រោយទៅគេវិញ ។....

✻ ✻ ✻

# ៨

# ស្នឹងសម្ងាត់

**តែ**មិនត្រឹមតែមិនខុសពីពពុះសាប៊ូ ដែលគេផ្លុំបណ្តែតចោលតាមខ្យល់នោះឡើយ គឺពាក្យធានាអះអាងចុងក្រោយរបស់សុផលទាំងប៉ុន្មាន បានរសាត់បាត់ឆ្ងាយទៅ ដូចជាខ្សែទឹកហូរក្នុងជងស្នឹងសង្កែយ៉ាងនោះ ព្រោះគេមិនឃើញសុផលវិលត្រឡប់មកប្រាប់នាងវិញទាល់តែសោះ ។

នាងសំ និយាយថា សុផលបានលួងលោមយកសំបុត្រពីរវ៉ូលទៅនេះ គឺពិតជាមានបំណងបំបាត់ភស្តុតាង នៃចំណងទាក់ទងនេះច្បាស់លាស់ ព្រោះគេខ្លាចវ៉ូលយកភស្តុតាងនេះ ទៅប្តឹងដល់តុលាការ ។ ឥឡូវ បើអស់រលីងពីខ្លួនយ៉ាងនេះហើយ តើមានអ្វីជាកម្លាំងអាចយកឈ្នះលើគេបាន ។ ទោះបីជានាងទៅអុកឡុកនៅពេលរៀបការ ក៏អាចនឹងគ្មានអ្នកណាគេជឿនាងដែរ ព្រោះគេមានលុយ គេអាចសូកប៉ាន់អាជ្ញាធរ ឱ្យកាយកប់ត្រឡប់ជាន់ រឿងត្រូវទៅជាខុសបាន ហើយជួនកាលនឹងអាចមានទោស ពីបទមួលបង្កាច់បង្ខូចកិត្តិយសគេថែមទៀតផង ។

រឿងនេះ មានតែម៉្យាងប៉ុណ្ណោះ គឺនៅពេលដែលកូនកើតមក គេអាចចាក់យកឈាមកូននេះទៅវិភាគ ទើបមានភស្តុតាងច្បាស់មិនអាចប្រកែកបាន ព្រោះឈាមឪពុកនិងឈាមកូន រមែងដូចគ្នា ។

នេះជាទស្សនៈដោយឡែកប៉ុណ្ណោះ តែសំរាប់នាងរំដួលវិញ នាងយល់ផ្ទុយពីគេថា បើទុកណាជានាងប្តឹងប្តល់ឱ្យគេទទួលស្គាល់ ក៏នាងមិនមានសេចក្តីសុខដែរ ព្រោះឪពុកម្តាយគេមិនពេញចិត្ត ហើយថែមទាំងគេដើរកលល្បិចបោកប្រាស់បេះដូងនាងបែបនេះទៀត នាងពិតជាមិនអាចរកសុភមង្គលបរិសុទ្ធឃើញទេ ។ គឺអ្វីទាំងអស់ វាបណ្តាលមកពីភាពល្ងិតល្ងង់ខ្លៅរបស់នាងប៉ុណ្ណោះ ដែលបង្កទៅជាកំហុសមួយ ពោរពេញដោយវិប្បដិសារីគួរឱ្យសោកស្តាយ និងឈឺចាប់ជាទីបំផុត ។

ដោយការឈឺចាប់ឥតព្រំដែន
រំដួលអួលណែនសែនខ្លោចផ្សា
មិនអាចទ្រាំនៅស្តាប់ភ្លេងការ
ស្រស់ស្រីយាត្រាទៅស្រុកវិញ ។

ទោះនាងខំទ្រាំលាក់ការពិត
ក៏លាក់មិនជិតបែករឿងពេញ -
ចំណានក៏សុំដកពាក្យវិញ
មីងន្ទួនទោម្នេញព្រោះខ្មាស់គេ ។

រំដួលនឹកខ្មាស់យស់ពន់ពេក

មានតែទឹកភ្នែកហូរជាទេ
នាងមិនអាចទ្រាំនៅបានទេ
មាសមេក៏រត់ចេញពីស្រុក ។

សូម្បីតែម្ដាយក៏មិនប្រាប់
ឥតបានសារស័ព្ទប្រាប់សុខទុក្ខ
ញាតិមិត្តសោកស្ដាយពេញភូមិស្រុក
ព្រោះតែបាត់មុខស្រស់ចរណៃ ។

មីងនួន នាងឡឹង ព្រមទាំងយស់
ស្វែងរកស្រីស្រស់ទាំងយប់ថ្ងៃ
នៅតែមិនឃើញរំដួលស្រី
កើតទុក្ខរីងរៃគ្រប់ៗគ្នា ។

ថ្លែងពីសុផលប្រុសព្រានស្នេហ៍
ឈប់នៅសង្កែដែនភារា
ក្រោយពេលការបាន ប្រាំទិវា
ក៏នាំភរិយាទៅភ្នំពេញ ។

បំភ្លេចរំដួលឃុំព្រែកហ្លួង
ដែលធ្លាប់លោមលួងសូមស្រឡាញ់
ដូចទឹកហូរទៅ មិនវិលវិញ
រស់នៅពោរពេញដោយសុខា ។

រដូវមួយៗ ផ្លាស់ទៅមក
ទឹកស្រកខកចិត្តឆ្អិតឱរា
នាំយកស្នាមស្នេហ៍អនុសារ
ដែលបានគូរចារលើឆ្នេរខ្សាច់ ។

ផ្លាស់ផារដូវទឹកជំនន់
ទឹកហូរជោរជន់លឿនជានិច្ច
ក្លិនស្នេហ៍ប្រែជាត្រូវបំភ្លេច
ខ្សែទឹកគួចលិចក្នុងព្យុះកម្ម ។

ឥឡូវទឹកស្ទឹងស្រកជាថ្មី
យប់ថ្ងៃ ថ្ងៃយប់គ្រប់មួយឆ្នាំ
ឆ្នេរខ្សាច់មាត់ទឹកហាក់នៅចាំ
រឿងស្នេហ៍បែកស្រាំពីឆ្នាំមុន ។

ស្រាប់តែព្រឹកនេះ គ្រប់ៗគ្នា
ព្រឺព្រួចអង្គារ ផ្អើលពេកពន់
ប្រទះឃើញខ្មោចស្រីតូចតន់
រំដួលសោភ័ណ លើឆ្នេរខ្សាច់ ។

នាងដេកស្ងាប់ស្រួលសែនអាណិត
ទារកនៅជិតយំមិនដាច់

ព្រមទាំងអក្ខរាចារពាក្យពេចន៍
រៀបស្រេចធ្វើទុកជាអំណើង ។

នាងសំដែលធ្លាប់ស្គាល់ស្រីស្ងួន
និមន្ទួនត្រូវជាប្អូននាងឡេង
បានរត់ទៅប្រាប់ជាដំណឹង
នាងឡឹងស្ទុះរឹងមកមើលខ្ញី ។

ហើយប្រាប់បន្តទៅអីងធ្លួន
ញាតិមិត្តបងប្អូនទាំងប្រុសស្រី
នាំគ្នាមកមើលសពចរំណោ
និងកូនតូចខ្ចីសែនកំសត់ ។

ជួនជាថ្ងៃនោះ នាយសុពល
ក៏បានមកដល់ជួបសន្ធត
ម្ដីម្នា នាំគ្នាមើលសំបុត្រ
ដែលស្រីកំសត់ធ្វើទុកឱ្យ

ជូនអ្នកមានគុណធ្ងន់បំផុត
នេះជាសំបុត្រកូនចុងក្រោយ
កូនសូមលាម៉ែទៅឆ្ងាយហើយ
ម៉ែអើយនេះគឺកម្មកូនពិត ។

ហេតុតែកូនស្រឡាញ់គេហួស
ទើបបានជ្រុលជ្រួសហួសក្រមក្រិត្យ
បំពានច្បាប់ស្រីប្រពៃពិត
ភ្នែកភ្លឺដូចល្ងិតព្រោះតណ្ហា ។

បងយស់សុំស្នេហ៍បែរមិនឆ្លើយ
ធ្វើប្លកតោះតើយមិនវាចា
នឹកដល់បងយស់សែនសោកា
ហេតុតែស្នេហា ទ្រាំចាំខ្ញុំ ! ។

មិនគួរចិត្តបើក បើកឱ្យគេ
កូនក្បត់ចិត្តម៉ែ ដែលខិតខំ
ប្រដៅពីតូច រហូតធំ
កូនពេញក្រមុំដើរផ្លូវខុស ។

ស្តាយកេរ្តិ៍កិត្តិយសឈ្មោះជាស្រី
ឥឡូវអប្រិយ៍ស្អុយខ្ជួរខ្ជោះ
ភ្លើតភ្លើនភ្លេចខ្លួនជឿពាក្យប្រុស
ចិត្តខ្មៅទុរយសព្រោះតណ្ហា ។

សូមផ្តាំអស់ស្រីខ្មែរជាន់ក្រោយ
កុំបីបណ្តោយឱ្យស្នេហា

ដឹកនាំប្រមុះសោះឡើយណា
កុំជឿវាថាប្រុសរូបល្អ ។

កុំស្រឡាញ់គេជ្រុលហួសហេតុ
ឃើញភ្នាមស្នេហ៍ភ្លេតឥតគិតយូរ
ឃើញតែរូបគេដូចគំនូរ
ញាប់ជឿផ្តាច់ប្តូរស៊ូស្លាប់រស់ ។

ហេតុតែជាស្រីនៅជនបទ
ដូចសំពត់ផ្ទត់ល្អឥតខ្ចោះ
មិនធ្លាប់ស្គាល់ស្នេហ៍ស្គាល់ចិត្តប្រុស
គេនាំធ្លាក់ជ្រោះ ក៏មិនដឹង ។

ជឿថាគេស្មោះអស់ពីចិត្ត
ឱ្យគេអោបរិតរួតព្រលឹង
សាងស្នេហ៍លើគ្រែខ្សាច់ក្នុងស្ទឹង
ឥតអ្នកណាដឹងរឿងខ្ញុំទេ ។

គេល្បួងលោមថានឹងចូលស្តី
គេប្រើសំដីប្លែមជាទ្វេ
ខ្ញុំលះបង់អស់ដើម្បីគេ
កឡូវបុព្វេផ្តល់ឱ្យហើយ ។

គេបែរជារៀបការស្រីផ្សេង
ឱ្យខ្ញុំបំបែងគ្មានកោះត្រើយ
បិត្តប្រុសទុរយសណាស់ម៉ែអើយ
គេមិនស្គាល់ឡើយកូនក្នុងផ្ទៃ ។

ខ្ញុំសែនខោមម្នេញចេញពីស្រុក
តាមទៅជួបមុខប្រុសអប្រិយ៍
នៅឯភ្នំពេញ ទាំងរីងរៃ
ក្រែងគេប្រណីដល់ខ្ញុំខ្លះ ។

គេនៅតែមិនអាណិតខ្ញុំ
កូនសែនក្រៀមក្រំទ្រូងស្ទើរស្ទះ
វិលវិញកូនមិនហ៊ានចូលផ្ទះ
ព្រោះនឹកអៀនខ្មាស់ខ្លួនអាស្រូវ ។

ក៏ទៅលាក់ខ្លួនពួនសម្ងំ
នៅក្នុងល្អាងធំភ្នំសំពៅ
បំរុងបួសជាដូនជីនៅ
យកធម៌ជាផ្លូវលាងកម្មផល ។

តែគិតយូរទៅក៏ដកចិត្ត
មិនបួសវិញពិតនាំឱ្យខ្វល់

ខ្លួនក្លិនអាសោចត៍ ស្អុយប្រាសខ្យល់
នាំឱ្យអំពល់ផល់សាសនា ។

ក៏ទ្រាំរស់នៅដោយធាយវត្ត
អត់ធ្មត់ឱ្យផ្ទៃគ្រប់មាសា
ទើបវិលមកចូលពេទ្យរាជការ
សំរាលបុត្រាណាម៉ែអើយ ! ។

វាពិតជាឈាមប្រុសទុរយស
តែកូនស្រណោះគ្នាកើតហើយ
ទើបទ្រាំពរពោះទ្រូងកត់សើយ
នេះហើយព្រោះជឿពាក្យលោលប្រាស់ ។

កូនស៊ូលេបថ្នាំធ្វើអត្តឃាត
មិនអាចរស់ទៀត ព្រោះកូនខ្មាស់
សូមឱ្យជាតិក្រោយផុតកម្មក្រាស់
ផ្លាស់បិត្តកើតជាកូនម៉ែទៀត ។

ខ្មាស់ទាំងបងឃស់ លោកបំណាន
ខ្មាស់ទាំងភូមិថាន សន្តានញាតិ
ខ្មាស់អស់មនុស្សសត្វ ខ្មាស់ធម្មជាតិ
ឱ្យកូនរស់ទៀត ម្តេចកើតទៅ ? ។

កូនមិនសងសឹកនឹងគេទេ
តែសូមស្រីខ្មែរ ដែលរស់នៅ
កុំជាប់ស្នេហ៍ប្រុសទាំងល្ងង់ខ្លៅ
ក្រែងធ្លាក់រណ្តៅទុក្ខដូចខ្ញុំ ។

ស្នេហ៍ពិត មិនមែនជាតណ្ហា
ត្រូវពិចារណាកុំប្រទាំ
ស្មានថាទឹកក្រុត ជាទឹកឃ្មុំ
នាំរងទុក្ខធំកេរ្តិ៍អាស្រូវ ។

សូមម៉ែយកកូនខ្ញុំទៅផង
បីបាច់ថ្នាក់ថ្នមឱ្យត្រឹមត្រូវ
ធំឡើងកុំធ្វើប្រុសថ្នើមខ្លៅ
ធ្វើបាបស្រីខ្លៅឱ្យប្រាស់ព្រាត់ ។

លាហើយបងឡឹង លាហើយម៉ែ
លាស្ទឹងសង្កែ ដែនសង្វាត់
ដែលជួយលាក់រឿងខ្ញុំវិបត្តិ
វេងស្ទឹងសង្វាត់ខ្ញុំលាហើយ ! ។

**រំជួលអភ័ព្វស្នេហ៍**

នៅពេលនោះ ខ្ញុំមិនអាចសរសេររៀបរាប់ឱ្យត្រូវពីទំហំទុក្ខសោក របស់មីងនួន តាឃយស់ នាងឡឹង និងបងប្អូនឃុំព្រែកហ្លួងវវែ

ទៀត ចំពោះមរណភាពរបស់វិរ៉ូលស្រីអភ័ព្វនោះឡើយ ។

ជាងនេះទៅទៀត គេឃើញក្រដាស់បទចំរៀង "ស្ទឹងសម្ងាត់ ដែលសុផលបានបង្ហាត់នាងច្រៀង នៅឯខ្ទមចុងចំការក្រូចអន្ទង់វិល នៅចងភ្ជាប់លើចរឹងឈើមួយ ដោតនៅក្បែរនាងនោះដែរ ។

ក្រោយពីអាជ្ញាធរ បានត្រួតពិនិត្យមើលសាកសពនោះ ថាពិតជាស្លាប់ដោយលេបថ្នាំពុលមែនហើយ មីងទួនក៏សុំអនុញ្ញាត្តិយកសពកូនទៅធ្វើបុណ្យនៅឯស្រុក ។

ចំណែកសុផលពេលនោះ ក្រោយពីបានយល់សំបុត្ររបស់ស្រីអភ័ព្វ និងត្រូវទទួលពាក្យរិះគន់ពីអ្នកជិតខាងគ្រប់គ្នា ក៏បានភ្ញាក់ខ្លួនយល់ខុស ហើយសារភាពប្រាប់ឪពុកម្ដាយថា ខ្លួនពិតជាបានទាក់ទងស្រឡាញ់នាងវិរ៉ូល និងធ្វើបាបបំភ្លេចនាងចោលមែន ។

តែអ្វីៗ វាកន្លងហួសអស់ទៅហើយ ដើម្បីលប់លាងនូវស្នាមវិប្បដិសារីដ៏វិបោគប្រេះឆានេះ សុផលបានទៅសុំយកកូនពីមីងទួនមកចិញ្ចឹមវិញ ព្រោះជាឈាមរបស់គេដែរ តែមីងទួនមិនឱ្យឡើយ ដោយគាត់ធ្វើតាមបណ្ដាំរបស់វិរ៉ូល ដែលមិនឱ្យកូននោះទៅសុផលជាដាច់ខាត ។

ទោះបីយ៉ាងនេះក្ដី ក៏សុផលមិនអាក់អន់ស្រពន់ចិត្តអ្វីទេ ហើយដើម្បីជាមធ្យោបាយកាត់បន្ថយនូវទោសកំហុសរបស់គេ ដែលបានធ្វើទៅលើនាងវិរ៉ូល ជារៀងរាល់ឆ្នាំ ឱ្យតែដល់ពេលរដូវទឹកសំរក ស្រកដល់បាតស្ទឹងឃើញខ្សាច់ សុផលតែងនាំភរិយាមកពីភ្នំពេញ មកធ្វើបុណ្យមត្តលោកជាន់ បង្សុក្កូល និងអុតធូបបួងសួងនៅលើឆ្នេរខ្សាច់

មាត់ទឹកត្រង់កន្លែងដែលគេបានបណ្ដុះអនុស្សាវរីយ៍ជាមួយនាង ដើម្បីបញ្ជូនកុសលមគ្គផលឱ្យដល់វិញ្ញាណក្ខ័ន្ធរបស់នាង ឆាប់បានទៅចាប់កំណើតនៅជាតិថ្មីទៀត ។

ចន្លឹមនោះ គេក៏តែងតែផ្ដល់ជាសោហ៊ុយលុយកាក់ ទៅឱ្យមីងនួន សំរាប់ចិញ្ចឹមកូនប្រុសនោះដែរ ។

សុផល ធ្វើបុណ្យនេះជារៀងរាល់ឆ្នាំ មិនដែលខកខាន រហូតទាល់តែមកដល់សម័យខ្មែរក្រហមចូលស្រុក ទើបលែងបានធ្វើតទៅទៀត ព្រោះមិនដឹងជាសុផលត្រូវស្លាប់ឬរស់ គឺបាត់ឈ្មោះរហូតមកទល់ពេលសព្វថ្ងៃនេះ ? ។.....

ទោះបីយ៉ាងនេះក្ដី ក៏ប្រជាជនដែលរស់នៅតាមដងស្ទឹងសង្កែ តែងចងចាំស្គាល់ឆ្នេរបទស្ទឹងសម្ងាត់ និងនាំគ្នាហាត់ច្រៀងលេងជារៀងរហូតមក ដើម្បីរំលឹកដល់ជីវិតរំដួលផ្កា បុប្ផាវិប្បយោគហ្នឹង !...។

ដោយសារមនុស្សជំនាន់នេះ ភាគច្រើនបានភ្លេចរឿងរំដួលស្ទឹងសម្ងាត់នេះទៅហើយ ខ្ញុំក៏ខំចងក្រងរឿងពិតនេះឡើងវិញ ព្រោះខ្ញុំមិនមែនអ្នកណាក្រៅពីកុមារភី កូននាងឡឹង ដែលនៅលេងក្នុងទូកជាមួយមីងរំដួលកំសត់នោះឡើយ !... ។

**❁ ចប់ ❁**

បាងកក ថ្ងៃ ២៧ ធ្នូ ២០០២

**គង្គ ប៊ុនឈឿន**

*សូមរង់ចាំអានរឿង*

# " មេឃចុះអ័ព្ទ "

ជាប្រលោមលោកបែប មនោសញ្ចេតនា...

ជីវិតតស៊ូក្រោមឥទ្ធិពលរលកយក្សស៊ូណាមិ

ដែលនឹងចេញផ្សាយក្នុងពេលឆាប់ៗ

នេះ ។ ជាស្នាដៃនិពន្ធរបស់លោក

គន្ធ ប៊ុនឈឿន